# ព្រះរាជក្រម

នស/រកម/០៣២៤/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ការដឹកជញ្ជូនតាមផ្លូវទឹក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីរក្សាសណ្តាប់ធ្នាប់ ធានាសុវត្ថិភាព សន្តិសុខនៃការដឹកជញ្ជូនតាមផ្លូវទឹក ព្រមទាំងការកសាងនិងថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ និងរួមចំណែកការពារបរិស្ថាន ព្រមទាំងផ្តល់កាលានុវត្តភាពវិនិយោគនិងការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ សមធម៌ និងតម្លាភាព សម្រាប់បម្រើពាណិជ្ជកម្មជាតិនិងអន្តរជាតិ និងទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះនាវា នាវិក កំពង់ផែ ម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ច យានដ្ឋាននាវា ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសកម្មភាពដែលពាក់ព័ន្ធផ្សេងទៀតនៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែនាវា កំពង់ផែ និងឋបនីយកណ្តាផែរបស់កងកម្លាំងមានសមត្ថកិច្ចនៃក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃ ដែលកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចគ្រប់គ្រងវិស័យដឹកជញ្ជូនតាមផ្លូវទឹកនៃព្រះរាជាណាចក្រកម្ពុជា។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យដឹកជញ្ជូនតាមផ្លូវទឹកមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## គោលការណ៍

**មាត្រា៥ .-**

គោលការណ៍នៃការគ្រប់គ្រងដឹកជញ្ជូនតាមផ្លូវទឹក មានដូចខាងក្រោម៖

- ធានាឱ្យមានលក្ខណៈសេរី យុត្តិធម៌ សមធម៌ និងគ្មានការរើសអើង សម្រាប់នាវាចរណ៍និងការចូលចេញចូលកំពង់ផែនៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃច្បាប់ជាតិនិងអន្តរជាតិ

- ជានាទប់ស្កាត់ផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ចំពោះការធ្វើនាវាចរណ៍និង/ឬការអភិវឌ្ឍកំពង់ផែ
- ជានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់ សន្តិសុខ ការរក្សាបរិស្ថាន សុខដុមនីយកម្មជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិ សម្រាប់ការធ្វើនាវាចរណ៍និងការអភិវឌ្ឍកំពង់ផែ
- អនុលោមតាមច្បាប់ជាតិនិងអន្តរជាតិ ទាក់ទងនឹងសុវត្ថិភាព សន្តិសុខ បរិស្ថាន សម្រាប់នាវា នាវិក និងកំពង់ផែ
- ជានាឱ្យមានតុល្យភាព សុខដុមនីយកម្ម និងអនុលោមភាព រវាងនាវានិងកំពង់ផែ ផលប្រយោជន៍របស់អ្នកប្រើប្រាស់និងអ្នកផ្តល់សេវា ផលប្រយោជន៍ឯកជននិងសាធារណៈ និងផលប្រយោជន៍ជាតិ និងអន្តរជាតិ។

## ជំពូកទី៤
## ការគ្រប់គ្រងនាវា
### ផ្នែកទី១
### ការគ្រប់គ្រងនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស

**មាត្រា៦ .-**

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើនាវាចរណ៍តាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការចុះបញ្ជីនាវា លើកលែងតែប្រភេទនាវាដែលប្រើសម្រាប់ដឹកជញ្ជូនជាលក្ខណៈគ្រួសារ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

ម្ចាស់នាវា ទោះជាបរទេសក្តី ដែលកាន់កាប់នាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស ត្រូវស្នើសុំចុះបញ្ជីនាវា។

ម្ចាស់នាវាភាររវេទកិច្ច ទោះជាបរទេសក្តី អាចស្នើសុំចុះបញ្ជីនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ស្របតាមកិច្ចសន្យាជាមួយម្ចាស់នាវា។

**មាត្រា៧ .-**

ការចុះបញ្ជីនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវទទួលបានវិញ្ញាបនបត្រចុះបញ្ជីនាវា ដែលមានសុពលភាពអចិន្ត្រៃយ៍ឬសុពលភាពបណ្តោះអាសន្នមិនលើសពី១(មួយ)ឆ្នាំ។

វិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេសទុតិយតាឬតតិយតា មានតម្លៃស្មើនឹងវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេសដែលបានផ្តល់ជាលើកដំបូង។

**មាត្រា៨ .-**

នាវាដែលនាំចូលពីក្រៅប្រទេសដើម្បីស្នើសុំចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស ត្រូវមានបង្កាន់ដៃពន្ធនាំចូល។ នាវាដែលនាំចូលបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមរបបពន្ធគយនាំចូលបណ្តោះអាសន្ន។

**មាត្រា៩ .-**

ក្នុងការចុះបញ្ជីនាវា ម្ចាស់នាវាឬម្ចាស់នាវាភាររវេទកិច្ចត្រូវផ្តល់អាសយដ្ឋានសម្រាប់ទំនាក់ទំនងដែលផ្លូវការមួយមិនអាចខ្វះបាន។ ក្នុងករណីប្តូរអាសយដ្ឋាន ម្ចាស់នាវាឬម្ចាស់នាវាភាររវេទកិច្ចត្រូវជូនដំណឹងពីការប្តូរនេះ និងត្រូវផ្តល់អាសយដ្ឋានថ្មីទៅអង្គភាពមានសមត្ថកិច្ចចុះបញ្ជីនាវា យ៉ាងយូរបំផុតរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានប្តូរ។

**មាត្រា១០ .-**

រាល់ការលក់ទិញ ការដូរ ប្រទានកម្ម ឬមូលហេតុគតិយុត្តផ្សេងទៀតដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិនាវា ត្រូវផ្ទេរកម្មសិទ្ធិនាវានិងប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស។

ក្នុងករណីមិនបានប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវា ម្ចាស់នាវានៅតែទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**មាត្រា១១ .-**

ការប្តូរភិនភាគនាវា ត្រូវប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស។

**មាត្រា១២ .-**

ក្នុងករណីដែលនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស បានបាត់បង់ទាំងស្រុង ឬផ្ទេរកម្មសិទ្ធិទៅក្រៅប្រទេស ឬមិនអាចប្រើបាន ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចត្រូវស្នើសុំលុបចេញពីការចុះបញ្ជីនាវា។

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ត្រូវជាប់កាតព្វកិច្ចបង់អាករផ្សេងៗ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើខកខានបំពេញកាតព្វកិច្ច ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

**មាត្រា១៣ .-**

ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ត្រូវអនុវត្តតាមវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស។ វិញ្ញាបនបត្រចុះបញ្ជីនាវាត្រូវព្យួរឬដកហូត ក្នុងករណីប្រើនាវាខុសពីគោលបំណងដែលបានផ្តល់ឱ្យស្របតាមវិញ្ញាបនបត្រចុះបញ្ជីនាវា។

**មាត្រា១៤ .-**

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើនាវាចរណ៍នៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យមានការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវទទួលបានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

**មាត្រា១៥ .-**

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ដែលមានសមត្ថភាពវិជ្ជាជីវៈត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

**មាត្រា១៦ .-**

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ក៏អាចធ្វើឡើងដោយភ្នាក់ងារឯកជនផងដែរ តាមការប្រគល់ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ប្រសិនបើភ្នាក់ងារនោះមានសមត្ថភាពវិជ្ជាជីវៈត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ។

**មាត្រា១៧ .-**

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឬអ្នកដំណើរ ត្រូវមានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការនាវា។

នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ ត្រូវមានធានារ៉ាប់រងដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៨ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២
## ការគ្រប់គ្រងនាវាសញ្ជាតិខ្មែរ

**មាត្រា១៩ ._**

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចដោយអនុលោមតាមកិច្ចសន្យាជាមួយម្ចាស់នាវា ដែលមាននាវាសមុទ្រ ឬកាន់កាប់នាវាសមុទ្រ ទោះជាបរទេសក្តី អាចស្នើសុំចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដើម្បីទទួលបានសិទ្ធិស្របច្បាប់ធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ។

**មាត្រា២០ ._**

ក្នុងការចុះបញ្ជីនាវាសញ្ជាតិខ្មែរ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ វិញ្ញាបនបត្រសុវត្ថិភាពនាវិកអប្បបរមា វិញ្ញាបនបត្របច្ចេកទេស និងសម្របសម្រួលក្នុងការផ្តល់អាជ្ញាបណ្ណវិទ្យុទាក់ទង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២១ ._**

វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានពីរប្រភេទ៖

- វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរអចិន្ត្រៃយ៍ ដែលមានសុពលភាពអតិបរមា៥(ប្រាំ)ឆ្នាំ
- វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរបណ្តោះអាសន្ន ដែលមានសុពលភាពអតិបរមា៦(ប្រាំមួយ)ខែ។

**មាត្រា២២ ._**

នាវាសមុទ្រដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវមានឈ្មោះដែលសរសេរជាអក្សរឡាតាំងនិង/ឬលេខអារ៉ាប់ ដែលយល់ព្រមពីអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

រាល់ការប្តូរឈ្មោះនាវាសញ្ជាតិខ្មែរ ត្រូវមានការអនុញ្ញាតពីអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

នាវាសញ្ជាតិខ្មែរ មិនត្រូវមានឈ្មោះផ្សេងពីឈ្មោះដែលមាននៅក្នុងវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរឡើយ។

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរមានសិទ្ធិបញ្ឈប់ការប្រើឈ្មោះនាវា ដែលបានផ្តល់ឱ្យជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ក្រោយពីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ច ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ។

ក្នុងករណីម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចមិនផ្តល់ឈ្មោះថ្មីសម្រាប់នាវា ដូចមានចែងនៅក្នុងកថាខណ្ឌទី៤ខាងលើនេះ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានសិទ្ធិបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

**មាត្រា២៣ ._**

[illegible]ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវផ្តល់អាសយដ្ឋានសម្រាប់ទំនាក់ទំនងដែលជាផ្លូវការមួយមិនអាចខ្វះបាន។ ក្នុងករណីប្តូរអាសយដ្ឋាន ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវជូនដំណឹងអំពីការប្តូរនេះ និងត្រូវផ្តល់អាសយដ្ឋានថ្មីទៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ យ៉ាងយូរបំផុតរយៈពេល១៥(ដប់ប្រាំ)ថ្ងៃបន្ទាប់ពីបានប្តូរ។

**មាត្រា២៤ .-**

នាវាសមុទ្រដែលបានចុះបញ្ជីដោយប្រទេសដទៃ អាចចុះបញ្ជីនាវាសញ្ជាតិខ្មែរបាន ក្នុងករណីដូចខាងក្រោម៖

- មានវិញ្ញាបនបត្រដែលបញ្ជាក់ថា នាវានោះបានលុបចេញពីការចុះបញ្ជីនាវានៃប្រទេសនោះ
- មានវិញ្ញាបនបត្រដែលបញ្ជាក់ថា នាវានោះត្រូវលុបចេញពីការចុះបញ្ជីនាវានៃប្រទេសនោះ ក្នុងរយៈពេលកំណត់មួយជាក់លាក់។

**មាត្រា២៥ .-**

ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ មិនតម្រូវឱ្យនាវាមានពន្ធនាំចូលឡើយ។

**មាត្រា២៦ .-**

នាវាសមុទ្រដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬនាវាសញ្ជាតិខ្មែរ ត្រូវមានជានាវ៉ាប់រង។

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ច មានសិទ្ធិសម្រេចជ្រើសរើសយកជានាវ៉ាប់រងសម្រាប់នាវាសមុទ្ររបស់ខ្លួនដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬនាវាសញ្ជាតិខ្មែរ អនុលោមតាមគោលការណ៍អន្តរជាតិ។

**មាត្រា២៧ .-**

ម្ចាស់នាវាដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬបានចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានសិទ្ធិចុះបញ្ជីជានានាវា។

ការជានានាវាដែលកំណត់ក្នុងច្បាប់នេះ មិនតម្រូវឱ្យមានការផ្ទេរ ការកាន់កាប់នាវាទៅឱ្យម្ចាស់បំណុលនោះឡើយ។ ការជានានាវាមានអានុភាព លុះត្រាតែមានការចុះបញ្ជីជានានាវា។ ការចុះបញ្ជីជានានាវាត្រូវធ្វើឡើងនៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

ក្រៅពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រគល់វត្ថុនិងសិទ្ធិកាន់កាប់វត្ថុរបស់ម្ចាស់បំណុលនៃការបញ្ចាំ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីពាក់ព័ន្ធនឹងសិទ្ធិលើការបញ្ចាំ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការជានានាវាដែលមានចែងក្នុងច្បាប់នេះ។

ក្រោយពីបានបំពេញលក្ខខណ្ឌសម្រាប់ការចុះបញ្ជីជានានាវា អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីជានានាវា។

បែបបទនិងនីតិវិធីនៃការចុះបញ្ជីជានានាវា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៨ .-**

ការចុះបញ្ជីជានានាវា ត្រូវមានកាលបរិច្ឆេទច្បាស់លាស់។

ករណីមានការចុះបញ្ជីជានានាវាមានពីរឬច្រើនសម្រាប់នាវាមួយគ្រឿង ការទូទាត់សងទៅម្ចាស់បំណុលនូវចំនួនទឹកប្រាក់ដែលបានមកពីការលក់នាវាដោយការដេញថ្លៃ ត្រូវធ្វើតាមលំដាប់រៀងនៃកាលបរិច្ឆេទដែលបានកត់ត្រាទុក។

**មាត្រា២៩ .-**

រាល់ការលក់ទិញ ការដូរ ប្រទានកម្ម ឬមូលហេតុគតិយុត្តផ្សេងទៀតដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិនាវា ត្រូវមានការផ្ទេរកម្មសិទ្ធិនិងប្តូរវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

ការផ្ទេរកម្មសិទ្ធិនាវា អាចធ្វើបានប្រសិនបើមានការឯកភាពពីម្ចាស់ភាគហ៊ុននៃនាវា ស្របតាមនិទ្ទេសដែលបានកត់ត្រាទុកក្នុងការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ឬការចុះបញ្ជីជានានាវា លើកលែងតែមានការចាត់ចែងផ្សេងពីនេះដោយតុលាការស្របតាមច្បាប់និងនីតិវិធីជាធរមាន។

**មាត្រា៣០ .-**

ការផ្ទេរ ការកែប្រែ ឬការរំលត់សិទ្ធិជាកម្មសិទ្ធិលើនាវា ត្រូវកត់ត្រាទុកក្នុងសំណុំឯកសារចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដែលត្រូវរក្សាទុកនៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

ករណីនាវាបានកាន់កាប់ដោយបុគ្គលពីរឬច្រើន សិទ្ធិជាកម្មសិទ្ធិអវិភាគលើនាវាត្រូវកត់ត្រាក្នុងសំណុំឯកសារចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

**មាត្រា៣១ .-**

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរទុតិយតាឬតតិយតា ក្នុងករណីវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ បានបាត់ រហែក ឬរលុបមិនអាចប្រើតទៅទៀតបាន។

វិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរទុតិយតាឬតតិយតា មានតម្លៃស្មើនឹងវិញ្ញាបនបត្រចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដែលបានផ្តល់លើកដំបូង។

**មាត្រា៣២ .-**

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ មានសិទ្ធិបដិសេធចុះបញ្ជីនាវាសញ្ជាតិខ្មែរ ក្នុងករណីណាមួយដូចខាងក្រោម៖

១- មិនមានឯកសារគ្រប់គ្រាន់ ដូចជាឯកសារម្ចាស់នាវា ឯកសារនាវាជាដើម។

២- មិនបានបំពេញលក្ខខណ្ឌបច្ចេកទេសគ្រប់គ្រាន់ពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងបរិស្ថាន ព្រមទាំងលក្ខខណ្ឌសុខភាពនិងផាសុកភាពនាវិក។

៣- នាវាដែលត្រូវបានហាមឃាត់ចុះបញ្ជី ឬលទ្ធភាពដែលបញ្ជាក់ថា នាវាអាចប្រើក្នុងគោលបំណងខុសច្បាប់ណាមួយ ឬអាចបង្កការខូចខាតដល់ផលប្រយោជន៍ ឬកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៣ .-**

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវបញ្ចប់ការចុះបញ្ជីចំពោះនាវា ក្នុងករណីណាមួយដូចខាងក្រោម៖

១- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចមិនព្រមបង់ប្រាក់ពិន័យលើបទល្មើសដែលនាវារបស់ខ្លួនបានប្រព្រឹត្ត។

២- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចមិនព្រមបង់ថ្លៃចំណុះផ្ទុកចុះបញ្ជីនាវាឬថ្លៃផ្សេងទៀតប្រចាំឆ្នាំរយៈពេលលើសពី៣(បី)ខែ។

៣- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចបានស្នើសុំបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

៤- មានភស្តុតាងបញ្ជាក់ថា នាវាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ។

៥- មានភស្តុតាងបញ្ជាក់ថា នាវាដែលចុះបញ្ជីនោះត្រូវបានបាត់បង់ទាំងស្រុង។

ការបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ តម្រូវឱ្យមានការព្រមព្រៀងពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

មុនពេលនៃការបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានចែងនៅក្នុងចំណុចទី១ ចំណុចទី២ និងចំណុចទី៥នៃកថាខណ្ឌទី១ខាងលើ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចនិងម្ចាស់បំណុល ហើយម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច និង/ឬម្ចាស់

បំណុល ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរមកអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរវិញ ក្នុងរយៈពេលមិនលើស ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានការជូនដំណឹង។ ផុតរយៈពេល៣០(សាមសិប)ថ្ងៃនេះ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ អាចសម្រេចបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរជាស្ថាពរ។

នៅមុនពេលនៃការបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានចែងនៅក្នុងចំណុចទី៣និងចំណុចទី៥ នៃកថាខណ្ឌទី១ខាងលើ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅម្ចាស់ភាគហ៊ុន និងម្ចាស់បំណុល ហើយម្ចាស់ភាគហ៊ុននិងម្ចាស់បំណុល ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរមក អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរវិញ ក្នុងរយៈពេលមិនលើស៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានការជូនដំណឹង។ ផុតរយៈពេល៣០(សាមសិប)ថ្ងៃនេះ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ អាចសម្រេចបញ្ចប់ការចុះបញ្ជីនាវាសញ្ជាតិខ្មែរជាស្ថាពរ។

ការលុបការចុះបញ្ជីនាវាសញ្ជាតិខ្មែរ ដូចមានកំណត់នៅក្នុងចំណុចទី៣នៃកថាខណ្ឌទី១ខាងលើ ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីម្ចាស់ភាគហ៊ុននិងម្ចាស់បំណុល។

ក្រោយបញ្ចប់សព្វគ្រប់នូវលក្ខខណ្ឌសម្រាប់ការលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវផ្តល់វិញ្ញាបនបត្រលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

**មាត្រា៣៤ .-**

នៅពេលដែលនាវាសញ្ជាតិខ្មែរត្រូវបាត់បង់ទាំងស្រុង ការធានានាវាត្រូវរលត់។ ករណីនេះ ការទូទាត់សងទៅម្ចាស់បំណុល ត្រូវធ្វើតាមលក្ខខណ្ឌដូចមានចែងនៅក្នុងកិច្ចសន្យាសាងសង់ ឬកិច្ចសន្យាធានានាវា ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៥ .-**

ករណីមានការអនុវត្តដោយបង្ខំចំពោះនាវាសញ្ជាតិខ្មែរ ដោយតុលាការមានសមត្ថកិច្ច ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីផ្សេងៗនៅក្នុងនីតិវិធីនេះ ត្រូវបញ្ជូនទៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរត្រូវជូនដំណឹងអំពីការរឹបអូសនេះទៅម្ចាស់ភាគហ៊ុននាវា ម្ចាស់បំណុលឯកសិទ្ធិ ម្ចាស់បំណុលដែលមានការធានា ឬដើមបណ្តឹងទាមទារសំណងដែលកើតឡើងក្នុងប្រតិបត្តិការរបស់នាវា។

ក្រោយពីបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវាសញ្ជាតិខ្មែរ អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរជូនម្ចាស់នាវាថ្មី ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សិទ្ធិអាទិភាពក្នុងការទទួលសំណងពីការលក់នាវាសញ្ជាតិខ្មែរដោយបង្ខំ ត្រូវបានកំណត់តាមលំដាប់រៀងដូចខាងក្រោម៖

១- ឯកសិទ្ធិ។

២- ការធានានាវា។

៣- សិទ្ធិលើបំណុលផ្សេងទៀតដែលពាក់ព័ន្ធនឹងនាវា។

**មាត្រា៣៦ .-**

នាវាសមុទ្រដែលត្រូវចុះបញ្ជីនាវាសញ្ជាតិខ្មែរ ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងទទួលបានវិញ្ញាបនបត្របច្ចេកទេសមានសុពលភាព៥(ប្រាំ)ឆ្នាំ ដែលត្រូវមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ជារៀងរាល់ឆ្នាំតាមកម្មវិធីត្រួតពិនិត្យ។

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា រួមមានការត្រួតពិនិត្យតួ ម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខារចាំបាច់ ដើម្បីធានាសុវត្ថិភាព សន្តិសុខ និងបរិស្ថានក្នុងការធ្វើនាវាចរណ៍។

**មាត្រា៣៧ .-**

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាសញ្ជាតិខ្មែរ ត្រូវធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវានៃអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

**មាត្រា៣៨ .-**

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាសញ្ជាតិខ្មែរនិងការផ្តល់វិញ្ញាបនបត្របច្ចេកទេស ក៏អាចធ្វើឡើងដោយអង្គការចំណាត់ថ្នាក់នាវាផងដែរ តាមការប្រគល់ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាសញ្ជាតិខ្មែរ ដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៣៩ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិស្នើសុំរដ្ឋសមាជិកណាមួយនៃអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ ដើម្បីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវានិងផ្តល់វិញ្ញាបនបត្របច្ចេកទេស។

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវានិងផ្តល់វិញ្ញាបនបត្របច្ចេកទេស តាមការស្នើសុំដោយរដ្ឋសមាជិកណាមួយនៃអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ។

**មាត្រា៤០ .-**

បែបបទនិងនីតិវិធីនៃការគ្រប់គ្រងនាវាសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណវិទ្យុទាក់ទង ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី៥

## នាវិក

### ផ្នែកទី១

### ការបណ្តុះបណ្តាលនាវិក

**មាត្រា៤១ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំនិងជំរុញការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលនាវិក។

ការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលនាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤២ .-**

ការបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលនាវិក ត្រូវមានជាអាទិ៍មុខជំនាញ កម្មវិធីសិក្សានិងកម្មសិក្សា កម្រិតសញ្ញាបត្រ ឧបករណ៍ សម្ភារៈ បរិក្ខារ សាស្ត្រាចារ្យឬគ្រូបង្ហាត់។

**មាត្រា៤៣ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវធានាឱ្យមានការវាយតម្លៃលើការបណ្តុះបណ្តាលនាវិក ដើម្បីទទួលបានការទទួលស្គាល់ពីអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ។

**មាត្រា៤៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីទទួលស្គាល់ការបណ្តុះបណ្តាលនាវិក ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤៥ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិអនុញ្ញាតឱ្យផ្នែកឯកជនបង្កើតនិងធ្វើអាជីវកម្មសាលាបង្រៀនបើកបរនាវា សម្រាប់នាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស។

លក្ខខណ្ឌនិងនីតិវិធីនៃការបង្កើតនិងការធ្វើអាជីវកម្មសាលាបង្រៀនបើកបរនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ផ្នែកទី២

## នាវិកបម្រើការងារនៅលើនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស

**មាត្រា៤៦ .-**

នាវិកដែលបម្រើការងារជាបរិបាលនាវា យន្តការីនាវា អ្នកបើកបរនាវា ជំនួយការបរិបាលនាវា និងជំនួយការយន្តការីនាវា ត្រូវមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក។

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក ត្រូវផ្តល់ឱ្យបេក្ខជន ស្របតាមប្រភេទ ទំហំ កម្លាំងម៉ាស៊ីន និងតំបន់ប្រតិបត្តិការរបស់នាវា តាមលក្ខខណ្ឌដូចខាងក្រោម៖

- មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ
- មានលិខិតឬវិញ្ញាបនបត្រពិនិត្យកាយសម្បទាដែលចេញដោយក្រសួងទទួលបន្ទុកវិស័យការងារ
- មានវិញ្ញាបនបត្របញ្ជាក់ការសិក្សានៅក្នុងឬក្រៅប្រទេសនិងមានលិខិតបញ្ជាក់ថា នាវិកបានបម្រើការងារនៅលើនាវា
- មានការប្រឡងឬធ្វើតេស្ត ដែលបញ្ជាក់ថា នាវិកមានសមត្ថភាពជំនាញបំពេញការងារនៅលើនាវាបាន។

**មាត្រា៤៧ .-**

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាបរិបាលនាវា ចែកជា៣(បី)កម្រិត ដូចខាងក្រោម៖

- កម្រិតទី១ : បរិបាលនាវាដែលត្រូវបម្រើការងារនៅលើនាវាមានបណ្តោយចាប់ពី៣៥(សាមសិបប្រាំ)ម៉ែត្រឡើង
- កម្រិតទី២ : បរិបាលនាវាដែលត្រូវបម្រើការងារនៅលើនាវាមានបណ្តោយចាប់ពី២៤(ម្ភៃបួន)ម៉ែត្រ និងតិចជាង៣៥(សាមសិបប្រាំ)ម៉ែត្រ
- កម្រិតទី៣ : បរិបាលនាវាដែលត្រូវបម្រើការងារនៅលើនាវាមានបណ្តោយតិចជាង២៤(ម្ភៃបួន)ម៉ែត្រ។

**មាត្រា៤៨ .-**

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាយន្តការីនាវា ចែកជា៣(បី)កម្រិត ដូចខាងក្រោម៖

- កម្រិតទី១ : យន្តការីនាវាដែលបម្រើការងារនៅលើនាវាមានកម្លាំងម៉ាស៊ីនចាប់ពី៧៥០(ប្រាំពីររយហាសិប)សេះឡើង
- កម្រិតទី២ : យន្តការីនាវាដែលបម្រើការងារនៅលើនាវាមានកម្លាំងម៉ាស៊ីនចាប់ពី២៥០(ពីររយហាសិប)សេះ និងតិចជាង៧៥០(ប្រាំពីររយហាសិប)សេះ
- កម្រិតទី៣ : យន្តការីនាវាដែលបម្រើការងារនៅលើនាវាមានកម្លាំងម៉ាស៊ីនតិចជាង២៥០(ពីររយហាសិប)សេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៩ .-**

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាអ្នកបើកបរនាវា ចែកជា៣(បី)កម្រិត ដូចខាងក្រោម៖

- កម្រិតទី១ : អ្នកបើកបរនាវានៅលើនាវាដែលមានបណ្តោយចាប់ពី១២(ដប់ពីរ)ម៉ែត្រឡើង
- កម្រិតទី២ : អ្នកបើកបរនាវានៅលើនាវាដែលមានបណ្តោយចាប់ពី៧(ប្រាំពីរ)ម៉ែត្រ ដល់តិចជាង១២(ដប់ពីរ)ម៉ែត្រ
- កម្រិតទី៣ : អ្នកបើកបរនាវានៅលើនាវាដែលមានបណ្តោយតិចជាង៧(ប្រាំពីរ)ម៉ែត្រ ដែលជាប្រភេទនាវាគាំទ្រ ឬនាវាផ្សេងទៀតដែលមានដំណើរចរឆ្លងកាត់ប្រឡាយនាវាចរណ៍ ច្រកនាវាចរណ៍ ឬផ្លូវនាវាចរណ៍ដែលមានចរាចរណ៍មមាញឹក។

ការតម្រូវឱ្យមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាអ្នកបើកបរនាវាកម្រិតទី៣ ត្រូវបានលើកលែងចំពោះនាវាដែលប្រើសម្រាប់ដឹកជញ្ជូនជាលក្ខណៈគ្រួសារ។

**មាត្រា៥០ .-**

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាជំនួយការបរិបាលនាវា ត្រូវផ្តល់ឱ្យនាវិកដែលបំពេញមុខងារជានាវិកជំនាញបម្រើការងារផ្នែកបើកបរនិងជាជំនួយការរបស់បរិបាលនាវា។

វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាជំនួយការយន្តការីនាវា ត្រូវផ្តល់ឱ្យនាវិកដែលបំពេញមុខងារជានាវិកជំនាញបម្រើការងារផ្នែកម៉ាស៊ីននិងជាជំនួយការរបស់យន្តការីនាវា។

**មាត្រា៥១ .-**

ប្រសិនបើមានកិច្ចព្រមព្រៀងឬអនុសញ្ញាអន្តរជាតិទទួលស្គាល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាទ្វេភាគីឬពហុភាគីជាមួយព្រះរាជាណាចក្រកម្ពុជា ជនបរទេសដែលស្នាក់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកស្របតាមច្បាប់នៃប្រទេសដែលផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកនោះ អាចបើកបរនាវាបាន។

**មាត្រា៥២ .-**

នាវិកដែលមានសមត្ថភាពជំនាញ ត្រូវបំពេញការងារនៅលើនាវា ស្របតាមមុខងារនិងកម្រិតសមត្ថភាពដែលបានកំណត់នៅលើវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក។

នាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតទាប មិនអនុញ្ញាតឱ្យបំពេញការងារដែលតម្រូវឱ្យមាននាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតខ្ពស់ឡើយ។

នាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតខ្ពស់ អាចបំពេញការងារនៅលើនាវាដែលតម្រូវឱ្យមាននាវិកដែលមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកកម្រិតទាបបាន។

ក្នុងករណីមានគ្រោះអាសន្ននៅលើនាវា ដែលបរិបាលនាវានិងយន្តការីនាវាបាត់បង់សមត្ថភាពបញ្ជានិងធ្វើប្រតិបត្តិការនាវា នាវិកថ្នាក់ក្រោមបន្ទាប់ មានសិទ្ធិបន្តដឹកនាំនិងធ្វើប្រតិបត្តិការនាវា រហូតបញ្ចប់ដំណើរនាវា។

**មាត្រា៥៣ .-**

នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកសម្រាប់នាវិកបម្រើការងារនៅលើនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ផ្នែកទី៣
## នាវិកបម្រើការងារនៅលើនាវាសមុទ្រ

**មាត្រា៥៤ .-**

នាវាសញ្ជាតិខ្មែរនីមួយៗត្រូវមាននាវិកសញ្ជាតិខ្មែរយ៉ាងតិច២០%(ម្ភៃភាគរយ)ដើម្បីបម្រើការងារនៅលើនាវា លើកលែងតែពុំមាននាវិកសញ្ជាតិខ្មែរដែលអាចបំពេញមុខងារនៅលើនាវានោះបាន។

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រ ត្រូវមានមុខងារដូចខាងក្រោម៖

- កម្រិតគ្រប់គ្រង : នាយនាវា នាយបើកបរ នាយយន្តការី នាយយន្តការីទី២
- កម្រិតប្រតិបត្តិការ : នាយបើកបរទី២ នាយបើកបរទី៣ នាយទទួលបន្ទុកបើកបរ នាយវិទ្យុទាក់ទង វិទ្យុការីនាវា នាយយន្តការីទី៣ នាយទទួលបន្ទុកម៉ាស៊ីន នាយអគ្គិសនី
- កម្រិតគាំទ្រ : នាវិកជំនាញផ្នែកបើកបរ នាវិកប្រចាំវេនបើកបរ នាវិកជំនាញផ្នែកម៉ាស៊ីន នាវិកប្រចាំវេនម៉ាស៊ីន នាវិកជំនាញផ្នែកអគ្គិសនី។

នាវិកសញ្ជាតិខ្មែរដែលបំពេញមុខងារ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក។

**មាត្រា៥៥ .-**

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រតាមមុខងារ ដូចមានចែងនៅក្នុងមាត្រា៥៤នៃច្បាប់នេះ ត្រូវមានការបណ្តុះបណ្តាលពិសេស ដើម្បីបំពេញមុខងារនៅលើនាវា។

**មាត្រា៥៦ .-**

នាយនាវាមានសិទ្ធិដឹកនាំ គ្រប់គ្រង និងបញ្ជានៅលើនាវា។

នាវិកបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវអនុវត្តតាមបញ្ជារបស់នាយនាវា និងត្រូវបំពេញមុខងារដែលនាយនាវាបានប្រគល់ឱ្យដោយប្រុងប្រយ័ត្ន។

សិទ្ធិនិងការទទួលខុសត្រូវរបស់នាយនាវានិងនាវិកដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៧ .-**

នាវិកសញ្ជាតិខ្មែរនិងនាវិកបរទេសដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវមានឯកសណ្ឋាននាវិក។

ឯកសណ្ឋាននាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៨ .-**

នាវិកសញ្ជាតិខ្មែរដែលត្រូវបម្រើការងារនៅលើនាវាសមុទ្រ ត្រូវមានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ សុខភាពល្អដោយមានវិញ្ញាបនបត្របញ្ជាក់សុខភាពនាវិក កម្រិតសញ្ញាបត្រសមស្រប ឯកសារបញ្ជាក់អំពីការបម្រើការងាររបស់នាវិកនៅលើនាវា និងការធ្វើតេស្តសមត្ថភាពជំនាញ។

នាវិកសញ្ជាតិខ្មែរដែលកំពុងហាត់ការដើម្បីបម្រើការងារនៅលើនាវា ត្រូវមានអាយុយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ ប្រសិនបើការងារនោះមិនប៉ះពាល់ដល់ភាពលូតលាស់នៃរាងកាយរបស់នាវិក។

**មាត្រា៥៩ .-**

នាវិកបរទេសមានសិទ្ធិបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរបាន ប្រសិនបើមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក[illegible]លេខ។

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំឱ្យមានកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការទទួលស្គាល់សមត្ថភាពជំនាញនាវិក និងការផ្ដល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្ហិលេខដល់នាវិកបរទេសដែលត្រូវបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ។

**មាត្រា៦០ .-**

នីតិវិធីនិងលក្ខខណ្ឌនៃការផ្ដល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្ហិលេខ និងវិញ្ញាបនបត្របញ្ជាក់សុខភាពនាវិក សម្រាប់នាវិកបម្រើការងារនៅលើនាវាសមុទ្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៦១ .-**

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រ ត្រូវមានសៀវភៅនាវិក។ សៀវភៅនាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាសមុទ្រ ក៏ត្រូវមានផងដែរនូវលិខិតឆ្លងដែន។

នាវិកបរទេសដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវមានលិខិតឆ្លងដែននិង/ឬឯកសារដែលមានតម្លៃស្មើ ដែលផ្ដល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់នាវិកនោះ។

**មាត្រា៦២ .-**

នាវាសញ្ជាតិខ្មែរ ត្រូវមានចំនួននាវិកអប្បបរមា ស្របតាមប្រភេទ ទំហំ កម្លាំងម៉ាស៊ីន តំបន់ប្រតិបត្តិការរបស់នាវា និងមុខងារដែលនាវិកត្រូវបំពេញ ដើម្បីធានាសុវត្ថិភាពនាវាចរណ៍។

ចំនួននាវិកអប្បបរមា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៦៣ .-**

នាវិកសញ្ជាតិខ្មែរឬនាវិកបរទេសដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ត្រូវមានកិច្ចសន្យាការងារនាវិក។

កិច្ចសន្យាការងារនាវិក ត្រូវមានចែងជាអាទិ៍អត្តសញ្ញាណរបស់គូភាគី តួនាទីដែលនាវិកត្រូវបម្រើការប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗនិងរបៀបនៃការទូទាត់ ការធានារ៉ាប់រងសុខភាព ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល លក្ខខណ្ឌបញ្ឈប់ការងារ។

កិច្ចសន្យាការងារនាវិក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងត្រូវចុះហត្ថលេខាដោយនាវិកនិងម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ដោយមានចំនួន៣(បី)ច្បាប់ ដែលមួយច្បាប់ត្រូវរក្សាទុកនៅម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច មួយច្បាប់ត្រូវរក្សាទុកនៅនាវិក និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

នាវិកសញ្ជាតិខ្មែរដែលបម្រើការងារនៅលើនាវាបរទេស ត្រូវមានកិច្ចសន្យាការងារនាវិកស្របតាមច្បាប់នៃប្រទេសម្ចាស់សញ្ជាតិនាវានិងលិខិតុបករណ៍អន្តរជាតិ។

**មាត្រា៦៤ .-**

ក្នុងករណីការបញ្ចប់កិច្ចសន្យាការងារនាវិករបស់នាវិកនៅលើនាវាសញ្ជាតិខ្មែរ ដោយផុតសុពលភាពនៃកិច្ចសន្យាការងារនាវិក៖

១- ម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច ត្រូវ៖

- ទូទាត់ប្រាក់ឈ្នួលនាវិកឱ្យបានចប់សព្វគ្រប់ដល់នាវិក
- ផ្ដល់មូលវិចារលើការងាររបស់នាយនាវា ដោយមានបញ្ជាក់អំពីរយៈពេលនិងបទពិសោធបម្រើការងារនៅលើនាវា។

២- នាយនាវាត្រូវផ្ដល់មូលវិចារលើការងាររបស់នាវិក ដោយមានបញ្ជាក់អំពីឋានៈ រយៈពេល និងបទពិសោធបម្រើការងារនៅលើនាវា។

**មាត្រា៦៥ .-**

នាវិកមានសិទ្ធិបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់ ដោយមូលហេតុណាមួយ ដូចខាងក្រោម៖

១- នាវាស្ថិតនៅក្នុងភាពមិនមានសុវត្ថិភាព បន្ទប់ស្នាក់នៅក្នុងនាវាមិនមានផាសុកភាព ហើយនាយនាវានៅតែធ្វេសប្រហែសមិនដោះស្រាយជូន។

២- នាយនាវាធ្វេសប្រហែសក្នុងការពិនិត្យដោះស្រាយ បើទោះបីជាមានចំនួននាវិកតវ៉ារហូតដល់ ៥០%ហើយក៏ដោយ។

៣- នាយនាវាមិនបានយកចិត្តទុកដាក់ដល់នាវិកដែលមានជំងឺ។

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវផ្ដល់ប្រាក់ឈ្នួលនាវិកយ៉ាងច្រើនបំផុតចំនួន៣(បី)ខែ គិតពីថ្ងៃបញ្ចប់កិច្ចសន្យាការងារនាវិក ក្នុងករណីការបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់តាមមូលហេតុណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ។

**មាត្រា៦៦ .-**

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចមានសិទ្ធិបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់ ដោយមូលហេតុណាមួយដែលនាវិកបានប្រព្រឹត្ត ដូចខាងក្រោម៖

១- មិនមានសមត្ថភាពបំពេញមុខងារនៅលើនាវា។

២- មិនគោរពបទបញ្ជាផ្ទៃក្នុងនៅលើនាវា។

៣- ប្រព្រឹត្តខុសដដែលៗនឹងមុខងារដែលខ្លួនត្រូវបំពេញ។

៤- ភូតភរកុហកឬធ្វេសប្រហែសនៅក្នុងការបំពេញមុខងារនៅលើនាវា។

៥- ប្រព្រឹត្តបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ។

៦- ប្រព្រឹត្តបទល្មើសផ្សេងទៀតដែលផ្ទុយនឹងច្បាប់ជាធរមាន។

នាយនាវាមានសិទ្ធិបណ្ដេញនាវិកចេញពីការបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរនៅមុនកាលកំណត់នៃកិច្ចសន្យាការងារនាវិក ក្នុងករណីនាវិកបានប្រព្រឹត្តខុសនូវមូលហេតុណាមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវផ្ដល់ប្រាក់ឈ្នួលនាវិក គិតត្រឹមថ្ងៃដែលបានបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់នោះ។

**មាត្រា៦៧ .-**

នៅពេលដែលនាវាសញ្ជាតិខ្មែរត្រូវបានលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ នាវិកដែលបម្រើការងារនៅលើនាវានោះ ក៏ត្រូវបានបញ្ចប់កិច្ចសន្យាការងារនាវិកផងដែរ។

ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចត្រូវផ្ដល់មូលវិចារលើការងាររបស់នាវិក និងត្រូវផ្ដល់ប្រាក់ឈ្នួលនាវិករយៈពេល២(ពីរ)ខែ គិតចាប់ពីថ្ងៃលុបចេញពីការចុះបញ្ជីនាវាសញ្ជាតិខ្មែរ។

**មាត្រា៦៨ .-**

នៅពេលនាវាសញ្ជាតិខ្មែរបានខូចដោយស្ថិតក្នុងដំណាក់កាលជួសជុល នាវិកត្រូវបានប្រគល់ការងារផ្សេងទៀតស្របតាមមុខជំនាញរបស់ខ្លួន។ ករណីនាវិកមិនទទួលបំពេញការងារនោះ ម្ចាស់នាវាឬម្ចាស់នាវាការវេទកិច្ចអាចបញ្ចប់កិច្ចសន្យាការងារនាវិកបាន។

ម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ចត្រូវផ្ដល់មូលវិចារលើការងាររបស់នាវិកនិងត្រូវផ្ដល់ប្រាក់ឈ្នួលនាវិក គិតត្រឹមថ្ងៃដែលត្រូវបានបញ្ចប់កិច្ចសន្យាការងារនាវិកមុនកាលកំណត់នោះ។

**មាត្រា៦៩ .-**

នាយនាវាត្រូវបញ្ជូននាវិកដែលបានបញ្ចប់កិច្ចសន្យាការងារនាវិកទៅកាន់ប្រទេសរបស់នាវិកវិញ ស្របតាមកិច្ចសន្យាការងារនាវិក។

រាល់ការចំណាយសម្រាប់ការស្នាក់នៅនិងការបរិភោគអាហារ ឬចំណាយដែលចាំបាច់ផ្សេងទៀត ក្នុងកំលុងពេលរង់ចាំការបញ្ជូនត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួន និងការធ្វើដំណើររបស់នាវិកទៅកាន់ប្រទេសរបស់ខ្លួន ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ជាបន្ទុករបស់ម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ច។

**មាត្រា៧០ .-**

នៅពេលនាវាសញ្ជាតិខ្មែរបានបាត់បង់ទាំងស្រុង នាវិកដែលបម្រើការងារនៅលើនាវានោះត្រូវបាន បញ្ចប់នៅមុនពេលកំណត់ ដូចមានចែងនៅក្នុងកិច្ចសន្យាការងារនាវិក។

ម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ចត្រូវផ្ដល់មូលវិចារលើការងារនាវិក និងផ្ដល់ប្រាក់ឈ្នួលនាវិករយៈពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃដែលនាវានោះបានបាត់បង់។

**មាត្រា៧១ .-**

នាវិកមានសិទ្ធិទទួលការទូទាត់លើការចំណាយផ្សេងៗសម្រាប់ប្រតិបត្តិការនាវា ទោះបីជានាវាសញ្ជាតិខ្មែរបានបាត់បង់ទាំងស្រុង និងអត្ថប្រយោជន៍ផ្សេងទៀតក្នុងប្រតិបត្តិការជួយសង្គ្រោះនាវា។

**មាត្រា៧២ .-**

ម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ចត្រូវទទួលខុសត្រូវចំពោះនាវិកដែលបម្រើការងារនៅលើនាវាសញ្ជាតិខ្មែរ ស្ថិតនៅក្រៅប្រទេសរបស់ខ្លួន ក្នុងករណីដូចខាងក្រោម៖

១- នាវិកមានជំងឺត្រូវទទួលបានការព្យាបាលឬការវះកាត់ ដោយមិនអាចពន្យារពេលបាន។

២- នាវិកទទួលមរណភាព អាចត្រូវបានបញ្ជូនសពមកប្រទេសកំណើត ឬធ្វើការបញ្ចុះ ឬបូជានៅក្រៅប្រទេសកំណើត។

**មាត្រា៧៣ .-**

នាវិកដែលកំពុងបម្រើការងារលើនាវាសមុទ្រ ត្រូវទទួលបានប្រាក់ឈ្នួលនាវិក ដោយអនុលោមតាមការព្រមព្រៀង ដូចមានចែងនៅក្នុងកិច្ចសន្យាការងារនាវិក។

ប្រាក់ឈ្នួលនាវិក ត្រូវផ្ដល់ឱ្យនាវិកឱ្យបានទៀងទាត់នៅតាមខែនីមួយៗ។

ប្រាក់ឈ្នួលនាវិក ត្រូវផ្ដល់ឱ្យនាវិក ទោះបីក្នុងកំលុងពេលឈប់សម្រាកប្រចាំឆ្នាំនិងការងារថែមម៉ោង។

**មាត្រា៧៤ .-**

ការងារថែមម៉ោងរបស់នាវិកនៅពេលនាវាកំពុងធ្វើនាវាចរណ៍ មិនត្រូវលើសពី២(ពីរ)ម៉ោងក្នុងមួយថ្ងៃ បន្ថែមលើម៉ោងធ្វើការងារប្រចាំថ្ងៃរបស់នាវិក។

ក្នុងករណីចាំបាច់ ការងារថែមម៉ោងរបស់នាវិក មិនត្រូវលើសពី៦(ប្រាំមួយ)ម៉ោងក្នុងមួយថ្ងៃ បន្ថែមលើម៉ោងធ្វើការងារប្រចាំថ្ងៃរបស់នាវិក។

ម៉ោងធ្វើការសរុបរបស់នាវិកនៅលើនាវា មិនត្រូវលើសពី៧២(ចិតសិបពីរ)ម៉ោងក្នុងមួយសប្ដាហ៍។

ការងារបន្ថែមម៉ោងរបស់នាវិកនៅលើនាវា មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីប្រធានសក្តិ។

**មាត្រា៧៥ .-**

ត្រូវបានបង្កើតគណៈកម្មការសម្របសម្រួលវិវាទការងារនាវិក ដើម្បីសម្របសម្រួលវិវាទការងាររបស់នាវិក។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការសម្របសម្រួលវិវាទការងារនាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៦ .-**

វិវាទការងាររបស់នាវិកដែលបម្រើការងារលើនាវាសញ្ជាតិខ្មែរ អាចសម្របសម្រួលដោយយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ឬដោយតុលាការមានសមត្ថកិច្ច។

**មាត្រា៧៧ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវជំរុញបង្កើតភ្នាក់ងារផ្គត់ផ្គង់នាវិក ដើម្បីជានាស្វែងរកទីផ្សារនាវិក លើកកម្ពស់ការបណ្តុះបណ្តាលនិងពង្រឹងគុណភាពសមត្ថភាពនាវិក ធានាការពារសិទ្ធិនិងផលប្រយោជន៍របស់នាវិក សម្រាប់នាវិកដែលបម្រើការងារនៅលើនាវា។

លក្ខខណ្ឌនិងនីតិវិធីនៃការបង្កើតភ្នាក់ងារផ្គត់ផ្គង់នាវិក ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## នាវាចរណ៍
### ផ្នែកទី១
### បទប្បញ្ញត្តិនាវាចរណ៍
#### កថាភាគទី១
#### បទប្បញ្ញត្តិទូទៅ

**មាត្រា៧៨ .-**

នាវាសញ្ជាតិខ្មែរត្រូវគោរពតាមបទប្បញ្ញត្តិនាវាចរណ៍ដូចមានចែងនៅក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវគោរពបទប្បញ្ញត្តិពាក់ព័ន្ធនឹងនាវាចរណ៍នៃប្រទេសដែលនាវាកំពុងស្ថិតនៅ។

នាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស និងនាវាបរទេស ដែលកំពុងស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមបទប្បញ្ញត្តិនាវាចរណ៍ ដូចមានចែងនៅក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បទប្បញ្ញត្តិនៅក្នុងជំពូកនេះ មិនរាំងដល់ប្រតិបត្តិការតាមវិធានពិសេសដែលអនុវត្តនៅក្នុងដែនទឹកកំពង់ផែ ព្រែកជីក និងផ្លូវទឹកបិទជិតដែលតភ្ជាប់ទៅផ្លូវសមុទ្រឡើយ។

**មាត្រា៧៩ .-**

បទប្បញ្ញត្តិនាវាចរណ៍ រួមមានវិធានបើកបរ ភ្លើងបើកបរ សញ្ញាបើកបរ សញ្ញាភ្លើង និងសញ្ញាសំឡេង។

**មាត្រា៨០ .-**

នាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវា ត្រូវយកចិត្តទុកដាក់ប្រុងប្រយ័ត្នចំពោះគ្រប់ប្រភេទគ្រោះថ្នាក់នាវាចរណ៍ គ្រោះថ្នាក់ប៉ះទង្គិច និងគ្រប់កាលៈទេសៈពិសេស ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌកំណត់ត្រារបស់នាវា ដែលអាចអនុញ្ញាតឱ្យនាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវាមិនចាំបាច់គោរពតាមវិធានបើកបរ ដើម្បីចៀសវាងគ្រោះថ្នាក់ភ្លាមៗ។

នាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវា មិនត្រូវបានឱ្យរួចផុតពីការទទួលខុសត្រូវ ចំពោះផលអវិជ្ជមានដែលកើតឡើងដោយការធ្វេសប្រហែសមិនគោរពតាមវិធានបើកបរ ឬការធ្វេសប្រហែសដែលតម្រូវឱ្យអនុវត្តតាមទម្លាប់របស់នាវិក ឬដោយកាលៈទេសៈពិសេសនៃករណីណាមួយឡើយ។

## កថាភាគទី២
## វិធានបើកបរ

**មាត្រា៨១ .-**

នាវិកត្រូវឃ្លាំមើលផ្លូវជាប់ជានិច្ចនិងឱ្យបានត្រឹមត្រូវដោយការមើលនិងស្តាប់ រួមផ្សំនឹងការប្រើគ្រប់មធ្យោបាយដែលមាន ស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង ដើម្បីវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយនូវស្ថានភាពដំណើរចរណ៍និងហានិភ័យនៃការប៉ះទង្គិច។

**មាត្រា៨២ .-**

នាវានីមួយៗត្រូវធ្វើដំណើរក្នុងល្បឿនសុវត្ថិភាពជានិច្ច ដែលអាចឱ្យនាវាចាត់វិធានការបានត្រឹមត្រូវនិងមានប្រសិទ្ធភាព ដើម្បីបញ្ចៀសការប៉ះទង្គិច និងអាចបញ្ឈប់ចលនានាវាបាននៅក្នុងចម្ងាយមួយសមស្រប ស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង។

**មាត្រា៨៣ .-**

នាវានីមួយៗត្រូវប្រើគ្រប់មធ្យោបាយដែលមានស្របតាមកាលៈទេសៈនិងស្ថានភាពជាក់ស្តែង ដើម្បីកំណត់ហានិភ័យនៃការប៉ះទង្គិចដែលអាចកើតមានឡើង ហើយបើមានការសង្ស័យអំពីហានិភ័យនេះកើតឡើង ត្រូវចាត់ទុកថាវាពិតជាកើតឡើង។

ប្រសិនបើមានបំពាក់រ៉ាដាដែលមានមុខងារប្រតិបត្តិការជាក់លាក់ ត្រូវប្រើឱ្យបានត្រឹមត្រូវ ដោយត្រូវផ្តើមពិនិត្យមើលក្នុងវង់គំហើញឆ្ងាយ ដើម្បីទទួលបានព័ត៌មានព្រមានជាមុនអំពីហានិភ័យនៃការប៉ះទង្គិច និងគណនាប៉ារ៉ាម៉ែត្រចលនារបស់គោលដៅដែលបានសង្កេត។

ព័ត៌មានពុំមានមូលដ្ឋានគ្រប់គ្រាន់ មិនត្រូវសន្មតយកជាបានការ ជាពិសេសព័ត៌មានដែលទទួលបានពីរ៉ាដា។

ក្នុងការកំណត់ហានិភ័យនៃការប៉ះទង្គិចដែលអាចកើតឡើង ត្រូវពិចារណាលើនិទ្ទេសដូចខាងក្រោម៖

- ហានិភ័យនឹងកើតឡើង ប្រសិនបើទិសសង្កេតទៅនាវាដែលខិតមកជិតមិនផ្លាស់ប្តូរ
- ហានិភ័យអាចកើតឡើងបាននៅពេលណាមួយ ទោះបីជាមានការកត់សម្គាល់ឃើញច្បាស់ថាមានការប្រែប្រួលទិសសង្កេត ជាពិសេសនៅពេលធ្វើដំណើរខិតចូលជិតគ្នាជាមួយនាវាមានទំហំធំ ឬនាវាសណ្តោង ឬធ្វើដំណើរកៀកគ្នាខ្លាំងជាមួយនាវាផ្សេងទៀត។

**មាត្រា៨៤ .-**

ចំណាត់ការណាមួយដើម្បីបញ្ចៀសការប៉ះទង្គិច ត្រូវធ្វើឡើងស្របតាមវិធានបើកបរ ហើយប្រសិនបើកាលៈទេសៈអនុញ្ញាត ត្រូវធ្វើដោយការជឿជាក់ ធ្វើក្នុងពេលវេលាគ្រប់គ្រាន់ និងអនុវត្តកិច្ចការសង្កេតដោយផ្ចិតផ្ចង់ក្នុងនាមជាអ្នកដើរសមុទ្រដ៏ល្អ។

ការប្តូរទិសបើកបរនិង/ឬល្បឿនដើម្បីបញ្ចៀសការប៉ះទង្គិច ប្រសិនបើកាលៈទេសៈអនុញ្ញាត ត្រូវធ្វើឱ្យប្រែប្រួលខ្លាំង ដើម្បីឱ្យនាវាផ្សេងទៀតមើលឃើញដោយភ្នែកឬរ៉ាដា ហើយមិនត្រូវប្តូរទិសបើកបរនិង/ឬល្បឿនម្តងម្តងៗច្រើនដងឡើយ។

ប្រសិនបើមានលម្ហគ្រប់គ្រាន់ ការប្តូរទិសបើកបរអាចជាចំណាត់ការតែមួយដែលមានប្រសិទ្ធភាពបំផុត ដើម្បីបញ្ចៀសស្ថានភាពកៀកគ្នាខ្លាំង ហើយត្រូវធ្វើក្នុងពេលវេលាគ្រប់គ្រាន់និងមិនបង្កឱ្យមានស្ថានភាពកៀកគ្នាខ្លាំងផ្សេងទៀត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ចំណាត់ការដែលបានធ្វើឡើងដើម្បីបញ្ចៀសការប៉ះទង្គិចជាមួយនាវាផ្សេងទៀត ត្រូវអនុវត្តកិច្ចការសង្កេតដើម្បីឱ្យនាវាឆ្លងកាត់គ្នាក្នុងចម្ងាយសុវត្ថិភាព ហើយចំណាត់ការដែលប្រកបដោយប្រសិទ្ធភាព ត្រូវពិនិត្យមើលដោយយកចិត្តទុកដាក់រហូតដល់នាវាផ្សេងទៀតត្រូវបានឆ្លងកាត់ផុត។

ប្រសិនបើចាំបាច់ ដើម្បីបញ្ចៀសការប៉ះទង្គិច ឬដើម្បីទុកពេលវេលាបន្ថែមសម្រាប់វាយតម្លៃស្ថានភាព នាវាត្រូវបន្ថយល្បឿន ឬបញ្ឈប់កម្លាំងចលករ ឬត្រូវប្រើកម្លាំងចលករបញ្ច្រាស ដើម្បីទប់កម្លាំងជម្រុលទៅមុខរបស់នាវា។

ក្នុងដំណើរឆ្លងកាត់ នាវាត្រូវគោរពតាមវិធានការដូចខាងក្រោម៖

- នាវាដែលតម្រូវមិនឱ្យបង្អាក់ការធ្វើដំណើរឬដំណើរឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត តាមវិធានណាមួយនៅពេលដែលបានតម្រូវ ត្រូវធ្វើចំណាត់ការឱ្យបានឆាប់ ដើម្បីទុកពេលនិងលម្ហគ្រប់គ្រាន់សម្រាប់ការឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត
- នាវាដែលតម្រូវមិនឱ្យបង្អាក់ការធ្វើដំណើរឬការឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត មិនត្រូវរួចពីកាតព្វកិច្ចនេះឡើយ ប្រសិនបើនាវានេះធ្វើដំណើរខិតទៅជិតនាវាផ្សេងទៀតបង្កគ្រោះថ្នាក់ប៉ះទង្គិច ហើយនៅពេលកំពុងធ្វើចំណាត់ការ ត្រូវយកចិត្តទុកដាក់ឱ្យបានពេញលេញដែលបានតម្រូវដោយវិធានបើកបរ
- នៅពេលនាវាពីរគ្រឿងកំពុងធ្វើដំណើរខិតជិតគ្នា ដែលអាចបង្កគ្រោះថ្នាក់ប៉ះទង្គិច នាវាដែលមានសិទ្ធិឆ្លងកាត់ហើយមិនត្រូវបានបង្អាក់ដំណើររបស់ខ្លួន ត្រូវរក្សាកាតព្វកិច្ចពេញលេញអនុលោមតាមបទប្បញ្ញត្តិនៃវិធានបើកបរ។

**មាត្រា៨៥ .-**

ការធ្វើនាវាចរណ៍នៅតាមប្រឡាយនាវាចរណ៍តូចចង្អៀត៖

១- នាវាដែលធ្វើដំណើរតាមបណ្តោយប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ត្រូវបើកបរអែបគែមស្តាំនៃប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍នោះ តាមដែលអាចធ្វើទៅបាននិងមានសុវត្ថិភាព។

២- នាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រឬនាវាប្រើក្ដោង មិនត្រូវបង្អាក់ដល់ការធ្វើដំណើរប្រកបដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត។

៣- នាវាដែលកំពុងនេសាទ មិនត្រូវបង្អាក់ដល់ការធ្វើដំណើររបស់នាវាផ្សេងទៀតឡើយ។

៤- នាវាមិនត្រូវឆ្លងកាត់ទទឹងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ប្រសិនបើការឆ្លងកាត់នោះបង្អាក់ដល់ការធ្វើដំណើរប្រកបដោយសុវត្ថិភាពរបស់នាវាផ្សេងទៀត។ ក្នុងករណីមានការសង្ស័យអំពីបំណងឆ្លងកាត់ទទឹងរបស់នាវាផ្សេងទៀត នាវាដែលកំពុងធ្វើដំណើរតាមបណ្តោយផ្លូវ អាចបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី៤ មាត្រា១០៦នៃច្បាប់នេះ។

៥- ការជែងនៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍៖

ក- នៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ការជែងអាចប្រព្រឹត្តទៅបានលុះត្រាតែនាវាត្រូវជែងបានយល់ព្រមឱ្យនាវាជែងឆ្លងកាត់ដោយសុវត្ថិភាព ហើយនាវាដែលមានបំណងសុំជែងត្រូវបង្ហាញអំពីបំណងសុំជែងដោយការបន្លឺសញ្ញាសំឡេង ដូចមានចែងនៅក្នុងចំណុចក កថាខណ្ឌទី៣ មាត្រា១០៦នៃច្បាប់នេះ។ នាវាត្រូវជែង បើយល់ព្រមឱ្យជែង ត្រូវឆ្លើយតបវិញដោយការបន្លឺសញ្ញាសំឡេង

ដូចមានចែងនៅក្នុងចំណុចខ កថាខណ្ឌទី៣ មាត្រា១០៦នៃច្បាប់នេះ និងចាត់វិធានការជាជំហានៗដើម្បីឱ្យនាវាដែងឆ្លងកាត់ដោយសុវត្ថិភាព។ ក្នុងករណីមានការសង្ស័យ នាវាត្រូវដែងអាចបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី៤ មាត្រា១០៦នៃច្បាប់នេះ។

៥- បញ្ញត្តិនេះមិនលើកលែងឱ្យនាវាសុំដែង រួចផុតពីកាតព្វកិច្ច ដូចមានចែងនៅក្នុងមាត្រា៨៩នៃច្បាប់នេះឡើយ។

៦- នាវាដែលកំពុងធ្វើដំណើរនៅជិតផ្លូវកោងឬទៅជិតប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍ ជាកន្លែងដែលនាវាផ្សេងទៀតមើលមិនឃើញ ត្រូវបើកបរដោយប្រុងប្រយ័ត្ន និងបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី៥ មាត្រា១០៦នៃច្បាប់នេះ។

៧- នាវាត្រូវចៀសវាងបោះយុថ្កានៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀត លើកលែងតែកាលៈទេសៈអនុញ្ញាត។

**មាត្រា៨៦ .-**

បញ្ញត្តិនៃមាត្រានេះអនុវត្តចំពោះគន្លងបែងចែកចរាចរណ៍ដែលបានអនុម័តដោយអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ ហើយនាវាដែលធ្វើដំណើរឆ្លងកាត់គន្លងបែងចែកចរាចរណ៍នេះ ក៏មិនត្រូវរួចផុតពីកាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិនាវាចរណ៍ផ្សេងទៀតឡើយ។

នាវាដែលប្រើគន្លងបែងចែកចរាចរណ៍ ត្រូវ៖

- ធ្វើដំណើរនៅតាមគន្លងចរាចរណ៍ ស្របតាមទិសដៅរួមនៃលំហូរចរាចរណ៍សម្រាប់គន្លងនោះ
- តាមដែលអាចធ្វើទៅបាន ត្រូវធ្វើដំណើរឱ្យឃ្លាតពីបន្ទាត់បែងចែកចរាចរណ៍ឬតំបន់បែងចែកចរាចរណ៍
- ជាទូទៅ ត្រូវចូលឬចេញគន្លងចរាចរណ៍នៅតាមមាត់ច្រកនៃគន្លង ហើយនៅពេលចូលឬចេញត្រង់ផ្នែកចំហៀង ត្រូវធ្វើឡើងក្នុងមុំតូចជៀបជាមួយនឹងទិសដៅរួមតាមដែលអាចធ្វើបាន។

តាមដែលអាចធ្វើបាន នាវាត្រូវចៀសវាងការឆ្លងកាត់ទទឹងគន្លងបែងចែកចរាចរណ៍ ហើយបើចាំបាច់ត្រូវកាត់ទទឹង ត្រូវឱ្យទិសក្បាលនាវាកាត់ត្រង់ឬស្ទើរត្រង់ជៀបទៅនឹងទិសដៅរួមនៃលំហូរចរាចរណ៍តាមដែលអាចធ្វើបាន។

ក្នុងតំបន់ចរាចរណ៍ជាប់ដីគោក នាវាត្រូវអនុវត្តដូចខាងក្រោម៖

- នាវាមិនត្រូវប្រើតំបន់ចរាចរណ៍ជាប់ដីគោក នៅពេលណាដែលនាវាអាចប្រើគន្លងចរាចរណ៍ប្រកបដោយសុវត្ថិភាព នៅក្នុងគន្លងបែងចែកចរាចរណ៍ដែលស្ថិតនៅជិតនោះ លើកលែងនាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រ នាវាប្រើក្ដោង និងនាវាកំពុងធ្វើនេសាទ ដែលអាចប្រើតំបន់ចរាចរណ៍នោះបាន
- បើទោះជាមានបញ្ញត្តិក្នុងគ្រទី១ខាងលើនេះក៏ដោយ ក៏នាវាអាចប្រើតំបន់ចរាចរណ៍ជាប់ដីគោកបានដែរ នៅពេលនាវាកំពុងធ្វើដំណើរចូលចេញកំពង់ផែ ស្ថានីយសមុទ្រ ស្ថានីយកណ្ដាលឬកន្លែងដែលស្ថិតនៅក្នុងតំបន់ចរាចរណ៍នេះ ឬដើម្បីចៀសវាងគ្រោះថ្នាក់ភ្លាមៗ។

នាវា ក្រៅពីនាវាកាត់ទទឹង ឬនាវាចូលចេញគន្លងចរាចរណ៍ មិនត្រូវចូលតំបន់បែងចែកចរាចរណ៍ ឬឆ្លងបន្ទាត់បែងចែកចរាចរណ៍បានទេ លើកលែងតែករណីដូចខាងក្រោម៖

- ករណីអាសន្ន ដើម្បីបញ្ចៀសគ្រោះថ្នាក់ភ្លាមៗ
- ករណីធ្វើនេសាទនៅក្នុងតំបន់បែងចែកចរាចរណ៍។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

នាវាដែលធ្វើនាវាចរណ៍នៅតំបន់ដែលស្ថិតនៅជិតមាត់ច្រកគន្លងបែងចែកចរាចរណ៍ ត្រូវធ្វើនាវាចរណ៍ដោយប្រុងប្រយ័ត្នជាពិសេស។

តាមដែលអាចធ្វើទៅបាន នាវាត្រូវចៀសវាងបោះយុថ្កានៅក្នុងគន្លងបែងចែកចរាចរណ៍ ឬនៅតំបន់ដែលស្ថិតនៅជិតមាត់ច្រកគន្លងបែងចែកចរាចរណ៍។

នាវាដែលមិនប្រើគន្លងបែងចែកចរាចរណ៍ ត្រូវចៀសឱ្យឆ្ងាយពីគន្លងនេះ តាមដែលអាចធ្វើបាន។

នាវាកំពុងធ្វើនេសាទ មិនត្រូវបង្អាក់ការធ្វើដំណើររបស់នាវាដែលកំពុងប្រើគន្លងចរាចរណ៍នោះទេ។

នាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រឬនាវាប្រើក្ដោង មិនត្រូវបង្អាក់ដល់ការធ្វើដំណើរដោយសុវត្ថិភាពរបស់នាវាប្រើម៉ាស៊ីនដែលកំពុងប្រើគន្លងចរាចរណ៍នោះទេ។

នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ នៅពេលជាប់រវល់ប្រតិបត្តិការរក្សាសុវត្ថិភាពនាវាចរណ៍នៅក្នុងគន្លងបែងចែកចរាចរណ៍ រាយ ទម្លាក់ ថែទាំជួសជុល ឬលើកខ្សែកាបក្រោមទឹកនៅក្នុងគន្លងបែងចែកចរាចរណ៍ ត្រូវបានលើកលែងពីការអនុវត្តតាមបទប្បញ្ញត្តិនៅក្នុងវិធាននេះ។

**មាត្រា៨៧ .-**

លើកលែងតែទីកន្លែងដែលតម្រូវអនុវត្តតាមវិធានផ្សេងដូចមានចែងនៅក្នុងមាត្រា៨៥ មាត្រា៨៦ និងមាត្រា៨៩នៃច្បាប់នេះ នាវាត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោមៈ

១- នាវាប្រើម៉ាស៊ីន ត្រូវចៀសចេញពីនាវាមិនអាចបញ្ជាបាន នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ នាវាកំពុងនេសាទ និងនាវាប្រើក្ដោង។

២- នាវាប្រើក្ដោង ត្រូវចៀសចេញពីនាវាមិនអាចបញ្ជាបាន នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ និងនាវាកំពុងនេសាទ។

៣- នាវាកំពុងនេសាទ ត្រូវចៀសចេញពីនាវាមិនអាចបញ្ជា និងនាវាមានកម្រិតសមត្ថភាពចលនាចរណ៍។

៤- លើកលែងតែកាលៈទេសៈអនុញ្ញាត នាវាគ្រប់ប្រភេទ ក្រៅពីនាវាមិនអាចបញ្ជាបាន និងនាវាមានកម្រិតសមត្ថភាពចលនាចរណ៍ ត្រូវចៀសវាងការបង្អាក់ដល់ការឆ្លងកាត់ដោយសុវត្ថិភាពរបស់នាវាមានដែនកម្រិតជម្រៅស៊ីទឹកដែលបង្ហាញភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងមាត្រា១០១នៃច្បាប់នេះ។ នាវាមានដែនកម្រិតជម្រៅស៊ីទឹក ត្រូវបើកបរដោយការប្រុងប្រយ័ត្នជាពិសេស ដោយមានការយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌពិសេសរបស់ខ្លួន។

៥- យន្តហោះសមុទ្រពេលកំពុងបើកបរលើទឹក ត្រូវរក្សាគម្លាត និងចៀសវាងការបង្អាក់ដល់ការធ្វើនាវាចរណ៍របស់នាវាទាំងអស់។ ទោះយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈមានហានិភ័យប៉ះទង្គិចកើតឡើងយន្តហោះសមុទ្រត្រូវគោរពតាមបញ្ញត្តិនៃជំពូកនេះ។

៦- យានហោះលើទឹកៈ

- នៅពេលហោះឡើង ចុះចត និងហោះនៅជិតផ្ទៃទឹក ត្រូវរក្សាគម្លាត និងចៀសវាងការបង្អាក់ការធ្វើនាវាចរណ៍ពីនាវាទាំងអស់
- នៅពេលធ្វើប្រតិបត្តិការលើផ្ទៃទឹក ត្រូវអនុវត្តតាមបញ្ញត្តិនៃជំពូកនេះដូចនាវាប្រើម៉ាស៊ីនដែរ។

**មាត្រា៨៨ .-**

នៅពេលដែលនាវាប្រើក្ដោងធ្វើដំណើរមកជិតគ្នា ដែលអាចនឹងបង្កការប៉ះទង្គិចនោះ នាវាមួយក្នុងចំណោមនាវាទាំងពីរ ត្រូវចៀសតាមករណីដូចតទៅៈ

១- នៅពេលណាដែលនាវានីមួយៗទទួលរងខ្យល់បក់នៅចំហៀងផ្សេងគ្នា នាវាដែលប៉ះខ្យល់នៅខាងឆ្វេង ត្រូវចៀស។

២- នៅពេលណាដែលនាវាទាំងពីរទទួលរងខ្យល់បក់នៅចំហៀងដូចគ្នា នាវាដែលធ្វើដំណើរនៅលើខ្យល់ ត្រូវចៀសពីផ្លូវនាវាដែលធ្វើដំណើរនៅក្រោមខ្យល់។

៣- ប្រសិនបើនាវាដែលទទួលរងនូវខ្យល់បក់នៅខាងឆ្វេង មើលឃើញនាវាដែលស្ថិតនៅលើខ្យល់ ហើយមិនអាចកំណត់បានពិតប្រាកដអំពីខ្យល់បក់នៅខាងឆ្វេងឬនៅខាងស្តាំរបស់នាវានោះ នាវានោះត្រូវចៀស។

សម្រាប់បទប្បញ្ញត្តិនៅក្នុងមាត្រានេះ ចំហៀងដែលស្ថិតនៅលើខ្យល់ត្រូវបានចាត់ទុកជាចំហៀងដែលស្ថិតនៅប្រឈមនឹងទិសដៅខ្យល់បក់ទៅលើផ្ទាំងក្តោងសំខាន់ ឬសម្រាប់ករណីនាវាបំពាក់ដោយក្តោងត្រង់ ចំហៀងដែលស្ថិតនៅលើខ្យល់ត្រូវបានចាត់ទុកជាចំហៀងដែលមានខ្យល់បក់លើផ្ទាំងក្តោងខ្លាំងជាង។

**មាត្រា៨៩ .-**

នាវាណាមួយកំពុងជែងនាវាមួយទៀត ត្រូវរក្សាចម្ងាយពីនាវាដែលត្រូវជែងនោះ។

នាវាត្រូវចាត់ទុកថាកំពុងជែង នៅពេលដែលនាវានោះបានទៅជិតនាវាមួយទៀត ឋិតនៅក្នុងទិសដៅមានមុំធំជាង២២,៥ដឺក្រេ ចំហៀងខាងក្រោយនៃនាវានោះ។ ក្នុងទីតាំងនេះ នាពេលយប់ នាវាកំពុងជែងអាចមើលឃើញតែភ្លើងកន្សៃ ដោយមិនមើលឃើញភ្លើងចំហៀងណាមួយរបស់នាវាត្រូវជែងឡើយ។

នៅពេលនាវាមានការសង្ស័យអំពីការកំពុងជែងនាវាមួយទៀត នាវាជែងត្រូវចាត់ថាជាករណីជែង និងត្រូវចាត់វិធានការស្របទៅតាមបទប្បញ្ញត្តិនាវាចរណ៍។

ការប្រែប្រួលទិសសង្កេតរវាងនាវាទាំងពីរជាបន្តបន្ទាប់ មិនធ្វើឱ្យនាវាជែងក្លាយជានាវាកាត់ទទឹងឡើយសម្រាប់ន័យនៅក្នុងបទប្បញ្ញត្តិនាវាចរណ៍ ឬធ្វើឱ្យនាវាជែងរួចពីកាតព្វកិច្ចរក្សាគម្លាតពីនាវាត្រូវជែងឡើយ លុះត្រាតែនាវាជែងត្រូវបានឆ្លងផុតពីនាវាដែលត្រូវជែង។

**មាត្រា៩០ .-**

នៅពេលដែលនាវាប្រើម៉ាស៊ីនពីរគ្រឿង មានទិសដៅបើកបរទល់មុខគ្នាឬស្ទើរទល់មុខគ្នា ដែលអាចនឹងបង្កហានិភ័យនៃការប៉ះទង្គិច នាវាទាំងពីរនោះត្រូវងាកទៅខាងស្តាំរៀងៗខ្លួន។

ស្ថានភាពដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ចាត់ទុកថាកើតមាននៅពេលដែលនាវាមួយបានឃើញក្បាលនាវាមួយទៀតចំពីមុខឬស្ទើរចំពីមុខ ហើយនៅពេលយប់បានឃើញភ្លើងដងក្តោងឬភ្លើងចំហៀងទាំងពីររបស់នាវាមួយទៀត។

នៅពេលដែលនាវាមួយស្ថិតនៅក្នុងការសង្ស័យអំពីការចៀសជាមួយនាវាមួយផ្សេងទៀត ត្រូវសន្មតថាការចៀសគ្នានឹងកើតមានឡើង ហើយត្រូវចាត់វិធានការសមស្របដើម្បីចៀស។

**មាត្រា៩១ .-**

នៅពេលនាវាប្រើម៉ាស៊ីនពីរគ្រឿងកំពុងធ្វើដំណើរកាត់មុខគ្នា អាចនឹងបង្កហានិភ័យនៃការប៉ះទង្គិច នាវាដែលឃើញនាវាមួយទៀតស្ថិតនៅចំហៀងខាងស្តាំ ត្រូវចៀសនាវានោះ ហើយត្រូវចៀសវាងការចៀសនៅពីខាងមុខនាវាមួយទៀត លើកលែងតែកាលៈទេសៈអនុញ្ញាត។

**មាត្រា៩២ .-**

ប្រសិនបើអាចធ្វើទៅបាន នាវានីមួយៗដែលត្រូវទុកផ្លូវឱ្យនាវាផ្សេងទៀត ត្រូវចាត់វិធានការជាមុន និងត្រឹមត្រូវដើម្បីទុកផ្លូវឱ្យនាវាផ្សេងទៀត។

**មាត្រា៩៣ .-**

ប្រសិនបើនាវាមួយក្នុងចំណោមនាវាពីរគ្រឿងកំពុងចៀស នាវាត្រូវចៀសត្រូវរក្សាទិសបើកបរនិងល្បឿនដដែល និងត្រូវមានវិធានការចាំបាច់នានាដើម្បីបញ្ចៀសការប៉ះទង្គិច ប្រសិនបើនាវាចៀសនោះមិនបានចាត់វិធានការអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

នៅពេលនាវាពីរគ្រឿងចៀសគ្នា នាវាដែលត្រូវបានចៀស ត្រូវរក្សាទិសបើកបរនិងល្បឿន។ ក្នុងករណីមើលឃើញថានាវាដែលត្រូវចៀស មិនអាចចាត់វិធានការអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ នាវាដែលត្រូវបានចៀស ត្រូវចាត់វិធានការបញ្ចៀសការប៉ះទង្គិចដោយធ្វើចលនាចរណ៍ឱ្យបានឆាប់។

នៅពេលមានមូលហេតុណាមួយ នាវាដែលតម្រូវឱ្យរក្សាទិសបើកបរនិងល្បឿន មើលឃើញនាវារបស់ខ្លួននិងនាវាមួយផ្សេងទៀតស្ថិតនៅកៀកគ្នាខ្លាំង ដែលការប៉ះទង្គិចមិនអាចគេចផុតដោយចំណាត់ការរបស់នាវាមួយទៀតតែឯង នាវានេះត្រូវចៀសដើម្បីបញ្ចៀសការប៉ះទង្គិច។

នាវាប្រើម៉ាស៊ីនដែលចាត់វិធានការក្នុងស្ថានភាពឆ្លងកាត់ទទឹងអនុលោមតាមបញ្ញត្តិក្នុងកថាខណ្ឌទី២នៃមាត្រានេះ ដើម្បីបញ្ចៀសការប៉ះទង្គិចជាមួយនាវាប្រើម៉ាស៊ីនផ្សេងទៀត មិនត្រូវប្តូរទិសបើកបរទៅឆ្វេងដែលមាននាវាមួយទៀតស្ថិតនៅផ្នែកខាងឆ្វេងរបស់ខ្លួន លើកលែងតែកាលៈទេសៈអនុញ្ញាត។

បញ្ញត្តិនេះមិនអនុញ្ញាតឱ្យនាវាចៀស រួចផុតពីកាតព្វកិច្ចនៃការទុកផ្លូវឱ្យនាវាដែលត្រូវចៀស។

**មាត្រា៩៤ .-**

បញ្ញត្តិនៅក្នុងមាត្រានេះអនុវត្តចំពោះនាវាដែលមិនអាចមើលឃើញនាវាផ្សេងទៀតនៅពេលធ្វើនាវាចរណ៍នៅក្នុងតំបន់ឬជិតតំបន់ដែលការមើលឃើញមានកម្រិត។

នាវានីមួយៗត្រូវធ្វើដំណើរដោយល្បឿនសុវត្ថិភាពទៅតាមស្ថានភាពនិងកាលៈទេសៈជាក់ស្តែងនៃកម្រិតមើលឃើញ ហើយនាវាដែលមានបំពាក់ម៉ាស៊ីន ត្រូវត្រៀមជានិច្ចសម្រាប់ការធ្វើចលនាចរណ៍បន្ទាន់។

នៅពេលដែលត្រូវអនុវត្តបទប្បញ្ញត្តិក្នុងកថាភាគទី២ ផ្នែកទី១ នៃជំពូកនេះ នាវានីមួយៗត្រូវមានការប្រុងប្រយ័ត្នចំពោះស្ថានភាពនិងកាលៈទេសៈជាក់ស្តែងនៃកម្រិតមើលឃើញ។

នាវាដែលមើលឃើញនាវាផ្សេងទៀតតាមតែរេដាតែប៉ុណ្ណោះ ត្រូវកំណត់អំពីស្ថានភាពកាន់តែខិតជិតគ្នាខ្លាំង និង/ឬហានិភ័យនៃគ្រោះថ្នាក់ប៉ះទង្គិចកើតឡើង។ ប្រសិនបើស្ថានភាពនេះកើតឡើង នាវានេះត្រូវចាត់វិធានការបញ្ចៀសការប៉ះទង្គិចក្នុងពេលវេលាគ្រប់គ្រាន់ ហើយនៅពេលដែលវិធានការនេះជាការប្តូរទិសបើកបរតាមលទ្ធភាពដែលអាចធ្វើបាន ត្រូវចៀសវាង៖

- ការប្តូរទិសបើកបរទៅឆ្វេង ប្រសិនបើនាវាផ្សេងទៀតស្ថិតនៅចំហៀងមុខមិនមែនជានាវាដែលត្រូវជែង
- ការប្តូរទិសបើកបរទៅចំហៀងដែលមាននាវាស្ថិតនៅចំហៀងចំឬនៅចំហៀងក្រោយ។

លើកលែងករណីត្រូវបានកំណត់ថាហានិភ័យនៃការប៉ះទង្គិចមិនកើតមាន នាវានីមួយៗដែលឮសញ្ញាសំឡេងអ័ព្ទនៃនាវាផ្សេងទៀតនៅចំហៀងខាងមុខ ឬដែលមិនអាចចៀសពីស្ថានភាពខិតជិតខ្លាំងជាមួយនាវាផ្សេងទៀតដែលស្ថិតនៅចំហៀងខាងមុខរបស់ខ្លួន នាវានោះត្រូវបន្ថយល្បឿនដល់អប្បបរមាដែលអាចឱ្យនាវានោះរក្សាទិសបើកបរបាន។ ប្រសិនបើចាំបាច់ នាវានោះត្រូវបញ្ឈប់ចលនា ហើយនៅក្នុងករណីខ្លះត្រូវបើកបរដោយប្រុងប្រយ័ត្នខ្ពស់រហូតដល់គ្រោះថ្នាក់នៃការប៉ះទង្គិចត្រូវបានឆ្លងផុត។

## កថាភាគទី៣
## ភ្លើងបើកបរនិងសញ្ញាបើកបរ

**មាត្រា៩៥ .-**

បទប្បញ្ញត្តិភ្លើងបើកបរនិងសញ្ញាបើកបរ ត្រូវអនុវត្តនៅគ្រប់ស្ថានភាពអាកាសធាតុ។

ភ្លើងបើកបរដែលប្រើក្នុងវិធានពាក់ព័ន្ធ ត្រូវអនុវត្តចាប់ពីពេលថ្ងៃលិចរហូតដល់ថ្ងៃរះ ហើយនៅក្នុងពេលនេះមិនត្រូវប្រើភ្លើងផ្សេងទៀតឡើយ លើកលែងតែភ្លើងដែលមិនអាចឱ្យមានការភាន់ច្រឡំនឹងភ្លើងដូចមានចែងនៅក្នុងបទប្បញ្ញត្តិនេះ ឬមិនធ្វើឱ្យបាត់បង់គំហើញ ឬបច្ចេកលក្ខណៈដែលខុសគ្នា ឬរំខានការសង្កេតមើលបានត្រឹមត្រូវ។

ភ្លើងបើកបរដូចមានចែងនៅក្នុងបទប្បញ្ញត្តិនេះ ក៏ត្រូវបានប្រើផងដែរពីថ្ងៃរះដល់ថ្ងៃលិច នៅពេលការមើលឃើញមានកម្រិត និងត្រូវប្រើនៅក្នុងកាលៈទេសៈផ្សេងទៀតនៅពេលដែលចាត់ទុកថាចាំបាច់។

សញ្ញាបើកបរដែលប្រើក្នុងវិធានពាក់ព័ន្ធ ត្រូវបានអនុវត្តនៅពេលថ្ងៃ។

**មាត្រា៩៦ .-**

នាវាប្រើម៉ាស៊ីន ដែលកំពុងធ្វើដំណើរ ត្រូវបើកភ្លើងបើកបរដូចខាងក្រោម៖

- ភ្លើងដងក្ដោងមុខ
- ភ្លើងដងក្ដោងទី២ ដែលស្ថិតនៅខ្ពស់ជាងភ្លើងដងក្ដោងមុខ លើកលែងតែនាវាដែលមានប្រវែងខ្លីជាង៥០(ហាសិប)ម៉ែត្រ
- ភ្លើងចំហៀង
- ភ្លើងកន្សៃ។

នាវាប្រើកម្លាំងចលករដោយកង្ហារ នៅពេលធ្វើប្រតិបត្តិការបាតនាវារត់ប៉ប្រះទឹក ត្រូវបើកភ្លើងបីរយហុកសិបដឺក្រេភ្លឹបភ្លែតពណ៌លឿង បន្ថែមពីលើភ្លើងដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

យានហោះលើផ្ទៃទឹក នៅពេលហោះឡើង ចុះចត ឬហោះជិតផ្ទៃទឹក ត្រូវបើកភ្លើងបីរយហុកសិបដឺក្រេភ្លឹបភ្លែតពណ៌ក្រហម ដែលមានអាំងតង់ស៊ីតេខ្ពស់ បន្ថែមពីលើភ្លើងដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

នាវាប្រើម៉ាស៊ីនមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ អាចបើកភ្លើងបីរយហុកសិបដឺក្រេពណ៌ស និងភ្លើងចំហៀងជំនួសបាន។

នាវាប្រើម៉ាស៊ីនមានប្រវែងខ្លីជាង៧(ប្រាំពីរ)ម៉ែត្រ និងល្បឿនអតិបរមា៧(ប្រាំពីរ)ណត អាចបើកភ្លើងបីរយហុកសិបដឺក្រេពណ៌សជំនួសបាន ហើយបើចាំបាច់ក៏អាចបើកភ្លើងចំហៀងបន្ថែមទៀតបានដែរ។

នាវាប្រើម៉ាស៊ីនមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ មានទទឹងមិនគ្រប់គ្រាន់សម្រាប់ដាក់ភ្លើងចំហៀងដាច់ដោយឡែកពីគ្នា អាចដាក់ភ្លើងចំហៀងនៅលើទីតាំងតែមួយនៅអ័ក្សបណ្ដោយផ្នែកខាងមុខឬ ផ្នែកខាងក្រោយនាវាបាន។

**មាត្រា៩៧ .-**

នាវាប្រើម៉ាស៊ីន ដែលកំពុងសណ្ដោង ត្រូវបើកភ្លើងបើកបរ ឬសញ្ញាបើកបរ ដូចខាងក្រោម៖

- ជំនួសភ្លើងក្ដោងមុខឬភ្លើងដងក្ដោងទី២ ដោយភ្លើងដងក្ដោងពីរស្ថិតលើបន្ទាត់ឈរ ហើយប្រសិនបើប្រវែងសណ្ដោងដែលវាស់ពីកន្សៃនាវាសណ្ដោង ទៅដល់ផ្នែកក្រោយបំផុតនៃនាវាត្រូវសណ្ដោងលើសពី២០០(ពីររយ)ម៉ែត្រ ត្រូវប្រើភ្លើងដងក្ដោង៣ស្ថិតលើបន្ទាត់ឈរតែមួយ

- ភ្លើងចំហៀង
- ភ្លើងកន្សៃ
- ភ្លើងសណ្តោងដាក់លើបន្ទាត់ឈរតែមួយនៅលើភ្លើងកន្សៃ
- នៅពេលតួសណ្តោងមានប្រវែងលើសពី២០០(ពីររយ)ម៉ែត្រ ត្រូវដាក់កោនមានបាតទល់គ្នា ដែលអាចមើលឃើញច្បាស់បាន។

នៅពេលនាវារុញនិងនាវាត្រូវរុញ បានតភ្ជាប់គ្នាជាអង្គតែមួយ ត្រូវចាត់ទុកថា ជានាវាប្រើម៉ាស៊ីនតែមួយ និងត្រូវបើកភ្លើងបើកបរ ដូចមានចែងនៅក្នុងមាត្រា៩៦ខាងលើនេះ។

នាវាប្រើម៉ាស៊ីន ដែលកំពុងរុញឬសណ្តោងចំហៀង ដែលមិនមែនជាអង្គតែមួយ ត្រូវប្រើភ្លើងបើកបរ ដូចខាងក្រោម៖

- ជំនួសភ្លើងក្តោងមុខឬភ្លើងដងក្តោងទី២ ដោយភ្លើងដងក្តោងចំនួនពីរស្ថិតលើបន្ទាត់ឈរតែមួយ
- ភ្លើងចំហៀង
- ភ្លើងកន្សៃ។

ត្រទី២ កថាខណ្ឌទី១ មាត្រា៩៦នៃច្បាប់នេះ ក៏ត្រូវយកមកអនុវត្តផងដែរ ចំពោះនាវាប្រើម៉ាស៊ីន ដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះ។

នាវាឬវត្ថុត្រូវសណ្តោង ក្រៅពីនាវាដូចមានចែងនៅក្នុងកថាខណ្ឌទី៧នៃមាត្រានេះ ត្រូវប្រើភ្លើងបើកបរ ដូចខាងក្រោម៖

- ភ្លើងចំហៀង
- ភ្លើងកន្សៃ
- កោនមានបាតទល់គ្នា ដែលអាចមើលឃើញច្បាស់ ប្រសិនបើប្រវែងសណ្តោងលើសពី២០០ (ពីររយ)ម៉ែត្រ។

ក្នុងករណីនាវាត្រូវសណ្តោងចំហៀងឬរុញស្ថិតនៅជាក្រុមតែមួយ ត្រូវប្រើភ្លើងដូចគ្នានឹងនាវាតែមួយ៖

- នាវាត្រូវរុញដែលស្ថិតនៅមុខបំផុត ហើយមិនមែនជាផ្នែកនៃអង្គតែមួយ ត្រូវដាក់ភ្លើងចំហៀង នៅផ្នែកខាងមុខរបស់នាវា
- នាវាត្រូវសណ្តោងចំហៀង ត្រូវដាក់ភ្លើងកន្សៃ និងភ្លើងចំហៀងនៅផ្នែកខាងមុខរបស់នាវា។

ផ្នែកខ្លះនៃនាវាឬវត្ថុដែលលិចទឹក ឬគ្រឿងតភ្ជាប់នាវា ឬវត្ថុត្រូវសណ្តោងដែលមិនអាចមើលឃើញ ត្រូវដាក់បង្ហាញ៖

- ប្រសិនបើប្រវែងសណ្តោងមានទទឹងខ្លីជាង២៥(ម្ភៃប្រាំ)ម៉ែត្រ ដាក់នូវភ្លើងបីរយហុកសិបដឺក្រេមួយពណ៌ស នៅលើឬជិតផ្នែកខាងមុខ និងមួយទៀតនៅលើឬជិតផ្នែកខាងក្រោយនៃវត្ថុត្រូវសណ្តោង លើកលែងតែដ្រាខុន មិនចាំបាច់ដាក់ភ្លើងនៅលើឬជិតផ្នែកខាងមុខនៃដ្រាខុននោះឡើយ
- ប្រសិនបើប្រវែងសណ្តោងមានទទឹង២៥(ម្ភៃប្រាំ)ម៉ែត្រឬវែងជាង ដាក់នូវភ្លើងបីរយហុកសិបដឺក្រេពីរពណ៌សបន្ថែមទៀតនៅលើឬជិតគែមសងខាងនាវា
- ប្រសិនបើប្រវែងសណ្តោងមានលើសពី១០០(មួយរយ)ម៉ែត្រ ដាក់នូវភ្លើងបីរយហុកសិបដឺក្រេពណ៌សបន្ថែម នៅចន្លោះភ្លើងដែលបានដាក់ដូចក្នុងត្រទី១និងទី២ខាងលើនេះ ធ្វើយ៉ាងណាឱ្យចម្ងាយរវាងភ្លើងទាំងនោះមិនលើសពី១០០(មួយរយ)ម៉ែត្រ

- កោនមានបាតទល់គ្នានៅលើឬជិតទីតាំងក្រោយបំផុតនៃនាវា ឬវត្ថុត្រូវសណ្តោងចុងក្រោយបំផុត ហើយប្រសិនបើប្រវែងសណ្តោងលើសពី២០០(ពីររយ)ម៉ែត្រ ត្រូវប្រើកោនមានបាតទល់គ្នាបន្ថែមទៀត ដែលអាចមើលឃើញច្បាស់បាន។

ក្នុងករណីមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា នាវាឬវត្ថុត្រូវសណ្តោងមិនអាចប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងកថាខណ្ឌទី៥និងកថាខណ្ឌទី៧នៃមាត្រានេះ ត្រូវចាត់វិធានការដែលអាចធ្វើបានដើម្បីបំពាក់ភ្លើងឱ្យនាវាឬវត្ថុត្រូវសណ្តោង ឬដើម្បីបង្ហាញអំពីវត្តមាននៃនាវាឬវត្ថុត្រូវសណ្តោង។

ប្រសិនបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា នាវាដែលជាធម្មតាមិនធ្វើប្រតិបត្តិការសណ្តោងមិនអាចដាក់បង្ហាញភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះបាន នាវានោះនឹងមិនតម្រូវឱ្យដាក់ភ្លើងនោះឡើយ នៅពេលដែលសណ្តោងនាវាផ្សេងទៀតក្នុងគ្រាអាសន្ន ឬត្រូវការជំនួយពីនាវាផ្សេងទៀត។ ករណីនេះ នាវាសណ្តោងនិងនាវាត្រូវសណ្តោង ត្រូវចាត់វិធានការដើម្បីបង្ហាញអំពីចរិតទំនាក់ទំនងរវាងគ្នា អនុលោមតាមបញ្ញត្តិមាត្រា១០៨នៃច្បាប់នេះ ជាពិសេសត្រូវបំភ្លឺឱ្យឃើញច្បាស់នូវខ្សែសណ្តោង។

**មាត្រា៩៨ .-**

នាវាកំពុងធ្វើដំណើរដោយប្រើក្តោង ត្រូវប្រើភ្លើងបើកបរដូចខាងក្រោម៖

- ភ្លើងចំហៀង
- ភ្លើងកន្ទៃ។

នាវាប្រើក្តោងមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រ ភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវដាក់បញ្ចូលគ្នាក្នុងគោមតែមួយ នៅលើឬជិតកំពូលដងក្តោង។

នាវាប្រើក្តោងកំពុងធ្វើដំណើរ អាចបន្ថែមលើភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ នូវភ្លើងបីរយហុកសិបដឺក្រេពីរនៅលើបន្ទាត់ឈរតែមួយ ខាងលើពណ៌ក្រហម ខាងក្រោមពណ៌បៃតងស្ថិតនៅលើឬជិតកំពូលដងក្តោងដែលអាចមើលឃើញច្បាស់។ ភ្លើងទាំងពីរនេះមិនត្រូវដាក់នៅជាប់នឹងភ្លើងបើកបរដែលបានដាក់ក្នុងគោមតែមួយនោះឡើយ។

នាវាប្រើក្តោងមានប្រវែងខ្លីជាង៧(ប្រាំពីរ)ម៉ែត្រ ប្រសិនបើអាចធ្វើបាន ត្រូវប្រើភ្លើងបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១និងទី២នៃមាត្រានេះ ហើយក្នុងករណីមិនអាចធ្វើបាន ត្រូវត្រៀមពិលឬភ្លើងគោមពណ៌ស ដែលអាចបំភ្លឺបានក្នុងរយៈពេលគ្រប់គ្រាន់ ដើម្បីបង្ការការប៉ះទង្គិច។ ទូកអុំនិងទូកចែវ ប្រសិនបើអាចធ្វើបាន ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ ហើយក្នុងករណីមិនអាចធ្វើបាន ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

នាវាដែលកំពុងធ្វើដំណើរដោយក្តោង ហើយក៏បានប្រើម៉ាស៊ីនចលករផងដែរ ត្រូវប្រើកោនកំពូលចុះក្រោមស្ថិតនៅខាងមុខក្តោងដែលអាចមើលឃើញច្បាស់។

**មាត្រា៩៩ .-**

នាវាកំពុងធ្វើនេសាទ ទោះជាកំពុងធ្វើដំណើរឬបោះយុថ្កា ត្រូវប្រើភ្លើងបើកបរនិងសញ្ញាបើកបរដូចមានចែងនៅក្នុងមាត្រានេះ។

នាវាកំពុងអូសអួន ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីរនៅលើបន្ទាត់ឈរតែមួយ ខាងលើពណ៌បៃតង ខាងក្រោមពណ៌ស ឬសញ្ញាបើកបរ ដែលផ្គុំឡើងដោយកោនពីរស្ថិតលើបន្ទាត់ឈរតែមួយមានកំពូលទល់គ្នា

- ភ្លើងដងក្ដោងក្រោយ ត្រូវស្ថិតនៅខ្ពស់ជាងភ្លើងបីរយហុកសិបដឺក្រេពណ៌បៃតង ហើយប្រសិនបើនាវាមានប្រវែងខ្លីជាង៥០(ហាសិប)ម៉ែត្រ មិនតម្រូវឱ្យប្រើភ្លើងដងក្ដោងទេ
- នៅពេលនាវានៅមានចលនាលើផ្ទៃទឹក ត្រូវប្រើភ្លើងចំហៀង និងភ្លើងកន្សៀបន្ថែមទៀត។

នាវាកំពុងធ្វើនេសាទ ក្រៅពីអូសអួន ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីរនៅលើបន្ទាត់ឈរតែមួយ ខាងលើពណ៌ក្រហម ខាងក្រោមពណ៌ស ឬសញ្ញាបើកបរ ដែលផ្គុំឡើងដោយកោនពីរស្ថិតលើបន្ទាត់ឈរតែមួយមានកំពូលទល់គ្នា
- នៅពេលបន្លាយឧបករណ៍នេសាទមានចម្ងាយវែងជាង១៥០(មួយរយហាសិប)ម៉ែត្រពីនាវា ត្រូវប្រើភ្លើងបីរយហុកសិបដឺក្រេពណ៌ស ឬកោនកំពូលឡើងលើ ស្ថិតក្នុងទិសដៅឆ្ពោះទៅឧបករណ៍នេសាទ
- នៅពេលនាវានៅមានចលនាលើផ្ទៃទឹក ត្រូវប្រើភ្លើងចំហៀងនិងភ្លើងកន្សៀបន្ថែមទៀត។

នាវាកំពុងធ្វើនេសាទ ស្ថិតនៅជិតគ្នានឹងនាវាកំពុងធ្វើនេសាទផ្សេងទៀត ត្រូវប្រើសញ្ញាភ្លើងបន្ថែមដូចខាងក្រោម៖

- នាវាមានប្រវែង២០(ម្ភៃ)ម៉ែត្រឡើង នៅពេលទម្លាក់អួនអូស ត្រូវប្រើភ្លើងពណ៌សពីរស្ថិតលើបន្ទាត់ឈរតែមួយ នៅពេលទាញអួនឡើង ត្រូវប្រើភ្លើងពីរ ពណ៌សខាងលើ ក្រហមខាងក្រោម ស្ថិតលើបន្ទាត់ឈរតែមួយ ហើយនៅពេលអួនទាក់នឹងឧបសគ្គ ត្រូវប្រើភ្លើងពណ៌ក្រហមពីរស្ថិតលើបន្ទាត់ឈរតែមួយ
- នាវាមានប្រវែង២០(ម្ភៃ)ម៉ែត្រឡើង កំពុងធ្វើនេសាទដោយប្រើអួនអូសជាគូ នៅពេលយប់ ត្រូវប្រើភ្លើងហ្វារដោយតម្រង់ទិសដៅទៅមុខនិងទៅនាវាជាគូអូស ហើយនៅពេលទម្លាក់ឬទាញអួនឡើងឬនៅពេលអួនទាក់នឹងឧបសគ្គ ត្រូវប្រើភ្លើងដូចក្នុងត្រេទី១ កថាខណ្ឌនេះ
- នាវាមានប្រវែងខ្លីជាង២០(ម្ភៃ)ម៉ែត្រ កំពុងធ្វើនេសាទដោយប្រើអួនអូសជាគូ អាចប្រើភ្លើងប្រហាក់ប្រហែលដូចក្នុងត្រេទី១និងទី២ខាងលើនេះ
- នាវាកំពុងធ្វើនេសាទដោយប្រើអួនហ៊ុម អាចប្រើភ្លើងពណ៌លឿងពីរស្ថិតលើបន្ទាត់ឈរតែមួយ ភ្លើងទាំងពីរនេះត្រូវបញ្ចេញពន្លឺភ្លែតៗឆ្លាស់គ្នារៀងរាល់វិនាទី ដោយមានរយៈពេលភ្លឺនិងងងឹតស្មើគ្នា ហើយភ្លើងនេះអាចប្រើតែក្នុងពេលដែលនាវាមានឧបសគ្គក្នុងដំណើរអូសអួន។

នាវានេសាទដែលមិនកំពុងធ្វើនេសាទ មិនត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងមាត្រានេះទេ ដោយត្រូវប្រើភ្លើងបើកបរនិងសញ្ញាបើកបរស្របតាមប្រវែងរបស់នាវា។

**មាត្រា១០០ .-**

នាវាមិនអាចបញ្ជាបាន ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីរ ពណ៌ក្រហម នៅលើបន្ទាត់ឈរតែមួយ ដែលអាចមើលឃើញច្បាស់
- ស្វ៊ែឬសញ្ញាបើកបរស្រដៀងគ្នាពីរ នៅលើបន្ទាត់ឈរតែមួយ ដែលអាចមើលឃើញច្បាស់
- នៅពេលនាវានៅមានចលនាលើផ្ទៃទឹក ត្រូវប្រើភ្លើងចំហៀងនិងភ្លើងកន្សៀបន្ថែមទៀត។

លើកលែងនាវាកំពុងប្រតិបត្តិការដោះសម្អាតមីន នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេបីនៅលើបន្ទាត់ឈរតែមួយដែលអាចមើលឃើញច្បាស់ ខាងលើនិងខាងក្រោមពណ៌ក្រហម និងកណ្ដាលពណ៌ស

- សញ្ញាបើកបរបីនៅលើបន្ទាត់ឈរតែមួយដែលអាចមើលឃើញច្បាស់ ខាងលើនិងខាងក្រោមជាស្វ៊ែ និងកណ្ដាលជាកោនមានបាតទល់គ្នា
- នៅពេលនាវានៅមានចលនាលើផ្ទៃទឹក ត្រូវប្រើភ្លើងដងក្ដោង ភ្លើងចំហៀង និងភ្លើងកន្សៃបន្ថែមទៀត
- នៅពេលបោះយុថ្កា ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចមានចែងនៅក្នុងត្រែទី១និងទី២ និងភ្លើងឬសញ្ញាបើកបរដូចមានចែងនៅក្នុងមាត្រា១០៣នៃច្បាប់នេះបន្ថែមទៀត។

នាវាប្រើម៉ាស៊ីនកំពុងប្រតិបត្តិការសណ្ដោង ដែលនាវាសណ្ដោងនិងនាវាត្រូវសណ្ដោង មិនអាចងាកចេញខ្លាំងពីទិសបើកបរ បន្ថែមលើភ្លើងបើកបរឬសញ្ញាបើកបរដូចមានចែងនៅក្នុងកថាខណ្ឌទី១មាត្រា៩៧នៃច្បាប់នេះ ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងត្រែទី១និងត្រែទី២ កថាខណ្ឌទី២នៃមាត្រានេះ។

នាវាកំពុងប្រតិបត្តិការបូមដីឬប្រតិបត្តិការនៅក្រោមទឹក នៅពេលមានកម្រិតសមត្ថភាពចលនាចរណ៍ត្រូវប្រើភ្លើងបើកបរនិងសញ្ញាបើកបរដូចមានចែងនៅក្នុងត្រែទី១ ត្រែទី២ និងត្រែទី៣ កថាខណ្ឌទី២ខាងលើនេះ ហើយនៅពេលមានឧបសគ្គ ត្រូវបន្ថែមភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីពណ៌ក្រហមឬស្វ៊ែពីរ នៅលើបន្ទាត់ឈរតែមួយ ដើម្បីបង្ហាញចំហៀងនាវាដែលមានឧបសគ្គ
- ភ្លើងបីរយហុកសិបដឺក្រេពីពណ៌បៃតងឬកោនមានបាតទល់គ្នាពីរ នៅលើបន្ទាត់ឈរតែមួយ ដើម្បីបង្ហាញចំហៀងនាវាដែលនាវាផ្សេងទៀតអាចឆ្លងកាត់
- នៅពេលបោះយុថ្កា ភ្លើងបើកបរឬសញ្ញាបើកបរដូចមានចែងនៅក្នុងកថាខណ្ឌនេះ ត្រូវជំនួសដោយភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងមាត្រា១០៣នៃច្បាប់នេះ។

នៅពេលដែលមានប្រតិបត្តិការអ្នកមុជទឹកជុំវិញបាតនាវា ហើយមិនអាចប្រើភ្លើងនិងសញ្ញាបើកបរទាំងអស់ដូចមានចែងនៅក្នុងកថាខណ្ឌទី៤ខាងលើនេះ នាវាត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេបីនៅលើបន្ទាត់ឈរតែមួយដែលអាចមើលឃើញច្បាស់ ខាងលើនិងខាងក្រោមពណ៌ក្រហម និងកណ្ដាលពណ៌ស
- ទង់សញ្ញាអន្តរជាតិដែលមានកូដអក្សរ«A» ដាក់លើដងទង់មានកម្ពស់មិនតិចជាង១(មួយ) ម៉ែត្រពីជាន់នាវា និងត្រូវបានមើលឃើញជុំវិញ។

នាវាកំពុងប្រតិបត្តិការដោះសម្អាតមីន ត្រូវបន្ថែមលើភ្លើងបើកបរសម្រាប់នាវាប្រើម៉ាស៊ីនដូចមានចែងនៅក្នុងមាត្រា៩៦នៃច្បាប់នេះ ឬបន្ថែមលើភ្លើងបើកបរឬសញ្ញាបើកបរដូចមានចែងសម្រាប់នាវាបោះយុថ្កានៅក្នុងមាត្រា១០៣នៃច្បាប់នេះ នូវភ្លើងបីរយហុកសិបដឺក្រេបីពណ៌បៃតងឬស្វ៊ែបី។ ភ្លើងបើកបរឬសញ្ញាបើកបរមួយក្នុងចំណោមបី ត្រូវដាក់នៅជិតកំពូលដងក្ដោងមុខ ភ្លើងបើកបរឬសញ្ញាបើកបរនីមួយៗក្នុងចំណោមភ្លើងឬសញ្ញាបើកបរពីរទៀត ត្រូវដាក់នៅចំហៀងសងខាងនាវាផ្នែកខាងមុខ។ ភ្លើងបើកបរឬសញ្ញាបើកបរទាំងនេះបង្ហាញថា មានគ្រោះថ្នាក់សម្រាប់នាវាផ្សេងទៀត ដែលចូលមកជិតក្នុងចម្ងាយ១០០០(មួយពាន់) ម៉ែត្រពីនាវាដោះសម្អាតមីន។

នៅពេលកំពុងប្រតិបត្តិការអ្នកមុជទឹកជុំវិញបាតនាវា នាវាមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ មិនតម្រូវឱ្យប្រើភ្លើងបើកបរនិងសញ្ញាបើកបរ ដូចមានចែងនៅក្នុងមាត្រានេះឡើយ។

**មាត្រា១០១ .-**

នាវាមានដែនកម្រិតជម្រៅស៊ីទឹក ត្រូវប្រើភ្លើងបីរយហុកសិបដឺក្រេបីពណ៌ក្រហមនៅលើបន្ទាត់ឈរតែមួយ ឬស៊ីឡាំងដែលអាចមើលឃើញច្បាស់បន្ថែមលើភ្លើងបើកបរដូចមានចែងនៅក្នុងមាត្រា៩៦នៃច្បាប់នេះ។

**មាត្រា១០២ .-**

នាវាកំពុងបំពេញកណ្ដជារកិច្ច ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីរនៅលើបន្ទាត់ឈរតែមួយ ខាងលើពណ៌ស និងខាងក្រោមពណ៌ក្រហម ដែលស្ថិតនៅលើឬជិតកំពូលដងក្ដោង
- ភ្លើងចំហៀងនិងភ្លើងកន្សៃបន្ថែមទៀត នៅពេលធ្វើដំណើរ
- ភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងមាត្រា១០៣នៃច្បាប់នេះ បន្ថែមលើភ្លើងបើកបរដូចមានចែងនៅក្នុងត្រទី១ខាងលើនេះ នៅពេលបោះយុថ្កា។

នៅពេលមិនបំពេញកណ្ដជារកិច្ច នាវាកណ្ដជារ ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងស្របតាមប្រភេទនិងប្រវែងនាវា។

**មាត្រា១០៣ .-**

នាវាបោះយុថ្កា ត្រូវប្រើភ្លើងបើកបរឬសញ្ញាបើកបរដែលអាចមើលឃើញច្បាស់ ដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពណ៌សឬស្វ៊ែមួយ នៅផ្នែកខាងមុខ
- ភ្លើងបីរយហុកសិបដឺក្រេពណ៌ស នៅកន្សៃឬជិតកន្សៃ ដែលស្ថិតនៅទាបជាងភ្លើងនៅផ្នែកខាងមុខ។

នាវាមានប្រវែងខ្លីជាង៥០(ហាសិប)ម៉ែត្រ ត្រូវប្រើភ្លើងបីរយហុកសិបដឺក្រេពណ៌សដែលអាចមើលឃើញច្បាស់ ជំនួសភ្លើងដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

នៅពេលបោះយុថ្កា នាវាមានប្រវែងចាប់ពី១០០(មួយរយ)ម៉ែត្រឡើង ត្រូវប្រើផងដែរនូវភ្លើងបំភ្លឺដាន់នាវាដែលមានអាំងតង់ស៊ីតេខ្ពស់ឬភ្លើងប្រហាក់ប្រហែល។

នាវាកឿង ត្រូវប្រើភ្លើងដូចមានចែងនៅក្នុងកថាខណ្ឌទី១ឬទី២នៃមាត្រានេះ និងត្រូវប្រើបន្ថែមនូវភ្លើងបើកបរឬសញ្ញាបើកបរដែលអាចមើលឃើញច្បាស់ ដូចខាងក្រោម៖

- ភ្លើងបីរយហុកសិបដឺក្រេពីរពណ៌ក្រហម នៅលើបន្ទាត់ឈរតែមួយ
- ស្វ៊ែបីនៅលើបន្ទាត់ឈរតែមួយ។

នាវាមានប្រវែងខ្លីជាង៧(ប្រាំពីរ)ម៉ែត្រ មិនតម្រូវឱ្យប្រើភ្លើងបើកបរឬសញ្ញាបើកបរ ដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ នៅពេលដែលបោះយុថ្កានៅកន្លែងមិនស្ថិតនៅក្នុងឬនៅជិតប្រឡាយនាវាចរណ៍តូចចង្អៀត ច្រកនាវាចរណ៍ ឬតំបន់បោះយុថ្កា ឬកន្លែងដែលនាវាផ្សេងទៀតធ្វើនាវាចរណ៍ជាធម្មតា។

នាវាមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ មិនតម្រូវឱ្យប្រើភ្លើងឬសញ្ញាបើកបរដូចមានចែងនៅក្នុងត្រទី១និងត្រទី២ កថាខណ្ឌទី៤នៃមាត្រានេះ នៅពេលកឿង។

**មាត្រា១០៤ .-**

ករណីយន្តហោះសមុទ្រឬយានហោះលើទឹក មិនអាចប្រើភ្លើងបើកបរនិងសញ្ញាបើកបរតាមបច្ចេកទេសតាមទីតាំង ដូចមានចែងនៅក្នុងផ្នែកនេះទេ នាវានោះត្រូវប្រើភ្លើងបើកបរនិងសញ្ញាបើកបរប្រហាក់ប្រហែលតាមបច្ចេកលក្ខណៈនិងទីតាំង ដែលអាចធ្វើទៅបាន។

## កថាភាគទី៤
## សញ្ញាសំឡេងនិងសញ្ញាភ្លើង

**មាត្រា១០៥ .-**

នាវាមានប្រវែងចាប់ពី១២(ដប់ពីរ)ម៉ែត្រឡើង ត្រូវបំពាក់ស៊ីផ្លេ នាវាមានប្រវែងចាប់ពី២០(ម្ភៃ)ម៉ែត្រឡើង ត្រូវបំពាក់ជួងបន្ថែម និងនាវាមានប្រវែងចាប់ពី១០០(មួយរយ)ម៉ែត្រឡើង ត្រូវបំពាក់គងបន្ថែម ដែលមានសំឡេងមិនត្រូវច្រឡំនឹងសំឡេងជួង។ ជួង ឬគង ឬឧបករណ៍ទាំងពីរ អាចជំនួសដោយឧបករណ៍ផ្សេងទៀតដែលមានបច្ចេកលក្ខណៈសំឡេងដូច និងអាចផ្តល់សញ្ញាសំឡេងបាន។

នាវាមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ មិនមានកាតព្វកិច្ចបំពាក់សញ្ញាសំឡេងដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះឡើយ។ ទោះបីជាមិនមានកាតព្វកិច្ចបំពាក់សញ្ញាសំឡេងបែបនេះក៏ដោយ ក៏នាវាត្រូវបំពាក់ឧបករណ៍ឬប្រើមធ្យោបាយផ្សេងទៀត ដែលអាចបញ្ចេញសំឡេងបាន។

**មាត្រា១០៦ .-**

នៅពេលនាវាមើលឃើញគ្នា ហើយការធ្វើចលនាចរណ៍ត្រូវបានតម្រូវដោយបទប្បញ្ញត្តិនៃច្បាប់នេះ នាវាប្រើម៉ាស៊ីនកំពុងធ្វើដំណើរ ត្រូវបន្លឺសញ្ញាសំឡេងតាមស៊ីផ្លេ ដូចខាងក្រោម៖

- ខ្លី១ ប្រាប់ថា «ខ្ញុំកំពុងប្តូរទិសបើកបរទៅស្តាំ»
- ខ្លី២ ប្រាប់ថា «ខ្ញុំកំពុងប្តូរទិសបើកបរទៅឆ្វេង»
- ខ្លី៣ ប្រាប់ថា «ខ្ញុំកំពុងធ្វើចលនាថយក្រោយ»។

ក្នុងកំលុងពេលបញ្ជាចលនាចរណ៍ នាវានីមួយៗអាចបន្ថែមលើសំឡេងស៊ីផ្លេដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ នូវសញ្ញាភ្លើងដូចខាងក្រោម៖

ក- សញ្ញាភ្លើង ត្រូវមានអត្ថន័យដូចខាងក្រោម៖

- បញ្ចេញពន្លឺ១ ប្រាប់ថា «ខ្ញុំកំពុងប្តូរទិសបើកបរទៅស្តាំ»
- បញ្ចេញពន្លឺ២ ប្រាប់ថា «ខ្ញុំកំពុងប្តូរទិសបើកបរទៅឆ្វេង»
- បញ្ចេញពន្លឺ៣ ប្រាប់ថា «ខ្ញុំកំពុងធ្វើចលនាថយក្រោយ»។

ខ- ការបញ្ចេញពន្លឺ១ មានរយៈពេលប្រហែល១(មួយ)វិនាទី ចន្លោះពេលនៃការបញ្ចេញពន្លឺពីមួយទៅមួយ មានថិរវេលាប្រហែល១(មួយ)វិនាទី ហើយគម្លាតពីសញ្ញាភ្លើងមួយទៅមួយទៀតមានរយៈពេលមិនតិចជាង១០(ដប់)វិនាទី។

គ- ភ្លើងដែលប្រើសម្រាប់ផ្តល់សញ្ញា ត្រូវជាភ្លើងបីរយហុកសិបដឺក្រេពណ៌ស ដែលគេអាចមើលឃើញច្បាស់ក្នុងចម្ងាយអប្បបរមា៥(ប្រាំ)ម៉ៃល៍សមុទ្រ។

នៅពេលនាវាមើលឃើញគ្នានៅក្នុងប្រឡាយនាវាចរណ៍តូចចង្អៀតឬច្រកនាវាចរណ៍៖

ក- នាវាដែលមានបំណងជែងនាវាផ្សេងទៀត ត្រូវបញ្ជាក់អំពីបំណងសុំជែងស្របតាមបញ្ញត្តិនៃចំណុចក កថាខណ្ឌទី៥ មាត្រា៨៥នៃច្បាប់នេះ ដោយបន្លឺសញ្ញាសំឡេងតាមស៊ីផ្លេ ដូចខាងក្រោម៖

- វែង២ ខ្លី១ ប្រាប់ថា «ខ្ញុំមានបំណងជែងអ្នកខាងស្តាំ»
- វែង២ ខ្លី២ ប្រាប់ថា «ខ្ញុំមានបំណងជែងអ្នកខាងឆ្វេង»។

ខ- នាវាត្រូវជែង ត្រូវបញ្ជាក់អំពីការយល់ព្រមឱ្យជែងស្របតាមបញ្ញត្តិនៃចំណុចក កថាខណ្ឌទី៥ មាត្រា៨៥នៃច្បាប់នេះ ដោយបន្លឺសញ្ញាសំឡេងនូវសំឡេង៤ ដែលមានសំឡេង វែង១ ខ្លី១ វែង១ និងខ្លី១។

នៅពេលនាវាមើលឃើញកំពុងខិតជិតគ្នា ហើយនាវានីមួយៗមិនអាចយល់អំពីបំណងរបស់នាវាផ្សេងទៀតបាន ឬមានការសង្ស័យអំពីវិធានការដើម្បីចៀសការប៉ះទង្គិចដោយនាវាមួយទៀតផុតឬមិនផុត

នាវាដែលមានការសង្ស័យនោះត្រូវបន្លឺសញ្ញាសំឡេងនូវសំឡេងខ្លី៥និងត្រូវធ្វើឡើងជាញឹកញាប់។ សញ្ញាសំឡេងនេះ អាចត្រូវបានប្រើបន្ថែមដោយសញ្ញាភ្លើងដែលមានពន្លឺខ្លី៥ និងត្រូវធ្វើឡើងវិញជាញឹកញាប់ផងដែរ។

នាវាកំពុងធ្វើដំណើរចូលជិតផ្លូវកោង ឬតំបន់ប្រឡាយនាវាចរណ៍ ឬច្រកនាវាចរណ៍ ដែលជាកន្លែងមិនអាចមើលឃើញគ្នាបាន ត្រូវបន្លឺសញ្ញាសំឡេងនូវសំឡេងវែង១។ នាវាផ្សេងទៀតដែលកំពុងស្ថិតនៅតាមផ្លូវកោង ប្រឡាយនាវាចរណ៍ ឬច្រកនាវាចរណ៍នេះ ដែលបានឮសញ្ញាសំឡេងនោះ ត្រូវឆ្លើយតបវិញដោយបន្លឺសញ្ញាសំឡេងដូចគ្នា។

ប្រសិនបើមានបំពាក់ស៊ីផ្លេច្រើន ដែលមានចម្ងាយពីគ្នាលើសពី១០០(មួយរយ)ម៉ែត្រ នោះការប្រើសញ្ញាសំឡេងសម្រាប់ចលនាចរណ៍និងសញ្ញាជូនដំណឹង ត្រូវធ្វើឡើងដោយស៊ីផ្លេតែមួយប៉ុណ្ណោះ។

**មាត្រា១០៧.-**

នៅក្នុងឬជិតកន្លែងដែលការមើលឃើញមានកម្រិត ទោះជាពេលយប់ឬពេលថ្ងៃ សញ្ញាដូចមានចែងនៅក្នុងមាត្រានេះ ត្រូវប្រើដូចខាងក្រោម៖

១- នាវាប្រើម៉ាស៊ីនដែលនៅមានចលនាលើផ្ទៃទឹក ត្រូវបន្លឺសញ្ញាសំឡេងនូវសំឡេងវែងមួយ ដែលសញ្ញាសំឡេងនេះអាចបន្លឺជាបន្តបន្ទាប់ទៀតបានក្នុងគម្លាតមិនលើសពី២(ពីរ)នាទី។

២- នាវាប្រើម៉ាស៊ីនដែលកំពុងធ្វើដំណើរ បានបញ្ឈប់ចលនាស្លាបចក្រនិងអស់ល្បឿនលើផ្ទៃទឹក ត្រូវបន្លឺសញ្ញាសំឡេងនូវសំឡេងវែង២ជាប់គ្នាដែលមានគម្លាតពីគ្នាមិនលើសពី២វិនាទី ហើយអាចធ្វើឡើងជាបន្តបន្ទាប់ក្នុងគម្លាតមិនលើសពី២(ពីរ)នាទី។

៣- នាវាមិនអាចបញ្ជា នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ នាវាមានដែនកម្រិតជម្រៅស៊ីទឹក នាវាប្រើក្ដោង នាវាកំពុងធ្វើនេសាទ និងនាវាកំពុងសណ្ដោងឬរុញនាវាផ្សេងទៀត ត្រូវបន្លឺសញ្ញាសំឡេងនូវសំឡេង៣ជាប់ៗគ្នាដែលមានសំឡេងវែង១និងខ្លី២ ហើយអាចធ្វើឡើងជាបន្តបន្ទាប់ក្នុងគម្លាតមិនលើសពី២(ពីរ)នាទី ជំនួសសញ្ញាដូចមានចែងនៅក្នុងចំណុចទី១ និងចំណុចទី២ខាងលើនេះ។

៤- នាវាកំពុងធ្វើនេសាទនៅពេលបោះយុថ្កា និងនាវាមានកម្រិតសមត្ថភាពចលនាចរណ៍កំពុងធ្វើការងារនៅពេលបោះយុថ្កា ត្រូវបន្លឺសញ្ញាដូចមានចែងនៅក្នុងចំណុចទី៣ខាងលើនេះ ជំនួសសញ្ញាដូចមានចែងនៅក្នុងចំណុចទី៧នៃមាត្រានេះ។

៥- នាវាត្រូវសណ្ដោងឬប្រសិនបើនាវាត្រូវសណ្ដោងមានលើសពី១គ្រឿង ហើយប្រសិនបើនាវាត្រូវសណ្ដោងដែលនៅចុងក្រោយបង្អស់មាននាវិកនៅលើនោះ ត្រូវបន្លឺសញ្ញាសំឡេងនូវសំឡេង៤ជាប់ៗគ្នាដែលមានសំឡេងវែង១និងខ្លី៣ ហើយអាចធ្វើឡើងជាបន្តបន្ទាប់ក្នុងគម្លាតមិនលើសពី២(ពីរ)នាទី។ ប្រសិនបើអាចធ្វើបាន សញ្ញានេះត្រូវបន្លឺឡើងភ្លាមៗបន្ទាប់ពីទទួលបានសញ្ញាសំឡេងពីនាវាសណ្ដោង។

៦- នាវារុញនិងនាវាត្រូវរុញ ដែលបានចងភ្ជាប់គ្នាជាអង្គតែមួយ ត្រូវចាត់ទុកជានាវាប្រើម៉ាស៊ីនតែមួយ និងត្រូវបន្លឺសញ្ញាសំឡេងដូចមានចែងនៅក្នុងចំណុចទី១ និងចំណុចទី២នៃមាត្រានេះ។

៧- នាវាបោះយុថ្កា ត្រូវគោះជួងឱ្យញាប់ក្នុងរយៈពេល៥(ប្រាំ)វិនាទី ហើយអាចធ្វើឡើងជាបន្តបន្ទាប់ក្នុងគម្លាតមិនលើសពី១(មួយ)នាទី។ នាវាមានប្រវែងចាប់ពី១០០(មួយរយ)ម៉ែត្រឡើង ត្រូវគោះជួងនៅផ្នែកខាងមុខ ហើយបន្ទាប់ពីគោះជួងនោះភ្លាម ត្រូវវាយគងក្នុងរយៈពេលប្រហែល៥(ប្រាំ)វិនាទីនៅផ្នែកខាងក្រោយ។ ក្នុងពេលបោះយុថ្កា នាវាអាចបន្លឺសញ្ញាសំឡេងបន្ថែមនូវសំឡេង៣ជាប់ៗគ្នាដែលមានសំឡេងខ្លី១ វែង១ និងខ្លី១ ដើម្បីព្រមានអំពីទីតាំងដែលនាវាកំពុងស្ថិតនៅនិងភាវនីយភាពនៃការប៉ះទង្គិចជាមួយនាវាដែលអាចនឹងធ្វើការចូលមកជិត។

៨- នាវាកឿង ត្រូវគោះជួង ហើយប្រសិនបើចាំបាច់ ត្រូវវាយគង ដូចមានចែងនៅក្នុងចំណុចទី៧ ខាងលើនេះ ហើយត្រូវគោះជួងឱ្យមានសំឡេងខ្លាំងនិងប្លែកគ្នា៣(បី)ដងភ្លាមៗនៅមុននិងក្រោយការគោះជួងបន្ថែមទៀត។ នាវាកឿង អាចបន្លឺសញ្ញាសំឡេងតាមស៊ីផ្លេបន្ថែមទៀត។

៩- នាវាមានប្រវែងចាប់ពី១២(ដប់ពីរ)ម៉ែត្រដល់ក្រោម២០(ម្ភៃ)ម៉ែត្រ មិនតម្រូវឱ្យគោះជួងដូចមានចែងនៅក្នុងចំណុចទី៧ និងចំណុចទី៨ខាងលើនេះទេ។ ករណីនាវាមិនមានជួង នាវាត្រូវប្រើវិធីផ្សេងទៀតដើម្បីផ្តល់សញ្ញាសំឡេងដែលមានប្រសិទ្ធភាព ហើយអាចធ្វើជាបន្តបន្ទាប់ក្នុងគម្លាតមិនលើសពី២(ពីរ) នាទី។

១០- នាវាមានប្រវែងខ្លីជាង១២(ដប់ពីរ)ម៉ែត្រ មិនតម្រូវឱ្យបន្លឺសញ្ញាសំឡេងដូចមានចែងខាងលើនោះទេ។ ករណីមិនអាចបន្លឺសញ្ញាសំឡេងនោះបាន នាវាត្រូវបន្លឺសញ្ញាសំឡេងដោយប្រើវិធីផ្សេងទៀតដែលមានប្រសិទ្ធភាព ហើយអាចធ្វើឡើងជាបន្តបន្ទាប់ក្នុងគម្លាតមិនលើសពី២(ពីរ)នាទី។

១១- នាវាកណ្តាលដែលកំពុងបំពេញកណ្តាលកិច្ច អាចបន្លឺសញ្ញាសំឡេងនូវសំឡេងខ្លី៤ ដើម្បីសម្គាល់អត្តសញ្ញាណរបស់ខ្លួន បន្ថែមលើសញ្ញាសំឡេងដូចមានចែងនៅក្នុងចំណុចទី១ ឬទី២ ឬទី៧ នៃមាត្រានេះ។

**មាត្រា១០៨ .-**

ប្រសិនបើមានការចាំបាច់ត្រូវប្រើសញ្ញាប្រុងប្រយ័ត្នប្រាប់ទៅនាវាផ្សេងទៀត នាវាអាចប្រើសញ្ញាភ្លើង ឬសញ្ញាសំឡេង ដែលមិនច្រឡំនឹងសញ្ញាដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនាវាចរណ៍ ឬអាចបញ្ចាំងភ្លើងហ្វាតម្រង់ទៅជ្រុងនៃគ្រោះថ្នាក់ ដែលមិនឱ្យរំខានដល់ការធ្វើដំណើររបស់នាវាណាមួយ។ ភ្លើងប្រុងប្រយ័ត្នប្រាប់ទៅនាវាផ្សេងទៀត មិនត្រូវធ្វើឱ្យច្រឡំនឹងសញ្ញាជំនួយនាវាចរណ៍។ សម្រាប់គោលបំណងនៃមាត្រានេះ ត្រូវចៀសវាងការប្រើភ្លើងភ្លឺលត់ដែលមានអាំងតង់ស៊ីតេខ្ពស់ឬភ្លើងវិលភ្លឺបភ្លែត។

**មាត្រា១០៩ .-**

នៅពេលស្ថិតក្នុងគ្រាមានអាសន្ននិងត្រូវការជំនួយសង្គ្រោះ នាវាត្រូវប្រើសញ្ញាគ្រាអាសន្ន។

**មាត្រា១១០ .-**

លក្ខណៈបច្ចេកទេសនៃភ្លើងបើកបរ សញ្ញាបើកបរ សញ្ញាភ្លើង សញ្ញាសំឡេង សញ្ញាគ្រាអាសន្ន និងប្រភេទ និងការប្រើទង់សញ្ញាអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## កថាភាគទី៥
## វិធានពិសេស

**មាត្រា១១១ .-**

នាវាដែលធ្វើនាវាចរណ៍តាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវបើកបរក្នុងស្ថានភាពដូចខាងក្រោម៖

- នាវាដឹកអ្នកដំណើរឬនាវាដឹកទំនិញគ្រោះថ្នាក់ មិនត្រូវសណ្តោងនាវាផ្សេងទៀត ហើយនាវាផ្សេងទៀតមិនត្រូវសណ្តោងនាវាដឹកអ្នកដំណើរឬនាវាដឹកទំនិញគ្រោះថ្នាក់ លើកលែងតែក្នុងករណីជួយសង្គ្រោះឬករណីប្រធានសក្តិ
- នាវាមិនត្រូវជែងនៅទីកន្លែងមានដាក់ផ្លាកសញ្ញាហាមជែង ពេលឆ្លងកាត់ក្រោមស្ពាន និងទីតាំងគ្មានសុវត្ថិភាព ជាអាទិ៍ច្រកមានទទឹងតូចចង្អៀតខណៈមាននាវាផ្សេងទៀតកំពុងធ្វើដំណើរបញ្ច្រាសទិសឬក្នុងស្ថានភាពមើលឃើញមានកម្រិត ផ្លូវបាំងមើលមិនឃើញ ឬមានស្ថានភាពបត់បែនខ្លាំង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- នាវាមិនត្រូវធ្វើចលនាចរណ៍នៅកណ្តាលផ្លូវនាវាឆ្លងកាត់ នៅកន្លែងបាំងមើលមិនឃើញ កន្លែងផ្លូវបត់បែន ច្រកក្រោមស្ពាន និងកន្លែងដែលមានដាក់ផ្លាកសញ្ញាហាមធ្វើចលនាចរណ៍នាវា។

**មាត្រា១១២ .-**

មុនពេលឆ្លងកាត់ក្រោមស្ពាន នាយនាវា ឬបរិបាលនាវា ឬអ្នកបើកបរនាវា ត្រូវគោរពតាមវិធានដូចខាងក្រោម៖

- ពិនិត្យឱ្យបានច្បាស់នូវស្ថានភាពក្រោមស្ពានដែលត្រូវឆ្លងកាត់ រួមមានកម្ពស់ក្រោមស្ពាន ទទឹងចន្លោះសសរស្ពាន ចរន្តទឹកហូរ រួមទាំងលក្ខខណ្ឌនៃការឆ្លងកាត់
- ត្រួតពិនិត្យប្រព័ន្ធចង្កូត ប្រព័ន្ធចងពួរ និងប្រព័ន្ធការពារការប៉ះទង្គិច
- បើកបរឆ្លងកាត់តាមផ្លាកសញ្ញាឆ្លងកាត់ក្រោមស្ពាន និងនៅក្នុងដែនកំណត់សញ្ញាជំនួយនាវាចរណ៍
- ធានាថាមានសុវត្ថិភាពនៅពេលបើកបរឆ្លងកាត់ក្រោមស្ពានដែលស្ថិតក្នុងស្ថានភាពទឹកហូរក្តួច ហើយប្រសិនបើមិនមានសុវត្ថិភាពក្នុងការបើកបរឆ្លងកាត់ ត្រូវបញ្ឈប់នាវា។

**មាត្រា១១៣ .-**

លើកលែងតែនាវាមិនអាចបញ្ជាបាន នាវាមានកម្រិតសមត្ថភាពចលនាចរណ៍ និងនាវាមានដែនកម្រិតជម្រៅស៊ីទឹក នាវាគ្រប់ប្រភេទ ត្រូវចៀសវាងការបង្អាក់ដល់ការធ្វើដំណើរដោយសុវត្ថិភាពរបស់នាវាបំពេញបេសកកម្មពិសេស និងនាវាបំពេញសកម្មភាពសុវត្ថិភាពសាធារណៈ។

នាវាបំពេញបេសកកម្មពិសេស ក្នុងពេលបំពេញភារកិច្ច ត្រូវបើកភ្លើងភ្លឹបភ្លែតពណ៌ខៀវដែលមានខួបបញ្ចេញពន្លឺចន្លោះ៥០(ហាសិប)ទៅ៧០(ចិតសិប)ដងក្នុងមួយនាទី។

នាវាបំពេញសកម្មភាពសុវត្ថិភាពសាធារណៈ ក្នុងពេលបំពេញភារកិច្ច ត្រូវបើកភ្លើងភ្លឹបភ្លែតពណ៌ក្រហមដែលមានខួបបញ្ចេញពន្លឺចន្លោះ៥០(ហាសិប)ទៅ៧០(ចិតសិប)ដងក្នុងមួយនាទី។

ភ្លើងភ្លឹបភ្លែតដែលបំពាក់នៅលើនាវាបំពេញបេសកកម្មពិសេស និងនាវាបំពេញសកម្មភាពសុវត្ថិភាពសាធារណៈ ត្រូវដាក់នៅលើទីតាំងខ្ពស់ជាងភ្លើងដងក្តោង និងមើលឃើញច្បាស់ក្នុងមុំបីរយហុកសិបដឺក្រេ។

បន្ថែមពីលើភ្លើងភ្លឹបភ្លែត នាវាបំពេញបេសកកម្មពិសេស និងនាវាបំពេញសកម្មភាពសុវត្ថិភាពសាធារណៈ អាចដាក់សញ្ញាបើកបរ ទង់សញ្ញា និងស៊ីរ៉ែន ដែលមានបច្ចេកលក្ខណៈខុសពីសញ្ញាបើកបរ សញ្ញាសំឡេង និងសញ្ញាភ្លើង ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនាវាចរណ៍។

**មាត្រា១១៤ .-**

បន្ថែមពីលើវិធានដូចមានចែងនៅក្នុងកថាភាគទី២ កថាភាគទី៣ និងកថាភាគទី៤ នៃផ្នែកទី១នេះ នាវាដែលធ្វើនាវាចរណ៍តាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចប្រើប្រាស់មធ្យោបាយផ្សេងទៀត មានជាអាទិ៍ទង់សញ្ញាអន្តរជាតិ និងវិទ្យុទាក់ទងប្រេកង់ខ្ពស់រវាងនាវានិងនាវា និងរវាងនាវានិងស្ថានីយវិទ្យុឆ្នេរសមុទ្រឬកំពង់ផែ ដើម្បីបញ្ចៀសគ្រោះថ្នាក់នៃការប៉ះទង្គិច។

## ផ្នែកទី២

## សុវត្ថិភាព សន្តិសុខ និងបរិស្ថាន ក្នុងការធ្វើនាវាចរណ៍

### កថាភាគទី១

### សុវត្ថិភាព សន្តិសុខ និងបរិស្ថាន

**មាត្រា១១៥ .-**

[illegible]ម្ចាស់នាវាភារវេទកិច្ច ត្រូវធានាភាពមានសុវត្ថិភាព ជាអាទិ៍ចំនួននាវិកអប្បបរមា សុវត្ថិភាព [illegible] ធានាការប្រុងប្រយ័ត្ន ដើម្បីឱ្យនាវាធ្វើនាវាចរណ៍ប្រកបដោយសុវត្ថិភាព មិនបង្កផលប៉ះពាល់ដល់បរិស្ថាន សម្រាប់នាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស និងនាវាសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ។

**មាត្រា១១៦ .-**

ម្ចាស់នាវា ម្ចាស់នាវាការវេទកិច្ច នាយនាវា ឬបរិបាលនាវា ត្រូវរក្សាតួ ម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខារ របស់នាវាដែលបានកត់ត្រាចូលក្នុងវិញ្ញាបនបត្រចុះបញ្ជីនាវា វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា និងវិញ្ញាបនបត្របច្ចេកទេសរបស់នាវា ក្រោយពីនាវានោះបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសរួចរាល់តាម កាលបរិច្ឆេទកំណត់។

**មាត្រា១១៧ .-**

នាវាសញ្ជាតិខ្មែរ ត្រូវមានរបាយការណ៍វាយតម្លៃសន្តិសុខនាវា ផែនការសន្តិសុខនាវា វិញ្ញាបនបត្រ សន្តិសុខនាវា នាយសន្តិសុខនាវា និងនាវិកផ្នែកសន្តិសុខនាវា។

សន្តិសុខនាវា ត្រូវកំណត់ដោយអនុក្រឹត្យ។

## កថាភាគទី២
## យន្តការសម្របសម្រួលសុវត្ថិភាព សន្តិសុខ និងបរិស្ថាន

**មាត្រា១១៨ .-**

ត្រូវបានបង្កើតយន្តការនិងមជ្ឈមណ្ឌល ដើម្បីធានានូវកិច្ចសហការ និងសម្របសម្រួលការត្រៀម និងការឆ្លើយតបនឹងការកំពប់ប្រេងនិងសារធាតុគ្រោះថ្នាក់ ការរុករកនិងសង្គ្រោះក្នុងគ្រាអាសន្ន ដូចខាងក្រោម៖

១- គណៈកម្មាធិការជាតិត្រៀមនិងឆ្លើយតបនឹងការកំពប់ប្រេងនិងសារធាតុគ្រោះថ្នាក់។

២- គណៈកម្មាធិការជាតិរុករកនិងសង្គ្រោះក្នុងគ្រាអាសន្ន។

៣- មជ្ឈមណ្ឌលរុករកនិងសង្គ្រោះក្នុងគ្រាអាសន្ន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិនីមួយៗ និងមជ្ឈមណ្ឌល ដូចមានចែងនៅក្នុង កថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣
## គ្រោះថ្នាក់នាវាចរណ៍
## កថាភាគទី១
## គ្រោះថ្នាក់នាវាចរណ៍

**មាត្រា១១៩ .-**

នាយនាវាឬបរិបាលនាវា ត្រូវខិតខំប្រឹងប្រែងផ្តល់ជំនួយសង្គ្រោះដល់មនុស្សគ្រប់រូប ដែលកំពុង រងគ្រោះដោយគ្រោះថ្នាក់នាវាចរណ៍ ប្រសិនបើនាវា ក្រុមនាវិក អ្នកដំណើរនៅលើនាវារបស់ខ្លួននៅតែស្ថិត នៅក្នុងស្ថានភាពសុវត្ថិភាព។

**មាត្រា១២០ .-**

នាយនាវាឬបរិបាលនាវា ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុគ្រោះថ្នាក់នាវាចរណ៍ជាបន្ទាន់ តាមដែលអាច ធ្វើបាន ទៅអាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុត ក្នុងករណីអ្នកដំណើរឬបុគ្គលណាមួយរងរបួស ឬបាត់បង់ ជីវិត។

**មាត្រា១២១ .-**

នាយនាវាឬបរិបាលនាវា ត្រូវខិតខំប្រឹងប្រែងបញ្ចៀសគ្រោះថ្នាក់ដល់នាវា ក្រុមនាវិក អ្នកដំណើរនៅ លើនាវារបស់ខ្លួន និងត្រូវផ្តល់ជំនួយសង្គ្រោះដល់នាវា ក្រុមនាវិក និងអ្នកដំណើរនៅលើនាវាផ្សេងទៀត បន្ទាប់ ពីមានការប៉ះទង្គិចនាវា។

នាយនាវាឬបរិបាលនាវាដែលស្ថិតនៅក្នុងស្ថានភាពប៉ះទង្គិចនាវា បង្កឱ្យមានគ្រោះថ្នាក់នាវាចរណ៍ ឬបង្កឱ្យមានការរងរបួស ឬបាត់បង់ជីវិតមនុស្សនៅលើនាវា ត្រូវជូនដំណឹងជាបន្ទាន់អំពីឧបទ្ទវហេតុនេះ រួមទាំងអត្តសញ្ញាណនាវារបស់ខ្លួន នាវាផ្សេងទៀតដែលបានប៉ះទង្គិច និងកំពង់ផែដែលនាវារបស់ខ្លួនត្រូវចូលចត ទៅអាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុត។

**មាត្រា១២២ .-**

នាយនាវាឬបរិបាលនាវា ត្រូវជូនដំណឹងដល់នាវាផ្សេងទៀតដែលស្ថិតនៅជិតនាវានោះ ឬទៅអាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុតជាបន្ទាន់ តាមដែលអាចធ្វើបាន ក្នុងករណីមានព្រឹត្តិការណ៍គំរាមកំហែង សន្តិសុខនៅលើនាវា ដូចជាការប្រព្រឹត្តបទល្មើស ឬការប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ។

**មាត្រា១២៣ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិធ្វើការស៊ើបអង្កេត ឬចូលរួមស៊ើបអង្កេតគ្រោះថ្នាក់នាវាចរណ៍ដែលកើតមានឡើងនៅក្នុងដែនដីនិងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ការស៊ើបអង្កេតគ្រោះថ្នាក់នាវាចរណ៍ ត្រូវប្រមូលព័ត៌មាន សាកសួរក្រុមនាវិកនិងបុគ្គលផ្សេងទៀតអំពីឧប្បត្តិហេតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់នាវាចរណ៍។

របាយការណ៍ឬព័ត៌មានអំពីលទ្ធផលនៃការស៊ើបអង្កេតគ្រោះថ្នាក់នាវាចរណ៍ ត្រូវទុកជាឯកសារសម្រាប់កែលម្អផ្នែកបច្ចេកទេស។

## កថាភាគទី២
## សំណងលើការប៉ះទង្គិចនាវា

**មាត្រា១២៤ .-**

សំណងលើព្យសនកម្មដោយការប៉ះទង្គិចនាវា រួមមានសំណងព្យសនកម្មចំពោះនាវា មនុស្ស និងទំនិញនៅលើនាវា និងចំពោះតតិយជន។

ប្រសិនបើការប៉ះទង្គិចនាវាបាននាំដល់ស្ថានភាពគ្រោះថ្នាក់ ជាករណីបង្កឡើងដោយករណីប្រធានសក្តិ ឬមូលហេតុនៃការបង្កគ្រោះថ្នាក់ស្ថិតនៅក្នុងភាពសង្ស័យដែលមិនអាចកំណត់អំពីអ្នកទទួលខុសត្រូវបាន នាវានីមួយៗត្រូវទទួលខុសត្រូវលើព្យសនកម្មដោយខ្លួនឯង។

**មាត្រា១២៥ .-**

ករណីការប៉ះទង្គិចបានបង្កឡើងដោយនាវាមួយគ្រឿង នាវានោះត្រូវទទួលខុសត្រូវក្នុងការសងចំពោះព្យសនកម្មនៃការប៉ះទង្គិច។

ករណីការប៉ះទង្គិចបានបង្កឡើងដោយនាវាច្រើនគ្រឿង នាវានីមួយៗត្រូវទទួលខុសត្រូវក្នុងការសងចំពោះព្យសនកម្មនៃការប៉ះទង្គិច ដោយគិតតាមសមាមាត្រនៃកម្រិតកំហុសដែលនាវានោះបានប្រព្រឹត្ត។

ករណីការប៉ះទង្គិចបានបង្កឡើងដោយនាវាច្រើនគ្រឿង ហើយមានកម្រិតកំហុសស្មើៗគ្នាដែលបង្កឡើងដោយការប៉ះទង្គិចនោះ ឬពុំអាចដឹងបានអំពីកម្រិតកំហុសដែលបង្កឡើងដោយការប៉ះទង្គិចនោះ ត្រូវចាត់ទុកថា នាវានីមួយៗបានប្រព្រឹត្តកំហុសស្មើៗគ្នា និងត្រូវទទួលខុសត្រូវក្នុងការសងចំពោះព្យសនកម្មនៃការប៉ះទង្គិចស្មើៗគ្នា។

ករណីការប៉ះទង្គិចនាវា ដែលបង្កឡើងឱ្យមានការរងរបួសឬការបាត់បង់ជីវិតនៅលើនាវាដែលចូលរួមបង្កការប៉ះទង្គិចនាវា គ្រប់នាវាដែលមានកំហុសក្នុងការប៉ះទង្គិចនាវា ត្រូវរួមគ្នាទទួលខុសត្រូវក្នុងការសងចំពោះព្យសនកម្មនោះ។

**មាត្រា១២៦ .-**

បណ្តឹងទាមទារសំណងលើព្យសនកម្មដោយការប៉ះទង្គិចនាវា ត្រូវធ្វើឡើងទៅតុលាការមានសមត្ថកិច្ច ស្របតាមការកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

**មាត្រា១២៧ .-**

បញ្ញត្តិនៃមាត្រា១២៦នៃច្បាប់នេះ មិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីពាក់ព័ន្ធ ដើម្បីប្តឹងទាមទារសំណងលើព្យសនកម្មនៃការប៉ះទង្គិចនាវា ទៅតុលាការឬមជ្ឈត្តការ ឬយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ទាំងនៅក្នុងប្រទេសឬនៅបរទេស ដែលភាគីទាំងនោះបានកំណត់ជ្រើសរើសតាមការព្រមព្រៀងគ្នានោះទេ។ ការព្រមព្រៀងនេះ មិនរារាំងដល់សិទ្ធិរបស់តតិយជនក្នុងការប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានោះទេ។

**មាត្រា១២៨ .-**

បណ្តឹងឧបាស្រ័យដែលកើតឡើងពីការប៉ះទង្គិចនាវា ត្រូវធ្វើឡើងនៅចំពោះមុខតុលាការ ដែលមានយុត្តាធិការលើបណ្តឹងដំបូង ស្របតាមបញ្ញត្តិដូចមានចែងនៅក្នុងមាត្រា១២៦នៃច្បាប់នេះ។

នៅក្នុងអង្គហេតុដែលមានដើមបណ្តឹងច្រើន ដើមបណ្តឹងនីមួយៗត្រូវប្តឹងទាមទារសំណងលើព្យសនកម្មនៃការប៉ះទង្គិចនាវា នៅចំពោះមុខតុលាការដែលបានទទួលចាត់ការពាក្យបណ្តឹងទាមទារសំណងពីភាគីដែលបង្កការប៉ះទង្គិចនាវា។ ក្នុងករណីដែលមានតុលាការផ្សេងបានទទួលពាក្យបណ្តឹងទាមទារនេះ តុលាការនេះត្រូវផ្ទេរសំណុំរឿងមកតុលាការដែលកំពុងចាត់ការលើពាក្យបណ្តឹងទាមទារសំណងពីភាគីដែលបង្កការប៉ះទង្គិចនាវា។

**មាត្រា១២៩ .-**

បណ្តឹងទាមទារសំណងលើព្យសនកម្មដោយការប៉ះទង្គិចនាវា មានអាជ្ញាយុកាល៣(បី)ឆ្នាំគិតចាប់ពីថ្ងៃដែលគ្រោះថ្នាក់នៃការប៉ះទង្គិចនោះបានកើតឡើង។

**មាត្រា១៣០ .-**

ក្នុងករណីដែលមានការប៉ះទង្គិចនាវា នាវាដែលបង្កឱ្យមានព្យសនកម្ម អាចរួចផុតពីការទទួលខុសត្រូវចំពោះសំណងលើព្យសនកម្មដោយការប៉ះទង្គិចនាវា បន្ទាប់ពីមានលិខិតវិទ្ធាវ៉ទ ដោយអនុវត្តស្របតាមគោលការណ៍អន្តរជាតិ។

## កថាភាគទី៣
## ការផ្តល់ជំនួយសង្គ្រោះនាវា

**មាត្រា១៣១ .-**

គ្រប់ការជួយសង្គ្រោះនាវាដែលកំពុងជួបគ្រោះថ្នាក់និងត្រូវការជំនួយសង្គ្រោះ ដែលទទួលបានលទ្ធផលជាប្រយោជន៍ ផ្តល់នូវសិទ្ធិដល់អ្នកជួយសង្គ្រោះដើម្បីទទួលប្រាក់លាភការ។

គ្រប់ករណីនៃការជួយសង្គ្រោះ ប្រាក់លាភការសរុប មិនត្រូវលើសពីតម្លៃនៃទ្រព្យសម្បត្តិដែលបានជួយសង្គ្រោះនោះឡើយ។

**មាត្រា១៣២ .-**

នាវាសណ្តោងរុញ ដែលកំពុងអូសឬរុញនាវាផ្សេងទៀត មិនមានសិទ្ធិទទួលប្រាក់លាភការ សម្រាប់ការជួយសង្គ្រោះនាវាដែលកំពុងត្រូវអូសឬរុញនោះទេ លើកលែងតែសេវាដែលបានផ្តល់នោះ ជាសេវាបន្ថែមផ្សេងទៀត ក្រៅពីកិច្ចសន្យាសណ្តោងរុញ។

ប្រាក់លាភការសម្រាប់ការជួយសង្គ្រោះនាវា ក៏ត្រូវផ្តល់ឱ្យអ្នកជួយសង្គ្រោះសម្រាប់ការជួយសង្គ្រោះនាវា ទោះបីជានាវានោះមានម្ចាស់នាវាតែមួយ។

**មាត្រា១៣៣ .-**

ចំនួនប្រាក់លាភការត្រូវកំណត់ដោយការព្រមព្រៀងគ្នារវាងអ្នកជួយសង្គ្រោះនិងអ្នកទទួលបានការជួយសង្គ្រោះ។ ករណីមិនអាចព្រមព្រៀងគ្នា ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច។

ការបែងចែកប្រាក់លាភការក្នុងចំណោមអ្នកជួយសង្គ្រោះ ត្រូវមានការព្រមព្រៀងគ្នារវាងអ្នកជួយសង្គ្រោះទាំងអស់ ហើយករណីមិនព្រមព្រៀងគ្នា ក៏ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច។

**មាត្រា១៣៤ .-**

ចំនួនប្រាក់លាភការ ត្រូវកំណត់ដោយផ្អែកលើនិទ្ទេសដូចខាងក្រោម៖

- កម្រិតជោគជ័យដែលទទួលបាន
- កិច្ចប្រឹងប្រែងរបស់អ្នកជួយសង្គ្រោះ
- ស្ថានភាពគ្រោះថ្នាក់ដែលប្រព្រឹត្តទៅដោយនាវាត្រូវសង្គ្រោះ អ្នកដំណើរ ក្រុមនាវិក ទំនិញនៅលើនាវា អ្នកជួយសង្គ្រោះ នាវាសង្គ្រោះ
- ពេលវេលា ការចំណាយដែលត្រូវប្រើ និងការខាតបង់ដែលបានទទួលរង
- ហានិភ័យរបស់អ្នកជួយសង្គ្រោះ និងតម្លៃទ្រព្យសម្បត្តិដែលអាចជួបនឹងហានិភ័យក្នុងការជួយសង្គ្រោះ
- តម្លៃនៃទ្រព្យសម្បត្តិត្រូវសង្គ្រោះ។

**មាត្រា១៣៥ .-**

ប្រាក់លាភការសម្រាប់ការជួយសង្គ្រោះជីវិតមនុស្ស មិនអាចកាត់ថ្លៃនិងកំណត់បាន និងត្រូវអនុវត្តក្នុងនាមមនុស្សជាតិ។

អ្នកជួយសង្គ្រោះជីវិតមនុស្ស មានសិទ្ធិទទួលចំណែកប្រាក់លាភការដែលបានផ្តល់ទៅអ្នកជួយសង្គ្រោះនាវា ទំនិញ និងឧបករណ៍បរិក្ខារនៅលើនាវា។

**មាត្រា១៣៦ .-**

បណ្តឹងទាមទារប្រាក់លាភការ សម្រាប់ការជួយសង្គ្រោះនាវា មានអាជ្ញាយុកាល៣(បី)ឆ្នាំ គិតចាប់ពីពេលដែលប្រតិបត្តិការជួយសង្គ្រោះបានបញ្ចប់។

## ជំពូកទី៧
## ការលួចរត់តាមនាវា

**មាត្រា១៣៧ .-**

នៅពេលណារកឃើញអ្នកលួចរត់តាមនាវា នៅសមុទ្របូនៅកំពង់ផែចូល នាយនាវាត្រូវប្រគល់អ្នកលួចរត់តាមនាវានោះ ទៅអាជ្ញាធរមានសមត្ថកិច្ចនៅកំពង់ផែដំបូង ដែលរកឃើញអ្នកលួចរត់តាមនាវានោះ។

នៅពេលប្រគល់អ្នកលួចរត់តាមនាវាទៅអាជ្ញាធរមានសមត្ថកិច្ច នាយនាវាត្រូវផ្តល់នូវសេចក្តីបញ្ជាក់ដោយមានហត្ថលេខា ដែលបញ្ជាក់អំពីព័ត៌មានពាក់ព័ន្ធនឹងអ្នកលួចរត់តាមនាវា រួមមានសញ្ជាតិ កំពង់ផែកំណើតប្រភព ពេលវេលា និងទីតាំងភូមិសាស្ត្ររបស់នាវា ដែលអ្នកលួចរត់នោះអាចឡើងលើនាវាបានព្រមទាំងកំពង់ផែដែលនាវាចូលចេញជាបន្តបន្ទាប់រួមទាំងកាលបរិច្ឆេទផង។

លើកលែងតែអ្នកលួចរត់តាមនាវា ស្ថិតនៅក្នុងបញ្ជាឱ្យនិរទេស ឬស្ថិតនៅក្នុងការហាមឃាត់ចូលប្រទេស អាជ្ញាធរមានសមត្ថកិច្ចត្រូវទទួលអ្នកលួចរត់តាមនាវាដែលបានប្រគល់ឱ្យអនុលោមតាមមាត្រានេះ និងបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១៣៨ .-**

អាជ្ញាធរមានសមត្ថកិច្ច ដែលបានទទួលអ្នកលួចរត់តាមនាវា នៅកំពង់ផែដែលនាវាចូល ត្រូវអនុវត្តដូចខាងក្រោម៖

១- ប្រគល់អ្នកលួចរត់តាមនាវាទៅរដ្ឋម្ចាស់សញ្ជាតិអ្នកលួចរត់តាមនាវា ឬទៅរដ្ឋដែលអនុញ្ញាតទទួលសញ្ជាតិអ្នកលួចរត់តាមនាវានោះ។

២- នៅពេលណាអាជ្ញាធរមានសមត្ថកិច្ចយល់ឃើញថា រដ្ឋម្ចាស់សញ្ជាតិអ្នកលួចរត់តាមនាវា ឬរដ្ឋដែលអនុញ្ញាតទទួលសញ្ជាតិអ្នកលួចរត់តាមនាវា បដិសេធមិនទទួល ឬអាជ្ញាធរមានសមត្ថកិច្ចយល់ឃើញថា អ្នកលួចរត់តាមនាវាមិនមានសញ្ជាតិ ហើយអនុលោមតាមបញ្ញត្តិកថាខណ្ឌទី២ មាត្រា១៤០នៃច្បាប់នេះ អ្នកលួចរត់តាមនាវា មិនគួរបញ្ជូនត្រឡប់ទៅប្រទេសរបស់ខ្លួនវិញបាន អាជ្ញាធរមានសមត្ថកិច្ចត្រូវប្រគល់អ្នកលួចរត់តាមនាវានោះ ទៅកាន់រដ្ឋដែលមានកំពង់ផែ ដែលអ្នកលួចរត់តាមនាវានោះបានឡើងលើនាវាស្ថិតនៅ។

៣- ប្រសិនបើអ្នកលួចរត់តាមនាវា មិនអាចបញ្ជូនត្រឡប់វិញបាន តាមបញ្ញត្តិនៃចំណុចទី១ និងទី២ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ច ដោយអនុលោមតាមកថាខណ្ឌទី២ មាត្រា១៤០នៃច្បាប់នេះ ត្រូវបញ្ជូនអ្នកលួចរត់តាមនាវានោះ ទៅកាន់រដ្ឋដែលមានកំពង់ផែចុងក្រោយបំផុតដែលនាវាបានចូលនៅមុនពេលដែលគេបានឃើញអ្នកលួចរត់តាមនាវានោះស្ថិតនៅ។

៤- ប្រសិនបើនៅទីបំផុត អ្នកលួចរត់តាមនាវានៅតែមិនអាចបញ្ជូនត្រឡប់វិញបាន អនុលោមតាមបញ្ញត្តិដូចមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ជូនអ្នកលួចរត់តាមនាវាទៅប្រទេសម្ចាស់សញ្ជាតិនាវាដែលអ្នកលួចរត់តាមនាវាបានឃើញនៅលើនាវានោះ។ ករណីនេះ ប្រទេសម្ចាស់សញ្ជាតិនាវាមានកាតព្វកិច្ចទទួលអ្នកលួចរត់តាមនាវានោះ។

**មាត្រា១៣៩ .-**

ការចំណាយសម្រាប់ថែរក្សាអ្នកលួចរត់តាមនាវា នៅកំពង់ផែដែលនាវាចូល និងការបញ្ជូនអ្នកលួចរត់តាមនាវា ទៅកាន់ប្រទេសសញ្ជាតិរបស់ខ្លួន ជាបន្ទុកចំណាយរបស់ម្ចាស់នាវា ហើយម្ចាស់នាវាមានសិទ្ធិទាមទារសំណងពីរដ្ឋនៃម្ចាស់សញ្ជាតិអ្នកលួចរត់តាមនាវានោះបាន។

ម្ចាស់នាវាទទួលខុសត្រូវសងចំពោះការថែរក្សាអ្នកលួចរត់តាមនាវា ត្រឹមរយៈពេល៣ខែ គិតចាប់ពីពេលដែលបានប្រគល់អ្នកលួចរត់តាមនាវានោះទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា១៤០ .-**

សិទ្ធិអំណាចដែលនាយនាវាឬអាជ្ញាធរមានសមត្ថកិច្ចបានទទួលអនុលោមតាមច្បាប់នេះ ពាក់ព័ន្ធនឹងការប្រគល់អ្នកលួចរត់តាមនាវា ជាសិទ្ធិអំណាចបន្ថែម និងមិនត្រូវមោឃភាពលើសិទ្ធិអំណាចឬកាតព្វកិច្ចផ្សេងទៀតដែលនាយនាវាឬអាជ្ញាធរមានសមត្ថកិច្ចមានចំពោះការប្រគល់អ្នកលួចរត់តាមនាវានោះទេ។

ក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ នាយនាវាឬអាជ្ញាធរមានសមត្ថកិច្ចនៃកំពង់ផែដែលទទួលអ្នកលួចរត់តាមនាវា ត្រូវគិតគូរអំពីមូលហេតុដែលអ្នកលួចរត់តាមនាវា មិនអាចចាកចេញពីនាវាបាន ឬមិនអាចបញ្ជូនត្រឡប់ទៅវិញបាននៅកំពង់ផែនៃរដ្ឋដែលអ្នកលួចរត់តាមនាវាត្រូវបានបញ្ជូន។

## ជំពូកទី៨
## ការឃាត់នាវាសមុទ្រ

**មាត្រា១៤១ .-**

នាវាសមុទ្រ ទោះជាសញ្ជាតិខ្មែរឬបរទេស អាចត្រូវបានឃាត់នៅកំពង់ផែ ឬនៅតាមដែនទឹកផ្ទៃក្នុង ឬនៅតាមតំបន់សមុទ្រដែនដីក្រោយពីនាវាចេញពីដែនទឹកផ្ទៃក្នុង នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាកម្មវត្ថុនៃសំណងលើបណ្ដឹងទាមទារសំណងនាវាចរណ៍។

**មាត្រា១៤២ .-**

បណ្ដឹងទាមទារសំណងនាវាចរណ៍ រួមមាន ជាអាទិ៍៖

- ការខូចខាតដែលបង្កឡើងដោយនាវា
- ការបាត់បង់ជីវិតឬរងរបួសដែលបង្កឡើងដោយនាវា ឬដែលកើតឡើងដោយជាប់ទាក់ទងនឹងប្រតិបត្តិការរបស់នាវា
- ការជួយសង្គ្រោះនាវា នាវិក អ្នកដំណើរ និងទំនិញនៅលើនាវា
- ការព្រមព្រៀងគ្នាដែលពាក់ព័ន្ធនឹងការប្រើឬជួលនាវា
- ការព្រមព្រៀងគ្នាដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញ
- ការបាត់បង់ ខូចខាតទំនិញ រួមនឹងការវត្ថុរបស់អ្នកដំណើរ
- ការទទួលខុសត្រូវលើសំណងរួមលើការខាតបង់
- កិច្ចសន្យាខ្ចីប្រាក់របស់ម្ចាស់នាវា
- ការធានានាវា
- ប្រតិបត្តិការសណ្ដោងឬរុញ
- កណ្ដជារកិច្ច ថ្លៃឈ្នួលកំពង់ផែ ថ្លៃប្រឡាយនាវាចរណ៍
- ទំនិញឬសម្ភារៈដែលបានប្រគល់ឱ្យនាវាសម្រាប់ជានាដល់ប្រតិបត្តិការនាវាចរណ៍ ឬថែទាំនាវា
- ការសាងសង់ ការជួសជុល ថ្លៃនាវូបករណ៍ ឬថ្លៃឈ្នួលយានដ្ឋាននាវា
- ប្រាក់ឈ្នួលនាវិករបស់នាយនាវាឬក្រុមនាវិក
- ការទូទាត់សងទៅនាយនាវា រួមទាំងការទូទាត់សងដែលធ្វើឡើងដោយអ្នកប្រគល់ទំនិញ អ្នកជួលដឹកទំនិញ ឬភ្នាក់ងារនាវាក្នុងនាមម្ចាស់នាវា
- ការប្រើកម្លាំងពលកម្មនាវិក និងប្រាក់ចំណូលរបស់នាវា។

**មាត្រា១៤៣ .-**

បណ្ដឹងទាមទារសំណងនាវាចរណ៍ ដែលត្រូវធានាដោយឯកសិទ្ធិលើនាវា ត្រូវធ្វើតាមលំដាប់លេខរៀងដូចខាងក្រោម៖

១- ប្រាក់ឈ្នួលនាវិកនិងប្រាក់បន្ថែមសរុប ដែលត្រូវផ្ដល់ឱ្យនាយនាវានិងក្រុមនាវិកដែលបម្រើការងារនៅលើនាវា។

២- ថ្លៃឈ្នួលកំពង់ផែ ថ្លៃប្រឡាយនាវាចរណ៍ឬព្រែកជីក និងថ្លៃកណ្ដជារកិច្ច។

៣- បណ្ដឹងទាមទារសំណងចំពោះម្ចាស់នាវាឬម្ចាស់នាវាភាររវេទកិច្ច អំពីការបាត់បង់ជីវិតឬរងរបួសដែលបានកើតឡើងទាំងនៅលើទឹកឬនៅលើដីគោក ហើយដែលពាក់ព័ន្ធដោយផ្ទាល់នឹងការធ្វើប្រតិបត្តិការ

៤- បណ្ដឹងទាមទារសំណងចំពោះម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ច អំពីការទទួលខុសត្រូវក្នុងនិងក្រៅកិច្ចសន្យា ដែលបានបង្កការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិ ដែលបានកើតឡើងទាំងនៅលើទឹកឬនៅលើដីគោក ហើយដែលពាក់ព័ន្ធដោយផ្ទាល់នឹងការធ្វើប្រតិបត្តិការនាវា។

៥- បណ្ដឹងទាមទារសំណងសម្រាប់ការផ្ដល់ជំនួយសង្គ្រោះ ការស្រង់បំណែកនាវា និងសំណងរួមលើការខាតបង់។

គ្មានបណ្ដឹងទាមទារសំណងនាវាចរណ៍ដែលធានាដោយឯកសិទ្ធិ ត្រូវបានធ្វើឡើងចំពោះម្ចាស់នាវាឬម្ចាស់នាវាភារវេទកិច្ចបានឡើយ លើការបាត់បង់ជីវិត ការរងរបួស ការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិនោះ ដែលបង្កឡើងដោយសារធាតុវិទ្យុសកម្ម ឬសារធាតុវិទ្យុសកម្មដែលមានជាតិពុល ផ្ទុះ ឬគ្រោះថ្នាក់ ដែលមានប្រភពចេញពីថាមពលប្រេងនុយក្លេអ៊ែ ផលិតផលឬសំណល់វិទ្យុសកម្មនៃនាវានោះ ប្រសិនបើប្រតិបត្តិករនៃឋបនាការនុយក្លេអ៊ែលើនាវាទទួលខុសត្រូវសង ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិឬច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤៤ .-**

ការទូទាត់សំណងចំពោះឯកសិទ្ធិលើនាវា ត្រូវធ្វើឡើងក្នុងកំលុងពេល១(មួយ)ឆ្នាំ គិតចាប់ពីពេលដែលឯកសិទ្ធិលើនាវានេះត្រូវបានទទួលស្គាល់ លើកលែងតែនាវាត្រូវបានរឹបអូសនិងលក់ដោយបង្ខំចប់ជាស្ថាពរនៅមុនពេលកំណត់១(មួយ)ឆ្នាំនោះ។

**មាត្រា១៤៥ .-**

ការឃាត់នាវាសមុទ្រ ដើម្បីធានាប្រាក់សំណងលើបណ្ដឹងទាមទារសំណងនាវាចរណ៍មួយឬច្រើនដូចមានចែងនៅក្នុងមាត្រា១៤២នៃច្បាប់នេះ និងការដោះលែងនាវាក្រោយការទូទាត់សំណង ឬការបង់ប្រាក់កក់ឬមូលប្បទានបត្រធានាសម្រាប់ការដោះលែងនាវា ត្រូវធ្វើឡើងដោយតុលាការមានសមត្ថកិច្ច។

**មាត្រា១៤៦ .-**

ដើមបណ្ដឹងអាចប្ដឹងឃាត់នាវាសមុទ្រណាមួយទុក ដែលជាកម្មវត្ថុធានាលើបណ្ដឹងទាមទារសំណងនាវាចរណ៍ ហើយប្រសិនបើមិនអាចឃាត់នាវានោះបាន ដើមបណ្ដឹងអាចប្ដឹងឃាត់នាវាសមុទ្រផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ម្ចាស់នាវានោះជំនួសបានសម្រាប់កម្មវត្ថុដូចគ្នា។ ការឃាត់នាវានេះ មិនអាចអនុវត្តឡើយចំពោះបណ្ដឹងដែលពាក់ព័ន្ធនឹងកម្មសិទ្ធិនាវា។

នាវាសមុទ្រមិនត្រូវបានឃាត់សម្រាប់ការធានាសងលើបណ្ដឹងទាមទារសំណងរួមនិងប្រាក់កក់ឬមូលប្បទានបត្រធានាផ្សេងទៀតលើសពីមួយដងក្នុងសំណុំរឿងក្ដីដូចគ្នានិងដើមបណ្ដឹងដូចគ្នា ដោយតុលាការមានសមត្ថកិច្ចឡើយ។ ករណីនេះ នាវាសមុទ្រក៏មិនត្រូវបានឃាត់ផងដែរ ប្រសិនបើសំណុំរឿងក្ដីដូចគ្នានិងដើមបណ្ដឹងដូចគ្នា កំពុងស្ថិតនៅក្នុងដែនយុត្តាធិការនៃតុលាការបរទេស។

ការឃាត់នាវាសមុទ្រសម្រាប់ធានាលើបណ្ដឹងទាមទារសំណងនាវាចរណ៍ពីម្ចាស់នាវា មិនអាចធ្វើបានឡើយ ករណីនាវានោះស្ថិតក្នុងការគ្រប់គ្រងនិងធ្វើប្រតិបត្តិការដោយម្ចាស់នាវាភារវេទកិច្ច។

ករណីនាវាភារវេទកិច្ច ដើមបណ្ដឹងអាចប្ដឹងឃាត់នាវាភារវេទកិច្ចនោះទុកជាកម្មវត្ថុធានាលើបណ្ដឹងទាមទារសំណងនាវាចរណ៍ ហើយប្រសិនបើមិនអាចឃាត់នាវានោះបាន ដើមបណ្ដឹងអាចប្ដឹងឃាត់នាវាសមុទ្រផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ម្ចាស់នាវាភារវេទកិច្ចនោះជំនួសបានសម្រាប់កម្មវត្ថុដូចគ្នា។

**មាត្រា១៤៧ .-**

នាវាដែលត្រូវបានឃាត់សម្រាប់ជាកម្មវត្ថុនៃសំណងលើបណ្ដឹងទាមទារសំណងនាវាចរណ៍ ត្រូវអនុញ្ញាតឱ្យដោះលែងបានក្រោយពីបានទទួលប្រាក់កក់ឬមូលប្បទានបត្រធានាគ្រប់គ្រាន់ ឬក្នុងលក្ខខណ្ឌដែលមានភាពចាំបាច់សម្រាប់អាជីវកម្មឬមូលហេតុសមរម្យផ្សេងទៀត និងដោយមានការយល់ព្រមពីដើមបណ្ដឹង។

ការស្នើសុំដោះលែងនាវាដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មិនត្រូវចាត់ទុកថាជាការទទួលស្គាល់លើសំណងឬអត្ថប្រយោជន៍នៃព្រំដែនសំណងរបស់ម្ចាស់នាវាឡើយ។

**មាត្រា១៤៨ .-**

ដើមបណ្តឹងទាមទារសំណងនាវាចរណ៍ ត្រូវសងរាល់ការខូចខាតទៅម្ចាស់នាវា ក្នុងការឃាត់នាវាសមុទ្រ ការចំណាយប្រាក់កក់ឬមូលប្បទានបត្រធានានិងប្រាក់ចំណាយផ្សេងៗ ដែលកើតឡើងពីការឃាត់នាវា ប្រសិនបើចាញ់ក្តី។

**មាត្រា១៤៩ .-**

បណ្តឹងទាមទារសំណងនាវាចរណ៍ត្រូវធ្វើឡើងចំពោះមុខតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវអនុវត្តតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការដឹកជញ្ជូននិងសំណង
## ផ្នែកទី១
## ការដឹកជញ្ជូនទំនិញ
## កថាភាគទី១
## កិច្ចសន្យាដឹកជញ្ជូន

**មាត្រា១៥០ .-**

ការដឹកជញ្ជូនទំនិញតាមនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស ឬនាវាសមុទ្រ ត្រូវធ្វើឡើងតាមកិច្ចសន្យាដឹកជញ្ជូនទំនិញ។

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះការខូចខាតឬការបាត់បង់ទំនិញដែលបានដឹកជញ្ជូន ទោះបីជាយកថ្លៃឈ្នួលឬមិនយកថ្លៃឈ្នួលក៏ដោយ។

**មាត្រា១៥១ .-**

អញ្ញត្រប័ណ្ណទំនិញ ត្រូវចាត់ទុកជាឯកសារភស្តុតាងនៃកិច្ចសន្យាដឹកជញ្ជូនទំនិញតាមផ្លូវទឹក និងកិច្ចសន្យាដឹកជញ្ជូនទំនិញតាមផ្លូវសមុទ្រ។

អញ្ញត្រប័ណ្ណទំនិញ ត្រូវបញ្ចូលនូវនិទ្ទេស ដូចខាងក្រោម៖

១- លក្ខណៈទូទៅនៃទំនិញ ស្លាកសញ្ញាសម្គាល់អត្តសញ្ញាណទំនិញ ហើយបើអាចធ្វើបាន លក្ខណៈគ្រោះថ្នាក់នៃទំនិញ ចំនួនកញ្ចប់ឬដុំ ទម្ងន់ទំនិញឬបរិមាណទំនិញ ដែលផ្តល់ឱ្យដោយអ្នកផ្ញើទំនិញ។

២- លក្ខណៈខាងក្រៅនៃទំនិញ។

៣- ឈ្មោះអ្នកដឹកជញ្ជូននិងទីស្នាក់ការក្រុមហ៊ុន។

៤- ឈ្មោះអ្នកផ្ញើទំនិញ។

៥- ឈ្មោះអ្នកទទួលទំនិញប្រសិនបើបានផ្តល់ឱ្យដោយអ្នកផ្ញើទំនិញ។

៦- កំពង់ផែផ្ទុកទំនិញស្របតាមកិច្ចសន្យាដឹកជញ្ជូនទំនិញ កាលបរិច្ឆេទដែលអ្នកដឹកជញ្ជូនបានទទួលទំនិញនៅកំពង់ផែផ្ទុកទំនិញ។

៧- កំពង់ផែផ្ទេរទំនិញ ស្របតាមកិច្ចសន្យាដឹកជញ្ជូនទំនិញ។

៨- ចំនួនច្បាប់ដើមនៃអញ្ញត្រប័ណ្ណទំនិញ ប្រសិនបើលើសពីមួយច្បាប់។

៩- ទីកន្លែងផ្តល់អញ្ញត្រប័ណ្ណទំនិញ។

១០- ហត្ថលេខារបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមអ្នកដឹកជញ្ជូន។

១១- ថ្លៃឈ្នួលដឹកជញ្ជូនទំនិញដែលត្រូវបង់ដោយអ្នកទទួលទំនិញឬមានការបញ្ជាក់ថា ថ្លៃឈ្នួលដឹកជញ្ជូនទំនិញ ត្រូវបង់ដោយអ្នកផ្ញើទំនិញ។

១២- សេចក្តីបញ្ជាក់ ដូចមានចែងនៅក្នុងកថាខណ្ឌទី៣ មាត្រា១៧០នៃច្បាប់នេះ។

១៣- សេចក្តីបញ្ជាក់ បើអាចធ្វើបាន បញ្ជាក់ថាទំនិញត្រូវដឹកនៅលើដាន់នាវា។

១៤- កាលបរិច្ឆេទឬរយៈពេលនៃការប្រគល់ទំនិញនៅកំពង់ផែផ្ទេរទំនិញ ប្រសិនបើបានយល់ព្រមគ្នារវាងភាគី។

១៥- ព្រំដែនសំណងដែលលើស ឬព្រំដែនសំណងដែលបានព្រមព្រៀងគ្នា ដោយអនុលោមតាមមាត្រា១៥៤នៃច្បាប់នេះ។

អ្នកដឹកជញ្ជូនត្រូវចេញអញ្ញត្រប័ណ្ណទំនិញ បន្ទាប់ពីទំនិញបានផ្ទុកនៅលើនាវាតាមសំណើរបស់អ្នកផ្ញើទំនិញ ដែលក្នុងនោះបន្ថែមលើនិទ្ទេសដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវសរសេរបញ្ជាក់ថា ទំនិញបានផ្ទុករួចនៅលើនាវាដែលមានឈ្មោះ កាលបរិច្ឆេទ ការផ្ទុកទំនិញ ឱ្យទៅអ្នកផ្ញើទំនិញ។ អ្នកដឹកជញ្ជូនអាចស្នើសុំអញ្ញត្រប័ណ្ណទំនិញឬឯកសារពាក់ព័ន្ធនឹងទំនិញដែលបានផ្ទុកនៅលើនាវាត្រឡប់វិញពីអ្នកផ្ញើទំនិញ មុននឹងចេញអញ្ញត្រប័ណ្ណទំនិញថ្មីឬឯកសារពាក់ព័ន្ធនឹងទំនិញថ្មីដែលបញ្ជាក់ថា ទំនិញនោះបានផ្ទុកនៅលើនាវារបស់ខ្លួន។

ការខកខានបញ្ចូលនិទ្ទេសណាមួយនៅក្នុងអញ្ញត្រប័ណ្ណទំនិញ មិនប៉ះពាល់ដល់សុពលភាពនៃអញ្ញត្រប័ណ្ណទំនិញឡើយ។

## កថាភាគទី២
## សំណងរបស់អ្នកដឹកជញ្ជូន

**មាត្រា១៥២ .-**

ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន ត្រូវគិតក្នុងកំលុងពេលដែលអ្នកដឹកជញ្ជូនបានទទួលទំនិញនៅកំពង់ផែផ្ទុកទំនិញ ក្នុងកំលុងពេលដឹកជញ្ជូន និងក្នុងកំលុងពេលបានប្រគល់ទំនិញនៅកំពង់ផែផ្ទេរទំនិញ។

ត្រូវចាត់ទុកថាបានទទួលទំនិញ នៅពេលដែលអ្នកដឹកជញ្ជូនបានទទួលទំនិញពីអ្នកផ្ញើទំនិញ ឬបុគ្គលក្នុងនាមអ្នកផ្ញើទំនិញ ឬអាជ្ញាធរ ឬភាគីទីពាណាមួយនៅកំពង់ផែផ្ទុកទំនិញ រហូតដល់កំលុងពេលប្រគល់ទំនិញទៅអ្នកទទួលទំនិញ ឬប្រគល់ទំនិញនៅកន្លែងដែលបានកំណត់ដោយអ្នកទទួលទំនិញ ឬទៅអាជ្ញាធរ ឬភាគីទី៣នៅកំពង់ផែផ្ទេរទំនិញ។

**មាត្រា១៥៣ .-**

អ្នកដឹកជញ្ជូនត្រូវសងចំពោះការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ដែលបានកើតឡើងក្នុងកំលុងពេលបានទទួលទំនិញ។ ករណីនេះត្រូវបានលើកលែងប្រសិនបើមានភស្តុតាងបញ្ជាក់ថា អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន បានចាត់វិធានការគ្រប់យ៉ាងដើម្បីចៀសវាងការកើតឡើងនោះ ហើយនៅតែមិនអាចចៀសវាងបាន។

ការយឺតយ៉ាវប្រគល់ទំនិញ បានកើតឡើងនៅពេលដែលទំនិញមិនបានប្រគល់នៅកំពង់ផែផ្ទេរទំនិញតាមកាលបរិច្ឆេទកំណត់ដូចមានចែងនៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ ឬតាមពេលវេលាសមរម្យដែលអ្នកដឹកជញ្ជូនដ៏ល្អបានអនុវត្ត ប្រសិនបើមិនមានកំណត់នៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ។

បុគ្គលដែលមានសិទ្ធិប្តឹងទាមទារសំណងចំពោះការបាត់បង់ទំនិញ អាចចាត់ទុកថាទំនិញត្រូវបានបាត់បង់ ប្រសិនបើទំនិញនោះមិនត្រូវបានប្រគល់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃជាប់ៗគ្នា ក្រោយកាលបរិច្ឆេទផុតកំណត់ប្រគល់ទំនិញនោះ។

អ្នកដឹកជញ្ជូនត្រូវសងលើការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ដែលបង្កឡើងដោយអគ្គិភ័យ ប្រសិនបើអ្នកប្តឹងបានបញ្ជាក់ថា អគ្គិភ័យនោះបង្កឡើងពីកំហុសឬការធ្វេសប្រហែស ឬការខកខានរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន ដើម្បីចាត់វិធានការពន្លត់អគ្គិភ័យនោះ។

អ្នកដឹកជញ្ជូនមិនត្រូវសងលើការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ក្នុងករណីទំនិញជាសត្វរស់ ប្រសិនបើអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន បានអនុវត្តតាមការណែនាំពិសេសដែលផ្តល់ដោយអ្នកផ្ញើទំនិញ លើកលែងតែមានភស្តុតាងបញ្ជាក់ថា អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួនមានកំហុសឬធ្វេសប្រហែស។

អ្នកដឹកជញ្ជូនមិនត្រូវសងលើការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ដែលបណ្តាលមកពីវិធានការជួយសង្គ្រោះជីវិតឬជួយសង្គ្រោះទ្រព្យសម្បត្តិដែលកំពុងជួបគ្រោះថ្នាក់នាវាចរណ៍នោះទេ លើកលែងតែសំណងរួមលើការខាតបង់។

នៅពេលណាកំហុសឬការធ្វេសប្រហែសរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន បានកើតឡើងដោយភ្ជាប់នឹងការបង្កហេតុផ្សេងទៀតដែលនាំដល់ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ សំណងរបស់អ្នកដឹកជញ្ជូន ត្រូវកំណត់ត្រឹមការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវដែលជាកំហុសឬការធ្វេសប្រហែសរបស់ខ្លួនប៉ុណ្ណោះ ហើយអ្នកដឹកជញ្ជូនក៏ត្រូវបញ្ជាក់អំពីភស្តុតាងនេះផងដែរ។

**មាត្រា១៥៤ .-**

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងចំពោះការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ត្រូវអនុវត្តដូចខាងក្រោម៖

ក- សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតទំនិញ ដូចមានចែងនៅក្នុងមាត្រា១៥៣នៃច្បាប់នេះ ត្រូវកំណត់ព្រំដែនសំណងត្រឹមចំនួន៨៣៥SDR (ប្រាំបីរយសាមសិបប្រាំអេសដេអ៊ែ) ក្នុងមួយកញ្ចប់ ឬឯកតានាវាចរណ៍ផ្សេងទៀត ឬ២,៥SDR (ពីរក្បៀសប្រាំអេសដេអ៊ែ) ក្នុងមួយគីឡូក្រាម នៃទម្ងន់ទំនិញដែលបានបាត់បង់ឬខូចខាត ដោយត្រូវជ្រើសរើសយកចំនួនណាមួយដែលខ្ពស់ជាងគេ។

ខ- សំណងរបស់អ្នកដឹកជញ្ជូនចំពោះការយឺតយ៉ាវប្រគល់ទំនិញ ដូចមានចែងនៅក្នុងមាត្រា១៥៣នៃច្បាប់នេះ ត្រូវកំណត់ព្រំដែនសំណងត្រឹមចំនួន២,៥ដងនៃថ្លៃឈ្នួលដឹកជញ្ជូន ដែលបានយឺតយ៉ាវនោះ និងមិនត្រូវលើសពីថ្លៃឈ្នួលដឹកជញ្ជូនសរុប ដែលបានកំណត់នៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ។

គ- ក្នុងគ្រប់ករណី ចំនួនបូកសរុបនៃសំណងរបស់អ្នកដឹកជញ្ជូន ដូចមានចែងនៅក្នុងចំណុចក និងចំណុចខ ខាងលើនេះ មិនត្រូវលើសព្រំដែនសំណងសរុប ដូចមានចែងនៅក្នុងចំណុចក ខាងលើនេះឡើយ។

សម្រាប់គោលបំណងគណនារកចំនួនដែលខ្ពស់ជាងគេ ដូចមានចែងនៅក្នុងចំណុចក កថាខណ្ឌទី១ ខាងលើនេះ ត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

ក- ត្រូវចាត់ទុកជាកញ្ចប់ឬឯកតានាវាចរណ៍ បើកាលណាកុងតឺន័រ ប៉ាឡេត ឬវត្ថុដឹកជញ្ជូនស្រដៀងគ្នា ដែលគេបានប្រើដើម្បីខ្ចប់ទំនិញ ហើយដែលកញ្ចប់ឬឯកតាទាំងនោះ ត្រូវបានដាក់បញ្ចូលក្នុងវត្ថុដឹកជញ្ជូនទំនិញ។

ខ- ក្នុងករណីវត្ថុដឹកជញ្ជូនដែលបានបាត់បង់ឬខូចខាត ហើយដែលមិនកាន់កាប់ឬផ្តល់ឱ្យដោយអ្នកដឹកជញ្ជូន វត្ថុដឹកជញ្ជូននោះត្រូវចាត់ទុកថាជាឯកតានាវាចរណ៍មួយដាច់ដោយឡែក។

**មាត្រា១៥៥ .-**

សិទ្ធិការពារខ្លួនក្នុងព្រំដែនសំណងដូចមានចែងនៅក្នុងច្បាប់នេះ ត្រូវអនុវត្តលើបណ្ដឹងទាមទារសំណងទល់នឹងអ្នកដឹកជញ្ជូន ចំពោះការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ដូចមានចែងនៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ ក្នុងទម្រង់ជាការទទួលខុសត្រូវផ្ទាល់ ឬការទទួលខុសត្រូវក្រៅកិច្ចសន្យា។

ប្រសិនបើបណ្ដឹងទាមទារសំណង ត្រូវបានធ្វើឡើងចំពោះបុគ្គលក្នុងនាមអ្នកដឹកជញ្ជូន បុគ្គលនោះមានសិទ្ធិប្រើសិទ្ធិការពារខ្លួនក្នុងព្រំដែនសំណាង ដែលត្រូវអនុវត្តដោយអ្នកដឹកជញ្ជូននោះបាន ប្រសិនបើបុគ្គលនោះមានភស្តុតាងបញ្ជាក់ថា ខ្លួនបានបំពេញការងារក្នុងនាមអ្នកដឹកជញ្ជូន។

លើកលែងបញ្ញត្តិដូចមានចែងនៅក្នុងមាត្រា១៥៦នៃច្បាប់នេះ ចំនួនបូកសរុបនៃសំណងដែលបានមកពីអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន មិនត្រូវលើសពីព្រំដែនសំណងដូចមានចែងនៅក្នុងច្បាប់នេះឡើយ។

**មាត្រា១៥៦ .-**

អ្នកដឹកជញ្ជូនមិនត្រូវទទួលផលប្រយោជន៍ពីព្រំដែនសំណង ដូចមានចែងនៅក្នុងមាត្រា១៥៤នៃច្បាប់នេះបានឡើយ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា ការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ បណ្ដាលមកពីអំពើឬកំហុសដោយចេតនា ដើម្បីបង្កឱ្យមានការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ឬដោយការធ្វេសប្រហែស ទោះបីជាដឹងថា ការធ្វើបែបនេះបង្កឱ្យមានការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបុគ្គលក្នុងនាមអ្នកដឹកជញ្ជូន។

**មាត្រា១៥៧ .-**

អ្នកដឹកជញ្ជូនមានសិទ្ធិដឹកទំនិញនៅលើជាន់នាវាបាន ដរាបណាមានការយល់ព្រមពីអ្នកផ្ញើទំនិញ ឬស្របតាមទម្លាប់ពាណិជ្ជកម្មជាក់លាក់ណាមួយ ឬមានការតម្រូវដោយច្បាប់។

ប្រសិនបើអ្នកដឹកជញ្ជូននិងអ្នកផ្ញើទំនិញ បានយល់ព្រមដឹកទំនិញនៅលើជាន់ណាមួយនៃនាវា អ្នកដឹកទំនិញត្រូវកត់ត្រាចូលក្នុងអញ្ញត្របណ្ណទំនិញ ឬកត់ត្រាសេចក្ដីបញ្ជាក់ចូលក្នុងឯកសារ ដើម្បីទុកជាភស្តុតាងនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ។ ក្នុងករណីគ្មានសេចក្ដីបញ្ជាក់ អ្នកដឹកជញ្ជូនត្រូវទទួលបន្ទុកលើការព្រមព្រៀងគ្នាអំពីការដឹកជញ្ជូនទំនិញនៅលើជាន់នាវានិងគ្មានសិទ្ធិប្រើការព្រមព្រៀងផ្សេងទៀតចំពោះ អ្នកទទួលទំនិញដែលបានទទួលអញ្ញត្របណ្ណទំនិញនិងជាអ្នកដែលត្រូវអនុវត្តតាមអញ្ញត្របណ្ណទំនិញនោះឡើយ។

នៅពេលណាទំនិញបានដឹកជញ្ជូននៅលើជាន់នាវា ផ្ទុយពីបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ឬនៅពេលណាដែលអ្នកដឹកជញ្ជូនបានប្រើការព្រមព្រៀងផ្សេងសម្រាប់ការដឹកជញ្ជូនទំនិញនៅលើជាន់នាវា អ្នកដឹកជញ្ជូនត្រូវសងចំពោះការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ដែលបណ្ដាលមកពីការសម្រេចចិត្តដឹកជញ្ជូនទំនិញនោះដោយខ្លួនឯងនៅលើជាន់នាវា។

ការដឹកជញ្ជូនទំនិញនៅលើជាន់នាវាដែលផ្ទុយពីការព្រមព្រៀងគ្នាសម្រាប់ការដឹកជញ្ជូន ត្រូវចាត់ទុកថាជាអំពើកំហុសរបស់អ្នកដឹកជញ្ជូន ដូចមានចែងនៅក្នុងមាត្រា១៥៦នៃច្បាប់នេះ។

**មាត្រា១៥៨ .-**

អ្នកដឹកជញ្ជូននៅតែទទួលខុសត្រូវចំពោះកិច្ចសន្យាដឹកជញ្ជូនទំនិញដដែល ទោះបីជាការដឹកជញ្ជូនទំនិញឬផ្នែកណាមួយនៃការដឹកជញ្ជូនទំនិញនោះ ត្រូវបានប្រគល់ទៅអ្នកដឹកជញ្ជូនបន្តក៏ដោយ។ អ្នកដឹកជញ្ជូន

ត្រូវទទួលខុសត្រូវក្នុងនាមអ្នកដឹកជញ្ជូនបន្ត ចំពោះអំពើឬកំហុសរបស់អ្នកដឹកជញ្ជូនបន្ត ឬបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្តនោះ ដែលធ្វើសកម្មភាពក្នុងផលប្រយោជន៍របស់អ្នកដឹកជញ្ជូន។

បទប្បញ្ញត្តិនៃច្បាប់នេះ ដែលចែងអំពីការទទួលខុសត្រូវលើសំណងរបស់អ្នកដឹកជញ្ជូន ត្រូវយកមកអនុវត្តផងដែរចំពោះអ្នកដឹកជញ្ជូនបន្ត។

ការព្រមព្រៀងដោយឡែកណាមួយ ដែលតម្រូវឱ្យអ្នកដឹកជញ្ជូនទទួលកាតព្វកិច្ចដែលគ្មានចែងនៅក្នុងច្បាប់នេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកដឹកជញ្ជូនបន្តបាន ប្រសិនបើអ្នកដឹកជញ្ជូនបន្តនោះបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ។ ទោះបីជាមានការយល់ព្រមឬមិនយល់ព្រមពីអ្នកដឹកជញ្ជូនបន្តក៏ដោយ អ្នកដឹកជញ្ជូននៅតែរក្សាកាតព្វកិច្ចដែលបានកំណត់នៅក្នុងការព្រមព្រៀងដោយឡែកនោះដដែល។

អ្នកដឹកជញ្ជូននិងអ្នកដឹកជញ្ជូនបន្ត ត្រូវទទួលខុសត្រូវរួមគ្នាឬតាមផ្នែកដែលបានកំណត់។

ចំនួនបូកសរុបនៃសំណងដែលទទួលបានមកពីអ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត និងបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្ត មិនត្រូវលើសព្រំដែនសំណងដូចមានចែងនៅក្នុងច្បាប់នេះឡើយ។

**មាត្រា១៥៩ .-**

ទោះបីជាមានចែងនៅក្នុងមាត្រា១៥៨នៃច្បាប់នេះក៏ដោយ នៅពេលដែលកិច្ចសន្យាដឹកជញ្ជូនទំនិញបានចែងច្បាស់លាស់អំពីផ្នែកណាមួយនៃការដឹកជញ្ជូន ដែលត្រូវអនុវត្តដោយបុគ្គលណាម្នាក់ក្រៅពីអ្នកដឹកជញ្ជូន កិច្ចសន្យានោះអាចបញ្ជាក់ច្បាស់ថា អ្នកដឹកជញ្ជូនមិនត្រូវទទួលខុសត្រូវសងលើការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញដែលកើតឡើងនៅពេលទំនិញស្ថិតក្រោមការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនបន្តឡើយ ក្នុងកំលុងពេលនៃការដឹកជញ្ជូននោះ។ ខដែលដាក់ឬលើកលែងការទទួលខុសត្រូវសងនេះមិនមានប្រសិទ្ធភាពអនុវត្តឡើយ ប្រសិនបើពុំមានពាក្យប្តឹងចំពោះអ្នកដឹកជញ្ជូនបន្ត ទៅតុលាការមានសមត្ថកិច្ចដូចមានចែងនៅក្នុងកថាខណ្ឌទី១ មាត្រា១៦៨ នៃច្បាប់នេះ។ ការទទួលបន្ទុកផ្តល់ភស្តុតាង ដែលបញ្ជាក់អំពីការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ ត្រូវអាស្រ័យនឹងអ្នកផ្ញើទំនិញ។

អ្នកដឹកជញ្ជូនបន្តត្រូវសងលើការបាត់បង់ ការខូចខាត ឬការយឺតយ៉ាវប្រគល់ទំនិញ បង្កឡើងដោយហេតុការណ៍ដែលកើតឡើងនៅពេលខ្លួនបានទទួលទំនិញ ដោយអនុលោមតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា១៥៨នៃច្បាប់នេះ។

## កថាភាគទី៣
## សំណងរបស់អ្នកផ្ញើទំនិញ

**មាត្រា១៦០ .-**

អ្នកផ្ញើទំនិញឬបុគ្គលក្នុងនាមខ្លួន មិនទទួលបានការសងចំពោះការបាត់បង់ទំនិញឬការខូចខាតទំនិញដែលរ៉ាប់រងដោយអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្តនោះឡើយ ក្នុងករណីដែលការបាត់បង់ឬការខូចខាតនោះកើតចេញ ពីកំហុសឆ្គង ឬការធ្វេសប្រហែសរបស់អ្នកផ្ញើទំនិញ ឬបុគ្គលក្នុងនាមខ្លួន។

**មាត្រា១៦១ .-**

អ្នកផ្ញើទំនិញ ត្រូវដាក់ស្លាកសញ្ញាសម្គាល់ឬបិទស្លាកសញ្ញាសម្គាល់ដែលបញ្ជាក់ថាទំនិញគ្រោះថ្នាក់។

នៅពេលអ្នកផ្ញើទំនិញ ប្រគល់ទំនិញគ្រោះថ្នាក់ទៅអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត អ្នកផ្ញើទំនិញត្រូវផ្តល់ព័ត៌មានអំពីលក្ខណៈគ្រោះថ្នាក់នៃទំនិញ ហើយបើចាំបាច់ត្រូវបញ្ជាក់អំពីវិធានការប្រុងប្រយ័ត្នដែលត្រូវអនុវត្តទៅអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត។ ប្រសិនបើអ្នកផ្ញើទំនិញខកខានជូនព័ត៌មាននេះ ហើយអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត មិនបានដឹងអំពីលក្ខណៈគ្រោះថ្នាក់នៃទំនិញ ត្រូវអនុវត្តដូចខាងក្រោម៖

ក- អ្នកផ្ញើទំនិញត្រូវទទួលខុសត្រូវសងទៅអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្តចំពោះការបាត់បង់ ឬខូចខាតបណ្តាលមកពីការផ្ទុកទំនិញនោះនៅលើនាវា។

ខ- ទំនិញនោះត្រូវរើចេញ បំផ្លាញចោល ឬប្រគល់ឱ្យវិញបើគ្មានគ្រោះថ្នាក់ ស្របតាមកាលៈទេសៈដែលចាំបាច់ត្រូវធ្វើ ដោយគ្មានការសងទូទាត់ឡើយ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី២ខាងលើនេះ មិនត្រូវយកមកជាសំអាងដោយបុគ្គលណាម្នាក់ ប្រសិនបើក្នុងកំលុងពេលទទួលខុសត្រូវដឹកជញ្ជូនទំនិញ ដោយបានដឹងជាមុនអំពីលក្ខណៈគ្រោះថ្នាក់ទំនិញ។

ក្នុងករណីបញ្ញត្តិនៃចំណុចខ កថាខណ្ឌទី២ខាងលើនេះ មិនអាចយកមកអនុវត្តបានឬសំអាងបាន ហើយទំនិញគ្រោះថ្នាក់បានបង្កឱ្យមានគ្រោះថ្នាក់ជាក់ស្តែងដល់ជីវិតឬទ្រព្យសម្បត្តិ ទំនិញនោះត្រូវបានរើចេញ បំផ្លាញចោល ឬប្រគល់ឱ្យវិញបើគ្មានគ្រោះថ្នាក់ ស្របតាមកាលៈទេសៈដែលចាំបាច់ត្រូវធ្វើ ដោយគ្មានការសងទូទាត់ឡើយ លើកលែងតែកាតព្វកិច្ចលើសំណងរួមនៃការខាតបង់ ឬលក្ខខណ្ឌដែលតម្រូវឱ្យអ្នកដឹកជញ្ជូនត្រូវសង ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៥៣នៃច្បាប់នេះ។

**មាត្រា១៦២ .-**

នៅពេលណាអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត បានទទួលទំនិញ អ្នកដឹកជញ្ជូនត្រូវចេញអញ្ញត្រប័ណ្ណទំនិញឱ្យទៅអ្នកផ្ញើទំនិញ តាមតម្រូវការរបស់អ្នកផ្ញើទំនិញ។

អញ្ញត្រប័ណ្ណទំនិញអាចត្រូវបានចុះហត្ថលេខាដោយបុគ្គលដែលបានទទួលសិទ្ធិពីអ្នកដឹកជញ្ជូន។ អញ្ញត្រប័ណ្ណទំនិញដែលចុះហត្ថលេខាដោយនាយនាវាឬបរិបាលនាវាដែលដឹកទំនិញនោះ ត្រូវចាត់ទុកថាបានចុះហត្ថលេខាក្នុងនាមអ្នកដឹកជញ្ជូន។

ការចុះហត្ថលេខាលើអញ្ញត្រប័ណ្ណទំនិញ អាចមានក្នុងទម្រង់ជាហត្ថលេខាដោយសរសេរ ដោយបោះពុម្ពបញ្ជូនតាមមធ្យោបាយមេកានិក ដោយការចោះរន្ធ ការបោះត្រា ការដាក់សញ្ញាសម្គាល់ ឬធ្វើឡើងដោយប្រើមធ្យោបាយមេកានិកឬអេឡិចត្រូនិក។

**មាត្រា១៦៣ .-**

ប្រសិនបើអញ្ញត្រប័ណ្ណទំនិញ មាននិទ្ទេសដែលពាក់ព័ន្ធនឹងលក្ខណៈទូទៅនៃទំនិញ ស្លាកសញ្ញាសម្គាល់អត្តសញ្ញាណទំនិញ ចំនួនកញ្ចប់ឬដុំ ទម្ងន់ឬបរិមាណទំនិញ ដែលអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនដែលចេញអញ្ញត្រប័ណ្ណទំនិញ ដឹងច្បាស់ឬមានហេតុផលគ្រប់គ្រាន់សង្ស័យថា មិនត្រឹមត្រូវត្រូវបង្ហាញទំនិញដែលទទួលនោះ និងនិទ្ទេសនៅក្នុងអញ្ញត្រប័ណ្ណទំនិញនោះ ហើយប្រសិនបើមិនមានមធ្យោបាយគ្រប់គ្រាន់ដើម្បីពិនិត្យអំពីនិទ្ទេសដែលសង្ស័យនោះទេ អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនត្រូវសរសេរបញ្ចូលនៅក្នុងអញ្ញត្រប័ណ្ណទំនិញនូវសិទ្ធិបម្រុងដែលបញ្ជាក់អំពីភាពមិនត្រឹមត្រូវទាំងនេះ អំពីមូលបទនៃការសង្ស័យ ឬអំពីអវត្តមាននៃមធ្យោបាយដែលអាចត្រួតពិនិត្យមើលបាន។

ប្រសិនបើអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនដែលផ្តល់អញ្ញត្រប័ណ្ណ ខកខានកត់សម្គាល់លើអញ្ញត្រប័ណ្ណទំនិញអំពីលក្ខណៈខាងក្រៅនៃទំនិញ ត្រូវចាត់ទុកថាបានធ្វើកំណត់សម្គាល់រួចរាល់ ហើយលក្ខណៈខាងក្រៅនៃទំនិញ ត្រូវចាត់ទុកថាស្ថិតក្នុងស្ថានភាពល្អ។

លើកលែងតែបានដាក់បញ្ចូលនូវនិទ្ទេសដែលបានអនុញ្ញាតឱ្យមានសិទ្ធិបម្រុងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ទើប៖

ក- អញ្ញត្រប័ណ្ណទំនិញ ត្រូវចាត់ទុកជាភស្តុតាងដើមនៃការទទួលទំនិញ ឬបញ្ជាក់ថាទំនិញបានផ្ទុកនៅលើនាវា ដោយអ្នកដឹកជញ្ជូន ដូចកំណត់នៅក្នុងអញ្ញត្រប័ណ្ណទំនិញនោះ។

ខ- ភស្តុតាងផ្ទុយដែលធ្វើឡើងដោយអ្នកដឹកជញ្ជូន មិនត្រូវបានអនុញ្ញាតឡើយ ប្រសិនបើអញ្ញត្រប័ណ្ណទំនិញត្រូវបានផ្ទេរទៅអ្នកទទួលទំនិញ ជាអ្នកដែលត្រូវអនុវត្តតាមអញ្ញត្រប័ណ្ណទំនិញនោះ។

អញ្ញត្រប័ណ្ណទំនិញតាមនិទ្ទេសដូចមានចែងនៅក្នុងចំណុចទី១១ កថាខណ្ឌទី២ មាត្រា១៥១នៃច្បាប់នេះ មិនកំណត់ថ្លៃឈ្នួលឬបង្ហាញអំពីថ្លៃឈ្នួលដែលត្រូវបង់ដោយអ្នកទទួលទំនិញនោះឡើយ ឬមិនកំណត់ថ្លៃឈ្នួលបន្ថែមដែលកើតឡើងនៅកំពង់ផែផ្ទុកទំនិញដែលត្រូវបង់ដោយអ្នកទទួលទំនិញផងដែរ ហើយត្រូវទុកជាភស្តុតាងដើម ដែលបញ្ជាក់ថា ពុំមានការបង់ថ្លៃឈ្នួលឬថ្លៃឈ្នួលបន្ថែមដែលត្រូវបង់ដោយអ្នកផ្ញើទំនិញនោះ។ ភស្តុតាងផ្ទុយ ដែលធ្វើឡើងដោយអ្នកដឹកជញ្ជូន មិនត្រូវបានអនុញ្ញាតឡើយ នៅពេលដែលអញ្ញត្រប័ណ្ណត្រូវបានផ្ទេរទៅអ្នកទទួលទំនិញ ជាអ្នកដែលត្រូវអនុវត្តអញ្ញត្រប័ណ្ណទំនិញនោះ។

**មាត្រា១៦៤ .-**

អ្នកផ្ញើទំនិញត្រូវធានាចំពោះអ្នកដឹកជញ្ជូន នូវភាពត្រឹមត្រូវនៃនិទ្ទេស ដែលពាក់ព័ន្ធនឹងលក្ខណៈទូទៅនៃទំនិញ ស្លាកសញ្ញាសម្គាល់អត្តសញ្ញាណទំនិញ ចំនួនកញ្ចប់ឬដុំ ទម្ងន់ឬបរិមាណទំនិញ ដែលបានផ្តល់ឱ្យដោយអ្នកផ្ញើទំនិញ សម្រាប់ដាក់បញ្ចូលនៅក្នុងអញ្ញត្រប័ណ្ណទំនិញ។ អ្នកផ្ញើទំនិញ ត្រូវបង់សំណងជានារ៉ាប់រងតតិយជនទៅអ្នកដឹកជញ្ជូន សម្រាប់ការបាត់បង់ដែលបណ្តាលមកពីភាពមិនត្រឹមត្រូវនៃនិទ្ទេសទាំងនោះ។ អ្នកផ្ញើទំនិញនៅតែទទួលខុសត្រូវចំពោះការបាត់បង់នេះ ទោះបីជាអញ្ញត្រប័ណ្ណទំនិញត្រូវបានផ្ទេរដោយអ្នកផ្ញើទំនិញក៏ដោយ។ គ្រប់ករណីទាំងអស់ សិទ្ធិរបស់អ្នកដឹកជញ្ជូនលើសំណងជានារ៉ាប់រងតតិយជនមិនកំណត់ព្រំដែនសំណងរបស់អ្នកដឹកជញ្ជូន ដូចមានចែងនៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ ចំពោះបុគ្គលណាមួយ ក្រៅពីអ្នកផ្ញើទំនិញឡើយ។

លិខិតធានាឬការព្រមព្រៀងគ្នា ដែលក្នុងនោះ អ្នកផ្ញើទំនិញ ទទួលរ៉ាប់រងបង់សំណងតតិយជនទៅអ្នកដឹកជញ្ជូនលើការបាត់បង់ដែលបណ្តាលមកពីការចេញអញ្ញត្រប័ណ្ណទំនិញ ដោយមិនបានបញ្ចូលនូវសិទ្ធិបម្រុងទាក់ទងនឹងនិទ្ទេសដែលបានផ្តល់ឱ្យដោយអ្នកផ្ញើទំនិញ ឬសិទ្ធិបម្រុងទាក់ទងនឹងលក្ខណៈខាងក្រៅនៃទំនិញនៅក្នុងអញ្ញត្រប័ណ្ណទំនិញ ត្រូវចាត់ទុកជាមោឃៈនិងមិនមានប្រសិទ្ធភាពអនុវត្តចំពោះអ្នកទទួលទំនិញដែលបានទទួលអញ្ញត្រប័ណ្ណទំនិញ ជាអ្នកដែលត្រូវអនុវត្តតាមអញ្ញត្រប័ណ្ណទំនិញនោះ។

លិខិតធានាឬការព្រមព្រៀងគ្នាដូចមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ មានសុពលភាពចំពោះអ្នកផ្ញើទំនិញបាន ប្រសិនបើអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន មានចេតនាលុបលាងកំហុសដោយបញ្ជាក់អំពីការលុបចោលសិទ្ធិបម្រុងដូចមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ ទៅអ្នកទទួលទំនិញ ជាអ្នកដែលត្រូវអនុវត្តតាមអញ្ញត្រប័ណ្ណទំនិញនោះ។ ករណីនេះ ប្រសិនបើសិទ្ធិបម្រុងដែលបានលុបចោលនោះទាក់ទងនឹងនិទ្ទេសដែលបានផ្តល់ឱ្យដោយអ្នកផ្ញើទំនិញសម្រាប់បញ្ចូលនៅក្នុងអញ្ញត្រប័ណ្ណទំនិញ អ្នកដឹកជញ្ជូនមិនមានសិទ្ធិទទួលសំណងពីអ្នកផ្ញើទំនិញ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះឡើយ។

ក្នុងករណីលុបលាងកំហុសដោយចេតនា ដូចមានចែងនៅក្នុងកថាខណ្ឌទី៣ខាងលើនេះ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះការបាត់បង់ដែលកើតឡើងដោយអ្នកទទួលទំនិញ ដោយគ្មានផលប្រយោជន៍ណាមួយពីព្រំដែនសំណងដូចមានចែងនៅក្នុងច្បាប់នេះឡើយ ដោយហេតុថា អ្នកទទួលទំនិញបានអនុវត្តតាមអញ្ញត្រប័ណ្ណទំនិញនោះ។

**មាត្រា១៦៥ .-**

នៅពេលអ្នកដឹកជញ្ជូនចេញឯកសារក្រៅពីអញ្ញត្រប័ណ្ណទំនិញ ដែលបញ្ជាក់អំពីការទទួលទំនិញដើម្បីដឹកជញ្ជូន ឯកសារនោះ ត្រូវចាត់ទុកជាភស្តុតាងដើមនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ និងទទួលយកដោយអ្នកដឹកជញ្ជូននូវទំនិញដូចបានបរិយាយនៅក្នុងឯកសារនោះ។

**មាត្រា១៦៦ .-**

ប្រសិនបើអ្នកទទួលទំនិញ បានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបាត់បង់ឬការខូចខាតដោយបញ្ជាក់នូវលក្ខណៈទូទៅនៃទំនិញដែលបានបាត់បង់ឬខូចខាតនោះទៅអ្នកដឹកជញ្ជូន ក្នុងរយៈពេលមិនយឺតជាងថ្ងៃដែលបានប្រគល់ទំនិញ ការប្រគល់ទំនិញនោះចាត់ទុកជាភស្តុតាងដើមនៃការប្រគល់ទំនិញដោយអ្នកដឹកជញ្ជូន ដូចបានបរិយាយនៅក្នុងឯកសារដឹកជញ្ជូន។ ក្នុងករណីខកខានបញ្ជាក់ ត្រូវចាត់ទុកថាទំនិញដែលបានដឹកជញ្ជូន ស្ថិតក្នុងស្ថានភាពល្អ។

នៅពេលណាការបាត់បង់ឬការខូចខាត មិនអាចមើលឃើញបាន បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះត្រូវយកមកអនុវត្ត ហើយក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃជាប់ៗគ្នា បន្ទាប់ពីថ្ងៃប្រគល់ទំនិញ អ្នកទទួលទំនិញមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបាត់បង់ឬការខូចខាតនោះទៅអ្នកដឹកជញ្ជូនទេ ចាត់ទុកថាទំនិញដែលបានដឹកជញ្ជូន ស្ថិតនៅក្នុងស្ថានភាពល្អ។

ប្រសិនបើទំនិញបានប្រគល់ទៅអ្នកទទួលទំនិញ ដោយបានត្រួតពិនិត្យរួមគ្នាដោយភាគីពាក់ព័ន្ធរួចហើយ មិនមានការចាំបាច់ជូនដំណឹងអំពីការបាត់បង់ឬការខូចខាតក្នុងកំលុងពេលត្រួតពិនិត្យនោះទេ។

ក្នុងករណីមានការបាត់បង់ឬការខូចខាតជាក់ស្ដែង ឬនៅមានមន្ទិលអំពីការបាត់បង់ឬការខូចខាត អ្នកដឹកជញ្ជូននិងអ្នកទទួលទំនិញ ត្រូវសម្របសម្រួលគ្នាដើម្បីត្រួតពិនិត្យនិងរាប់ទំនិញ។

គ្មានការសងទូទាត់ណាមួយត្រូវបានធ្វើឡើងចំពោះការបាត់បង់ដែលបណ្ដាលមកពីការយឺតយ៉ាវប្រគល់ទំនិញនោះទេ លើកលែងតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដឹកជញ្ជូនក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃជាប់ៗគ្នា បន្ទាប់ពីថ្ងៃដែលទំនិញបានប្រគល់ទៅអ្នកទទួលទំនិញ។

ប្រសិនបើទំនិញត្រូវបានប្រគល់ដោយអ្នកដឹកជញ្ជូនបន្ត ការជូនដំណឹងជាលាយលក្ខណ៍អក្សរដូចមានចែងនៅក្នុងកថាខណ្ឌខាងលើនេះ ទៅអ្នកដឹកជញ្ជូនបន្ត ត្រូវមានប្រសិទ្ធភាពអនុវត្តដូចគ្នានឹងការជូនដំណឹងទៅអ្នកដឹកជញ្ជូន។ ករណីដូចគ្នានេះដែរ ការជូនដំណឹងទៅអ្នកដឹកជញ្ជូន ត្រូវមានប្រសិទ្ធភាពអនុវត្តដូចគ្នាផងដែរ នឹងការជូនដំណឹងទៅអ្នកដឹកជញ្ជូនបន្ត។

លើកលែងតែ អ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត បានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបាត់បង់ឬការខូចខាត ដោយបញ្ជាក់នូវលក្ខណៈទូទៅនៃទំនិញដែលបានបាត់បង់ឬខូចខាតនោះ ទៅអ្នកផ្ញើទំនិញ ក្នុងរយៈពេលមិនលើសពី៩០(កៅសិប)ថ្ងៃជាប់ៗគ្នា បន្ទាប់ពីថ្ងៃកើតមានការបាត់បង់ឬការខូចខាត ឬបន្ទាប់ពីបានប្រគល់ទំនិញ អនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១៥២នៃច្បាប់នេះ ដោយកំណត់យកកាលបរិច្ឆេទណាមួយដែលនៅក្រោយគេ ទើបការខកខានជូនដំណឹងនោះ ចាត់ទុកជាភស្តុតាងដើមដែលបញ្ជាក់ថា អ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត បានទទួលទំនិញដោយមិនមានការបាត់បង់ឬការខូចខាតទំនិញដោយសារកំហុសឬការធ្វេសប្រហែសរបស់អ្នកផ្ញើទំនិញឬបុគ្គលក្នុងនាមអ្នកផ្ញើទំនិញឡើយ។

ការជូនដំណឹងទៅបុគ្គលក្នុងនាមអ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត រួមទាំងនាយនាវា ឬបរិបាលនាវា ឬនាយទទួលបន្ទុកនាវា ឬទៅបុគ្គលក្នុងនាមអ្នកផ្ញើទំនិញ ត្រូវចាត់ទុកថាបានជូនដំណឹងទៅអ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត ឬអ្នកផ្ញើទំនិញ។

**មាត្រា១៦៧ .-**

បណ្ដឹងទាមទារសំណង ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញ ដូចមានចែងនៅក្នុងច្បាប់នេះ ត្រូវមានអាជ្ញាយុកាល២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃកំណត់ដែលអ្នកដឹកជញ្ជូនត្រូវប្រគល់ទំនិញ។

**មាត្រា១៦៨ .-**

បណ្ដឹងទាមទារសំណងលើការបាត់បង់ឬការខូចខាតទំនិញ ត្រូវធ្វើឡើងទៅតុលាការមានសមត្ថកិច្ច ស្របតាមការកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

នៅក្នុងអង្គហេតុដែលមានដើមបណ្ដឹងច្រើន ដើមបណ្ដឹងនីមួយៗត្រូវប្ដឹងទាមទារសំណងលើការបាត់បង់ឬការខូចខាតទំនិញ នៅចំពោះមុខតុលាការដែលបានទទួលចាត់ការពាក្យបណ្ដឹងទាមទារសំណងពីភាគីណាមួយ។ ក្នុងករណីដែលមានតុលាការផ្សេងបានទទួលពាក្យបណ្ដឹងទាមទារនេះ តុលាការនេះត្រូវផ្ទេរសំណុំរឿងមកតុលាការដែលកំពុងចាត់ការលើពាក្យបណ្ដឹងទាមទារសំណងរបស់ភាគីណាមួយនោះ។

បណ្ដឹងឧបាស្រ័យ ត្រូវធ្វើឡើងចំពោះមុខតុលាការដែលមានយុត្តាធិការលើបណ្ដឹងដំបូង ស្របតាមបញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

**មាត្រា១៦៩ .-**

គូភាគីអាចព្រមព្រៀងគ្នាជ្រើសរើសតុលាការ ឬមជ្ឈត្តការ ឬយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ទាំងនៅក្នុងប្រទេសឬនៅបរទេស ដើម្បីដោះស្រាយវិវាទរបស់ខ្លួន។ ការព្រមព្រៀងនេះ មិនរារាំងដល់សិទ្ធិរបស់តតិយជនក្នុងការប្ដឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានោះទេ។

កាលណាកិច្ចសន្យាដឹកជញ្ជូនទំនិញ មានចែងឧសន្យាដែលថា វិវាទដែលកើតឡើងរវាងភាគី ត្រូវដោះស្រាយតាមតុលាការ ឬមជ្ឈត្តការ ឬយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ហើយអញ្ញត្រប័ណ្ណទំនិញ ដែលបានផ្ដល់ឱ្យស្របតាមកិច្ចសន្យានេះ មិនចែងអំពីកំណត់សម្គាល់នោះ អ្នកដឹកជញ្ជូនមិនអាចប្រើឧសន្យានោះបានទេ ដោយត្រូវអនុវត្តតាមអញ្ញត្រប័ណ្ណទំនិញនោះ។

**មាត្រា១៧០ .-**

ឧសន្យានៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ ឬនៅក្នុងអញ្ញត្រប័ណ្ណទំនិញ ឬឯកសារណាមួយ ដែលបញ្ជាក់ភស្តុតាងនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើឧសន្យានោះ ប្រាសចាកដោយផ្ទាល់ឬដោយប្រយោលពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់នេះ។ ឧសន្យាដែលចាត់ទុកជាមោឃៈ មិនប៉ះពាល់ដល់សុពលភាពនៃកិច្ចសន្យានោះឡើយ។

ទោះបីជាមានបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី១ ក៏អ្នកដឹកជញ្ជូនអាចបង្កើនការទទួលខុសត្រូវ និងកាតព្វកិច្ច ដូចមានចែងនៅក្នុងច្បាប់នេះផងដែរ។

នៅពេលណាចេញអញ្ញត្រប័ណ្ណទំនិញឬឯកសារដែលបញ្ជាក់ភស្តុតាងអំពីកិច្ចសន្យាដឹកជញ្ជូនទំនិញ ឯកសារនោះ ត្រូវមានសេចក្ដីបញ្ជាក់ដែលបញ្ជាក់ថា ការដឹកជញ្ជូនត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ហើយត្រូវចាត់ទុកជាមោឃៈនូវឧសន្យាដែលប្រាសចាក ដើម្បីចៀសវាងផលប៉ះពាល់ដល់អ្នកផ្ញើទំនិញ និងអ្នកទទួលទំនិញ។

នៅពេលណាដើមបណ្ដឹងបានប្ដឹងអំពីការបាត់បង់ទំនិញ ដែលបណ្ដាលមកពីឧសន្យាដែលចាត់ទុកជាមោឃៈ ឬដែលបណ្ដាលមកពីកំហុសដែលមាននៅក្នុងសេចក្ដីបញ្ជាក់ អ្នកដឹកជញ្ជូនត្រូវសងការបាត់បង់ ឬការខូចខាតទំនិញ ឬការយឺតយ៉ាវប្រគល់ទំនិញ។

**មាត្រា១៧១ .-**

បទប្បញ្ញត្តិនៃច្បាប់នេះ មិនប៉ះពាល់ដល់ការអនុវត្តឧសន្យានៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញពាក់ព័ន្ធនឹងការគិតថ្លៃសំណងរួមលើការខាតបង់ ឬការកំណត់ប្រាក់លាភការសម្រាប់ការជួយសង្គ្រោះនាវាក្នុងគ្រោះថ្នាក់នាវាចរណ៍ឡើយ។

**មាត្រា១៧២ .-**

បទប្បញ្ញត្តិនៃច្បាប់នេះ មិនកែប្រែសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត និងបុគ្គលក្នុងនាមអ្នកដឹកជញ្ជូននិងអ្នកដឹកជញ្ជូនបន្ត ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិឬច្បាប់ជាតិដែលពាក់ព័ន្ធនឹងព្រំដែនសំណងរបស់ម្ចាស់នាវា។

បញ្ញត្តិនៃមាត្រា១៦៩ និងមាត្រា១៧០នៃច្បាប់នេះ មិនត្រូវប៉ះពាល់ដល់ការអនុវត្តបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់អន្តរជាតិផ្សេងទៀតជាធរមាន ហើយច្បាប់អន្តរជាតិផ្សេងទៀតនោះក៏មិនត្រូវប៉ះពាល់ដល់ការអនុវត្តកថាខណ្ឌទី៤ មាត្រា១៧០នៃច្បាប់នេះដែរ។

អ្នកដឹកជញ្ជូនមិនទទួលខុសត្រូវសងចំពោះការខូចខាតដែលបង្កឡើងដោយឧប្បត្តិហេតុនុយក្លេអ៊ែ ប្រសិនបើប្រតិបត្តិករនៃបេនាការនុយក្លេអ៊ែលើនាវា បានទទួលខុសត្រូវសងដោយអនុលោមតាមច្បាប់អន្តរជាតិ ឬច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី២
## ការដឹកជញ្ជូនអ្នកដំណើរនិងការវត្ថុ

**មាត្រា១៧៣ .-**

ការដឹកជញ្ជូនអ្នកដំណើរ រួមនិងការវត្ថុរបស់អ្នកដំណើរ តាមនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស ឬនាវាសញ្ជាតិខ្មែរ ត្រូវធ្វើឡើងតាមកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ។

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះព្យសនកម្មលើការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬការខូចខាតឬការបាត់បង់ការវត្ថុរបស់អ្នកដំណើរតាមកិច្ចសន្យាដឹកជញ្ជូនដែលខ្លួនបានដឹកជញ្ជូន ទោះបីជាយកថ្លៃឈ្នួលឬមិនយកថ្លៃឈ្នួលក៏ដោយ។

**មាត្រា១៧៤ .-**

សំបុត្រអ្នកដំណើរ ត្រូវបញ្ចូលនូវនិទ្ទេសសំខាន់ៗដូចខាងក្រោម៖

- ឈ្មោះនាវា លេខសម្គាល់នាវា
- ឈ្មោះរបស់អ្នកដំណើរ អាសយដ្ឋានបច្ចុប្បន្នរបស់អ្នកដំណើរ
- ការវត្ថុរបស់អ្នកដំណើរ
- លេខកៅអីឬកន្លែងអង្គុយ
- កំពង់ផែចេញដំណើរ កំពង់ផែគោលដៅ កាលបរិច្ឆេទចេញដំណើរ និងកាលបរិច្ឆេទមកដល់។

សំបុត្រអ្នកដំណើរ ត្រូវចុះហត្ថលេខាដោយអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន និងមានកាលបរិច្ឆេទច្បាស់លាស់។

**មាត្រា១៧៥ .-**

អ្នកដឹកជញ្ជូនត្រូវសងចំពោះព្យសនកម្ម ដែលបណ្តាលឱ្យមានការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ និងការបាត់បង់ឬការខូចខាតការវត្ថុរបស់អ្នកដំណើរ ប្រសិនបើឧប្បត្តិហេតុនោះអាចកើតចេញពីកំហុសឬការធ្វេសប្រហែសរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន ក្នុងកំលុងពេលដឹកជញ្ជូន។

អ្នកដែលបញ្ជាក់ភស្តុតាងថា ឧប្បត្តិហេតុដែលបង្កឱ្យមានការបាត់បង់ឬការខូចខាត ដែលបានកើតឡើងនៅក្នុងកំលុងពេលដឹកជញ្ជូន រួមនិងទំហំនៃការបាត់បង់ឬការខូចខាតនោះ ត្រូវបញ្ជាក់ដោយអ្នកប្តឹង។

កំហុសឬការធ្វេសប្រហែសរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួន ត្រូវចាត់ទុកថាបានកើតឡើង ប្រសិនបើគ្មានភស្តុតាងផ្ទុយដែលបញ្ជាក់ថា ការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬការបាត់បង់ឬការខូចខាតការវត្ថុរបស់អ្នកដំណើរ បណ្តាលមកពីមូលហេតុដែលជាប់ពាក់ព័ន្ធនឹងការបាក់បែកការប៉ះទង្គិច ការកឿង ការកើល ការផ្ទុះ ឬឆេះនាវា។

**មាត្រា១៧៦ .-**

អ្នកដឹកជញ្ជូននៅតែទទួលខុសត្រូវសងចំពោះការដឹកជញ្ជូនដដែល ទោះបីជាការអនុវត្តដឹកជញ្ជូននោះ ត្រូវបានប្រគល់ទៅអ្នកដឹកជញ្ជូនបន្តក៏ដោយ។

ករណីការប្រគល់ការអនុវត្តដឹកជញ្ជូន ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវសងចំពោះអំពើឬកំហុសដែលបានប្រព្រឹត្តដោយអ្នកដឹកជញ្ជូនបន្ត។

**មាត្រា១៧៧ .-**

អ្នកដឹកជញ្ជូនមិនទទួលខុសត្រូវសងចំពោះការបាត់បង់ឬការខូចខាតរូបិយបណ្ណ មូលប្បទានបត្រដែលអាចចរាចរបាន មាស ប្រាក់ ពេជ្រ ត្បូង ឬវត្ថុសិល្បៈ ឬវត្ថុមានតម្លៃផ្សេងៗឡើយ លើកលែងតែមានការប្រកាសអំពីចំនួននិងតម្លៃ និងមានការប្រគល់ដែលយល់ព្រមទទួលដោយអ្នកដឹកជញ្ជូន ក្នុងគោលបំណងរក្សាទុកនៅលើនាវាក្នុងកំលុងពេលដឹកជញ្ជូន។

**មាត្រា១៧៨ .-**

ប្រសិនបើអ្នកដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថា ការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬការបាត់បង់ឬការខូចខាតការវត្ថុអ្នកដំណើរ បានបង្កឡើងដោយឬរួមចំណែកដោយកំហុសឬការធ្វេសប្រហែសរបស់អ្នកដំណើរ អ្នកដឹកជញ្ជូនអាចរួចផុតពីការទទួលខុសត្រូវសងទាំងស្រុងឬដោយផ្នែក។

**មាត្រា១៧៩ .-**

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ មិនត្រូវលើសពី៤៦ ៦៦៦SDR (សែសិបប្រាំមួយពាន់ប្រាំមួយរយហុកសិបប្រាំមួយអេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ក្នុងមួយជើង។

**មាត្រា១៨០ .-**

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតការវត្ថុជាប់ខ្លួន មិនត្រូវលើសពី៨៣៣SDR (ប្រាំបីរយសាមសិបបីអេសដេអ៊ែ) សម្រាប់អ្នកដំណើរម្នាក់ក្នុងមួយជើង។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតរថយន្ត រួមទាំងការវត្ថុនៅលើរថយន្តនោះ មិនត្រូវលើសពី៣ ៣៣៣SDR (បីពាន់បីរយសាមសិបបីអេសដេអ៊ែ) ក្នុងរថយន្តមួយគ្រឿង ក្នុងមួយជើង។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយគូភាគី សំណងរបស់អ្នកដឹកជញ្ជូនចំពោះការបាត់បង់ឬការខូចខាតការវត្ថុផ្សេងទៀតរបស់អ្នកដំណើរក្រៅពីការវត្ថុដូចមានចែងនៅក្នុងកថាខណ្ឌទី១និងទី២ខាងលើនេះ មិនត្រូវលើសពី១ ២០០SDR (មួយពាន់ពីររយអេសដេអ៊ែ) ក្នុងអ្នកដំណើរម្នាក់ ក្នុងមួយជើង។

**មាត្រា១៨១ .-**

អេសដេអ៊ែ ដូចមានចែងនៅក្នុងច្បាប់នេះ ត្រូវប្តូរជារូបិយបណ្ណដែលត្រូវអនុវត្តនៅតាមតុលាការមានសមត្ថកិច្ច ផ្អែកលើតម្លៃកំណត់ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ។

**មាត្រា១៨២ .-**

អ្នកដឹកជញ្ជូននិងអ្នកដំណើរ អាចយល់ព្រមជាលាយលក្ខណ៍អក្សរលើសំណាងរបស់អ្នកដឹកជញ្ជូន ចំពោះការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុរបស់អ្នកដំណើរ ខ្ពស់ឬទាបជាងព្រំដែនសំណាងដូចមានចែងនៅក្នុងមាត្រា១៧៩ និងមាត្រា១៨០នៃច្បាប់នេះ។

**មាត្រា១៨៣ .-**

បើមានបណ្តឹងចំពោះបុគ្គលក្នុងនាមអ្នកដឹកជញ្ជូន ឬអ្នកដឹកជញ្ជូនបន្ត ដើម្បីទាមទារសំណង ដូចមានចែងនៅក្នុងច្បាប់នេះ បុគ្គលនោះមានសិទ្ធិការពារខ្លួនក្នុងព្រំដែនសំណាងរបស់អ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត ប្រសិនបើខ្លួនមានភស្តុងតាងបញ្ជាក់ថាបានធ្វើការងារក្នុងនាមអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត។

**មាត្រា១៨៤ .-**

ព្រំដែនសំណាងដូចមានចែងនៅក្នុងមាត្រា១៧៩និងមាត្រា១៨០នៃច្បាប់នេះ មានប្រសិទ្ធភាពអនុវត្តព្រំដែនសំណាងនេះ ត្រូវជាចំនួនបូកសរុបនៃបណ្តឹងទាមទារសំណាងទាំងអស់ ដែលបានកើតឡើងចំពោះការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុ សម្រាប់អ្នកដំណើរម្នាក់ នៅកន្លែងដែលព្រំដែនសំណាងនោះត្រូវបានអនុវត្ត។

ករណីការដឹកជញ្ជូនត្រូវបានអនុវត្តដោយអ្នកដឹកជញ្ជូនបន្ត ចំនួនបូកសរុបសំណាងពីអ្នកដឹកជញ្ជូន និងអ្នកដឹកជញ្ជូនបន្ត ព្រមទាំងពីបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្ត មិនត្រូវលើសពីចំនួនដែលត្រូវផ្តល់ឱ្យទោះបីជាឱ្យទៅអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្តឡើយ។

គ្រប់ករណីដែលបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្ត បានទទួលសិទ្ធិដូចមានចែងនៅក្នុងមាត្រា១៨៣នៃច្បាប់នេះ ដើម្បីទទួលសិទ្ធិការពារខ្លួនក្នុងព្រំដែនសំណាងដូចមានចែងនៅក្នុងមាត្រា១៧៩ និងមាត្រា១៨០នៃច្បាប់នេះ ចំនួនបូកសរុបសំណាងពីអ្នកដឹកជញ្ជូន អ្នកដឹកជញ្ជូនបន្ត និងបុគ្គលក្នុងនាមអ្នកដឹកជញ្ជូនបន្តមិនត្រូវលើសពីព្រំដែនសំណាងឡើយ។

**មាត្រា១៨៥ .-**

អ្នកដឹកជញ្ជូនមិនមានសិទ្ធិទទួលអត្ថប្រយោជន៍ណាមួយពីព្រំដែនសំណាងដូចមានចែងនៅក្នុងមាត្រា១៧៩ មាត្រា១៨០ និងមាត្រា១៨២នៃច្បាប់នេះឡើយ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា ការខូចខាតនោះបានបណ្តាលមកពីអំពើឬកំហុសរបស់អ្នកដឹកជញ្ជូន ក្នុងគោលបំណងបង្កឱ្យមានការខូចខាត ឬដោយធ្វេសប្រហែសដោយដឹងច្បាស់ថា លទ្ធផលនៃការខូចខាតនឹងកើតមាន។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះនិយោជិតឬភ្នាក់ងាររបស់អ្នកដឹកជញ្ជូន ឬអ្នកដឹកជញ្ជូនបន្ត ដែលបានអនុវត្តដឹកជញ្ជូនក្នុងនាមអ្នកដឹកជញ្ជូនឬអ្នកដឹកជញ្ជូនបន្ត។

**មាត្រា១៨៦ .-**

អ្នកដំណើរត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួនដូចខាងក្រោម៖

ក- ករណីមើលឃើញការខូចខាតភារវត្ថុ៖

សម្រាប់ភារវត្ថុជាប់ខ្លួន នៅមុនឬនៅពេលអ្នកដំណើរចុះពីនាវា

សម្រាប់ភារវត្ថុផ្សេងទៀត នៅមុនឬនៅពេលប្រគល់ភារវត្ថុម្តងទៀត។

ខ- ករណីខូចខាតភារវត្ថុដែលមិនអាចមើលឃើញបាន ឬបាត់បង់ភារវត្ថុ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃគិតពីថ្ងៃអ្នកដំណើរចុះពីនាវា ឬថ្ងៃប្រគល់ភារវត្ថុម្តងទៀត ឬពេលវេលាដែលភារវត្ថុគួរត្រូវបានប្រគល់ម្តងទៀត។

ការខកខានអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ចាត់ទុកថាអ្នកដំណើរបានទទួលភារវត្ថុដោយមិនមានការខូចខាតឬមិនមានការបាត់បង់។

ការជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មិនចាំបាច់ផ្តល់ឡើយប្រសិនបើលក្ខណៈនៃភារវត្ថុដែលបានទទួលនៅពេលទទួលភារវត្ថុ ដោយមានការត្រួតពិនិត្យរួមគ្នា។

**មាត្រា១៨៧ .-**

បណ្តឹងទាមទារសំណង ដែលបានកើតឡើងចំពោះការរងរបួសឬការបាត់បង់ជីវិតអ្នកដំណើរ ឬចំពោះការបាត់បង់ឬការខូចខាតភារវត្ថុអ្នកដំណើរ ត្រូវមានអាជ្ញាយុកាលរយៈពេល៣(បី)ឆ្នាំ។

រយៈពេលអាជ្ញាយុកាល ត្រូវគណនាដូចខាងក្រោម៖

ក- ករណីរងរបួស ត្រូវគិតចាប់ពីកាលបរិច្ឆេទដែលអ្នកដំណើរចុះចេញពីនាវា។

ខ- ករណីបាត់បង់ជីវិតដែលបានកើតឡើងក្នុងកំលុងពេលដឹកជញ្ជូន ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការបាត់បង់ជីវិត។

គ- ក្នុងករណីរងរបួសដែលបានកើតឡើង ក្នុងកំលុងពេលដឹកជញ្ជូន និងបណ្តាលឱ្យបាត់បង់ជីវិតក្រោយពេលចុះចេញពីនាវា ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការបាត់បង់ជីវិត។

ឃ- ករណីបាត់បង់ឬខូចខាតភារវត្ថុ ត្រូវគិតចាប់ពីកាលបរិច្ឆេទដែលអ្នកដំណើរចុះចេញពីនាវា ឬកាលបរិច្ឆេទដែលអ្នកដំណើរគួរត្រូវបានចុះចេញពីនាវា ដោយអាចកំណត់យកកាលបរិច្ឆេទណាមួយដែលនៅចុងក្រោយបង្អស់។

អាជ្ញាយុកាលដែលបានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ត្រូវមានរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការកើតឡើងនូវឧប្បត្តិហេតុ ក្នុងករណីដែលកាលបរិច្ឆេទនៃការបាត់បង់ជីវិតមិនអាចកំណត់បាន។

**មាត្រា១៨៨ .-**

បណ្តឹងទាមទារសំណងលើការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុអ្នកដំណើរ ត្រូវធ្វើឡើងទៅតុលាការមានសមត្ថកិច្ច ស្របតាមការកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

នៅក្នុងអង្គហេតុដែលមានដើមបណ្តឹងច្រើន ដើមបណ្តឹងនីមួយៗ ត្រូវប្តឹងទាមទារសំណងលើការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុអ្នកដំណើរនៅចំពោះមុខតុលាការដែលបានទទួលចាត់ការពាក្យបណ្តឹងទាមទារសំណងពីភាគីណាមួយ។ ក្នុងករណីដែលមានតុលាការផ្សេងបានទទួលពាក្យបណ្តឹងទាមទារនេះ តុលាការនេះត្រូវផ្ទេរសំណុំរឿងមកតុលាការដែលកំពុងចាត់ការលើពាក្យបណ្តឹងទាមទារសំណងរបស់ភាគីណាមួយនោះ។

បណ្តឹងឧបាស្រ័យ ត្រូវធ្វើឡើងនៅចំពោះមុខតុលាការដែលមានយុត្តាធិការលើបណ្តឹងដំបូង ស្របតាមបញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

ក្រោយការកើតឡើងនូវឧប្បត្តិហេតុដែលបង្កឱ្យមានព្យសនកម្ម គូភាគីអាចព្រមព្រៀងគ្នាជ្រើសរើសតុលាការ ឬមជ្ឈត្តការ ឬយន្តការដោះស្រាយវិវាទណាមួយផ្សេងទៀត ទាំងនៅក្នុងប្រទេសឬនៅបរទេសដើម្បីដោះស្រាយវិវាទរបស់ខ្លួន។ ការព្រមព្រៀងនេះ មិនរារាំងដល់សិទ្ធិរបស់តតិយជនក្នុងការប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានោះទេ។

**មាត្រា១៨៩ .-**

ប្រការនៃកិច្ចសន្យាដឹកជញ្ជូននិងភារវត្ថុអ្នកដំណើរ ដែលបានធ្វើឡើងនៅមុនពេលកើតឡើងនៃឧប្បត្តិហេតុ ដែលបង្កឱ្យមានការរងរបួសឬការបាត់បង់ជីវិត ឬការបាត់បង់ឬការខូចខាតភារវត្ថុ ដោយឱ្យ

អ្នកដឹកជញ្ជូនរួចផុតពីការផ្តល់សំណងទៅអ្នកដំណើរ ឬដោយផ្តល់សំណងទាបជាងព្រំដែនសំណងដូចមានចែងនៅក្នុងច្បាប់នេះ ឬផ្ទេរបន្ទុកភស្តុតាងដែលបានដាក់ទៅលើអ្នកដឹកជញ្ជូន ឬរឹតត្បិតលើការសម្រេចចិត្តរបស់ភាគីដូចមានចែងនៅក្នុងមាត្រា១៨៨នៃច្បាប់នេះ ត្រូវចាត់ទុកជាមោឃៈ។

ការចាត់ទុកជាមោឃៈ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មិនប៉ះពាល់ដល់សុពលភាពនៃកិច្ចសន្យារវាងភាគីឡើយ។

**មាត្រា១៩០ .-**

បទប្បញ្ញត្តិនៃច្បាប់នេះ មិនកែប្រែសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកដឹកជញ្ជូនឬបុគ្គលក្នុងនាមខ្លួនអ្នកដឹកជញ្ជូនបន្តឬបុគ្គលក្នុងនាមខ្លួន ដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ជាពិសេសពាក់ព័ន្ធនឹងព្រំដែនសំណងរបស់ម្ចាស់នាវា។

**មាត្រា១៩១ .-**

គ្មានសំណងណាមួយត្រូវបានធ្វើឡើងចំពោះការខូចខាតដែលបង្កឡើងដោយឧប្បត្តិហេតុនុយក្លេអ៊ែនោះឡើយ ប្រសិនបើប្រតិបត្តិករនៃបរិក្ខារនុយក្លេអ៊ែលើនាវា ទទួលខុសត្រូវសងចំពោះការខូចខាត តាមអនុសញ្ញាអន្តរជាតិឬច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## **ជំពូកទី១០**
## **ការគ្រប់គ្រងកំពង់ផែ**
### **ផ្នែកទី១**
### **ចំណាត់ថ្នាក់កំពង់ផែនិងអង្គគ្រប់គ្រងកំពង់ផែ**

**មាត្រា១៩២ .-**

កំពង់ផែមាន៤ថ្នាក់ ដូចខាងក្រោម៖

- ថ្នាក់ទី១ ជាកំពង់ផែសម្រាប់បម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ និងមានសក្តានុពលសេដ្ឋកិច្ចសង្គមខ្ពស់បំផុត
- ថ្នាក់ទី២ ជាកំពង់ផែសម្រាប់បម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាមួយប្រទេសជិតខាង ដែលមានកិច្ចព្រមព្រៀងដោយឡែក
- ថ្នាក់ទី៣ ជាកំពង់ផែសម្រាប់បម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ថ្នាក់ពិសេស ជាកំពង់ផែក្រៅពីកំពង់ផែក្នុងថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣។

**មាត្រា១៩៣ .-**

កំពង់ផែនីមួយៗត្រូវបង្កើតឡើងដោយផ្អែកលើនិទ្ទេសដូចមានចែងនៅក្នុងមាត្រា១៩២នៃច្បាប់នេះ និងនិទ្ទេសសំខាន់ៗផ្សេងទៀត ដូចខាងក្រោម៖

- ឈ្មោះកំពង់ផែ
- ទីតាំងភូមិសាស្ត្រ ដែលមានលក្ខណៈអំណោយផលពីធម្មជាតិ មានសក្តានុពលក្នុងប្រព័ន្ធដឹកជញ្ជូន
- កម្មវត្ថុនិងមុខងារ ដែលស្របតាមគោលបំណងនៃការបង្កើតកំពង់ផែ
- សមត្ថភាពឬទំហំកំពង់ផែដែលអាចលើកដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ
- ផែនទីមាងប្លង់រួមនិងព្រំដែនរបស់កំពង់ផែ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការបង្កើតកំពង់ផែថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ពិសេសដែលបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិឬជាមួយប្រទេសជិតខាង ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្កើតកំពង់ផែថ្នាក់ទី៣និងថ្នាក់ពិសេសដែលបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៩៤.-**

កំពង់ផែគ្រប់ថ្នាក់ត្រូវមានដែនកំពង់ផែ ដែលរួមមានដែនទឹកនិងដីគោក។

**មាត្រា១៩៥.-**

កំពង់ផែគ្រប់ថ្នាក់ត្រូវមានអង្គគ្រប់គ្រងកំពង់ផែ។

## ផ្នែកទី២
## មេបញ្ជាការផែ

**មាត្រា១៩៦.-**

កំពង់ផែថ្នាក់ទី១និងកំពង់ផែថ្នាក់ទី២ ត្រូវមានមេបញ្ជាការផែ។

មេបញ្ជាការផែត្រូវចាត់តាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិចេញសេចក្តីសម្រេចចាត់តាំងមេបញ្ជាការផែសម្រាប់កំពង់ផែផ្សេងទៀត។

មេបញ្ជាការផែត្រូវជាមន្ត្រីក្របខ័ណ្ឌរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

លក្ខណវិនិច្ឆ័យជាមេបញ្ជាការផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៩៧.-**

មេបញ្ជាការផែមានភារកិច្ចដូចខាងក្រោម៖

- រៀបចំចលនានាវាចូលចេញកំពង់ផែ
- បញ្ជាការផ្លាស់ប្តូរទីតាំងរបស់នាវានៅក្នុងដែនទឹកកំពង់ផែឬការផ្លាស់ប្តូរទីតាំងចេញទៅក្រៅដែនទឹកកំពង់ផែ
- ហាមឃាត់ រឹតត្បិត ផ្អាក ឬរារាំងសកម្មភាពទាំងឡាយនៅក្នុងកំពង់ផែ ដើម្បីធានាសុវត្ថិភាពប្រតិបត្តិការបរិបនីយកណ្ឌផែនិងនាវាទាំងឡាយ
- មានសិទ្ធិបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ
- ធ្វើការណែនាំនិងចាត់វិធានការអំពីករណីនាវាដឹកជញ្ជូនទំនិញគ្រោះថ្នាក់។

បទបញ្ជាមេបញ្ជាការផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ផ្នែកទី៣
## ការអនុញ្ញាតឱ្យនាវាចូលចេញកំពង់ផែ

**មាត្រា១៩៨.-**

មុននឹងចូលកំពង់ផែ នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ត្រូវមានលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ។

ក្នុងករណីប្រធានសក្តិ នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ក្នុងដំណើរឆ្លងកាត់ដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិចូលជ្រកនៅកំពង់ផែណាមួយឬកន្លែងណាមួយជាបណ្តោះអាសន្ន ដោយគ្រាន់តែជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត និងមិនតម្រូវឱ្យមានលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែឡើយ។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៩៩ .-**

នៅពេលចេញពីកំពង់ផែ នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ត្រូវមានលិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២០០ .-**

នាវាមិនត្រូវបានផ្តល់លិខិតអនុញ្ញាតឱ្យចេញពីកំពង់ផែ ក្នុងករណីនាវាកំពុងស្ថិតនៅក្នុងដំណើរការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យនាវាបរទេសឬនាវាកំពុងស្ថិតនៅក្នុងការបំពេញកាតព្វកិច្ចជាមួយភាគីដែលពាក់ព័ន្ធ រួមមានប្រតិបត្តិករកំពង់ផែ អ្នកផ្ញើទំនិញ អ្នកទទួលទំនិញជាអាទិ៍។

**មាត្រា២០១ .-**

ការចូលចេញកំពង់ផែ ត្រូវបានផ្តល់អាទិភាពចំពោះនាវាដែលបម្រើឱ្យការសង្គ្រោះនៅពេលមានគ្រោះអាសន្ន។

**មាត្រា២០២ .-**

កំពង់ផែនីមួយៗត្រូវទទួលឱ្យនាវាចូលបានស្របតាមថ្នាក់របស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា១៩២នៃច្បាប់នេះ។

ក្នុងករណីចាំបាច់ ក្រសួងសាធារណការនិងដឹកជញ្ជូនមានសិទ្ធិអនុញ្ញាតឱ្យនាវាចូលចេញកំពង់ផែក្នុងថ្នាក់ផ្សេងទៀត។

**មាត្រា២០៣ .-**

នាវាបរទេសនិងនាវាសញ្ជាតិខ្មែរ មិនត្រូវធ្វើការដឹកជញ្ជូនទំនិញឬអ្នកដំណើរ រវាងកំពង់ផែដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាបានឡើយ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២០៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវជំរុញរៀបចំភ្នាក់ងារនាវា ដើម្បីផ្តល់សេវាកម្មដល់នាវាចូលចេញកំពង់ផែក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

នីតិបុគ្គលឬរូបវន្តបុគ្គលដែលធ្វើជាភ្នាក់ងារនាវា ត្រូវមានលិខិតអនុញ្ញាតភ្នាក់ងារនាវា។

នីតិវិធីផ្តល់លិខិតអនុញ្ញាតភ្នាក់ងារនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២០៥ .-**

នាវាបរទេសដែលចូលចេញកំពង់ផែនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើភ្នាក់ងារនាវា ដូចមានចែងនៅក្នុងមាត្រា២០៤នៃច្បាប់នេះ។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះត្រូវបានលើកលែង ក្នុងករណីនាវាបរទេសស្ថិតនៅក្រោមការគ្រប់គ្រងនិងធ្វើប្រតិបត្តិការដោយក្រុមហ៊ុននាវាដែលមានទីស្នាក់ការក្រុមហ៊ុន សាខា ឬបុត្រសម្ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ករណីនេះ ក្រុមហ៊ុននាវាមិនមានសិទ្ធិសម្របសម្រួលផ្តល់សេវាកម្មសម្រាប់នាវារបស់ក្រុមហ៊ុននាវាផ្សេងទៀតឡើយ។

## ផ្នែកទី៤
## ការអភិវឌ្ឍ ការសាងសង់ និងប្រតិបត្តិការកំពង់ផែ

**មាត្រា២០៦ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិសម្រេចលើផែនការអភិវឌ្ឍន៍កំពង់ផែឬដំណាក់កាលនៃផែនការអភិវឌ្ឍន៍កំពង់ផែរបស់កំពង់ផែនីមួយៗស្របតាមលក្ខណវិនិច្ឆ័យដូចមានចែងនៅក្នុងផែនការកម្មកំពង់ផែ។

ផែនការកម្មកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២០៧ .-**

ការសាងសង់និង/ឬជួសជុលបបនីយកណ្ឋផែ ត្រូវមានលិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលបបនីយកណ្ឋផែ។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលបបនីយកណ្ឋផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២០៨ .-**

ការសាងសង់និងការជួសជុលបបនីយកណ្ឋផែ ត្រូវធ្វើឡើងស្របតាមបទដ្ឋានបច្ចេកទេសសាងសង់និងជួសជុលបបនីយកណ្ឋផែ។

បទដ្ឋានបច្ចេកទេសសាងសង់និងជួសជុលបបនីយកណ្ឋផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២០៩ .-**

ការធ្វើប្រតិបត្តិការបបនីយកណ្ឋផែ ត្រូវមានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការបបនីយកណ្ឋផែ។

បបនីយកណ្ឋផែដែលបានសាងសង់រួចឬផ្នែកណាមួយដែលបានសាងសង់រួច ត្រូវធានាបាននូវសុវត្ថិភាព សន្តិសុខនិងបរិស្ថាន មុនដាក់ឱ្យធ្វើប្រតិបត្តិការ។

លិខិតអនុញ្ញាតធ្វើប្រតិបត្តិការបបនីយកណ្ឋផែ មានសុពលភាព២(ពីរ)ឆ្នាំ។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការបបនីយកណ្ឋផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២១០ .-**

ប្រតិបត្តិករកំពង់ផែត្រូវមានសមត្ថភាពវិជ្ជាជីវៈដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២១១ .-**

អ្នកគ្រប់គ្រងកំពង់ផែ ត្រូវធ្វើរបាយការណ៍អំពីប្រតិបត្តិការបបនីយកណ្ឋផែមកក្រសួងសាធារណការនិងដឹកជញ្ជូន។

ទម្រង់របាយការណ៍អំពីប្រតិបត្តិការបបនីយកណ្ឌផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ផ្នែកទី៥
## សន្តិសុខនិងបរិស្ថាន

**មាត្រា២១២ ._**

កំពង់ផែត្រូវមានឋបនីយកណ្ឌទទួលសំណល់ពីនាវា។

បទដ្ឋានបច្ចេកទេសឋបនីយកណ្ឌទទួលសំណល់ពីនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២១៣ ._**

កំពង់ផែត្រូវមានផែនការបង្ការគ្រោះអាសន្នសម្រាប់ឆ្លើយតបនឹងការកំពប់ប្រេងឬសារធាតុគ្រោះថ្នាក់នៅកំពង់ផែ។

**មាត្រា២១៤ ._**

កំពង់ផែបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ត្រូវមានរបាយការណ៍វាយតម្លៃសន្តិសុខឋបនីយកណ្ឌផែ ផែនការសន្តិសុខឋបនីយកណ្ឌផែ លិខិតបញ្ជាក់សន្តិសុខឋបនីយកណ្ឌផែ នាយសន្តិសុខឋបនីយកណ្ឌផែ និងបុគ្គលិកផ្នែកសន្តិសុខឋបនីយកណ្ឌផែ។

សន្តិសុខឋបនីយកណ្ឌផែ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៦
## បទបញ្ជាស្ដីពីនាវាចរណ៍

**មាត្រា២១៥ ._**

កំពង់ផែត្រូវមានបទបញ្ជាស្ដីពីនាវាចរណ៍។

បទបញ្ជាស្ដីពីនាវាចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ផ្នែកទី៧
## ថ្លៃឈ្នួលកំពង់ផែ

**មាត្រា២១៦ ._**

កំពង់ផែត្រូវមានតារាងថ្លៃឈ្នួលដែលកំណត់ដោយអង្គគ្រប់គ្រងកំពង់ផែ។

អង្គគ្រប់គ្រងកំពង់ផែត្រូវអនុវត្តការប្រមូលថ្លៃឈ្នួលកំពង់ផែ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិកំណត់ពិដានថ្លៃឈ្នួលកំពង់ផែ ដើម្បីធានាបាននូវភាពប្រកួតប្រជែងប្រកបដោយសមធម៌។

**មាត្រា២១៧ ._**

ការបង្ខិតបង្ខំឱ្យទទួលយកសេវាកម្មកំពង់ផែនៅកំពង់ផែណាមួយ ទោះតាមរូបភាពណាក៏ដោយត្រូវហាមឃាត់។

## ផ្នែកទី៨
## ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ

**មាត្រា២១៨.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំ ដឹកនាំ និងគ្រប់គ្រងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ។

ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១
## ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក

**មាត្រា២១៩.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំ អភិវឌ្ឍ និងការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ដែលរួមមានផ្លូវនាវាចរណ៍ សំណង់សិល្បការ្យផ្លូវទឹក សញ្ញាជំនួយនាវាចរណ៍ និងប្រព័ន្ធដើម្បីទ្រទ្រង់ដល់ការធ្វើនាវាចរណ៍ ការដឹកជញ្ជូន និងកំពង់ផែ។

ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២០.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសិក្សានិងរៀបចំផែនទីផ្លូវទឹក ផែនទីនាវាចរណ៍ និងផ្សព្វផ្សាយសម្រាប់នាវាចរណ៍។

ផែនទីផ្លូវទឹកត្រូវរៀបចំឡើងសម្រាប់គោលបំណងអភិវឌ្ឍបណ្តាញផ្លូវទឹក ដោយបង្ហាញភូមិសាស្ត្ររួមនៃតំបន់ផ្លូវទឹក។

ផែនទីនាវាចរណ៍ត្រូវរៀបចំឡើងសម្រាប់គោលបំណងនាវាចរណ៍ ដោយបង្ហាញភូមិសាស្ត្រផ្លូវទឹក និងព័ត៌មានប្រកបដោយសុក្រឹតភាពសម្រាប់បម្រើការធ្វើនាវាចរណ៍ ដើម្បីជានាភាពជឿជាក់ ប្រសិទ្ធភាពបើកបរ និងចៀសវាងគ្រោះថ្នាក់នាវាចរណ៍។

**មាត្រា២២១.-**

សំណង់សិល្បការ្យនិងអង្គបណ្តែតទឹក ដែលប៉ះពាល់ឬបង្កការប៉ះពាល់ដល់សុវត្ថិភាពរបស់នាវា ក្នុងការធ្វើនាវាចរណ៍ជាប្រក្រតីនៅតាមផ្លូវនាវាចរណ៍ ត្រូវហាមឃាត់។

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទប់ស្កាត់រាល់សកម្មភាពដែលរាំងស្ទះដល់នាវាចរណ៍ ឬសកម្មភាពដែលធ្វើឱ្យនាវាចរណ៍ជួបការលំបាក ព្រមទាំងត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីចៀសវាងគ្រោះថ្នាក់។ ក្នុងករណីចាំបាច់ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា២២២.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិផ្អាកជាបណ្តោះអាសន្ននូវការធ្វើនាវាចរណ៍នៅតាមផ្លូវទឹកណាមួយ សម្រាប់គោលបំណងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

## ជំពូកទី១២
## កណ្តាជារកិច្ច

**មាត្រា២២៣.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំកណ្តាជារកិច្ចសម្រាប់នាវា ដែលធ្វើនាវាចរណ៍ឆ្លងកាត់ដែនកណ្តាជារកិច្ចបំពេញចេញកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

**មាត្រា២២៤.-**

នាវាដែលធ្វើនាវាចរណ៍នៅតាមដែនកណ្ដាជារកិច្ច ឬចូលចេញកំពង់ផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើសេវាកណ្ដាជារកិច្ច ដែលរួមមានកណ្ដាជារកិច្ចជាកាតព្វកិច្ច និងកណ្ដាជារកិច្ចមិនមែនកាតព្វកិច្ច។

**មាត្រា២២៥.-**

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច កណ្ដាជារត្រូវអនុវត្តដូចខាងក្រោម៖

- ផ្ដល់ព័ត៌មាននិងផ្ដល់យោបល់ដល់នាយនាវា អំពីស្ថានភាពដែនកណ្ដាជារកិច្ច ទីតាំងនិងវិធីដែលនាវាត្រូវចូលចត និងពិនិត្យមើលស្ថានភាពធ្វើដំណើររបស់នាវា ដែលអាចប្រព្រឹត្តទៅបានប្រកបដោយសុវត្ថិភាព
- រាយការណ៍ជាបន្ទាន់ទៅមេបញ្ជាការផែឬអាជ្ញាធរមានសមត្ថកិច្ច ករណីពិនិត្យឃើញភាពមិនប្រក្រតីពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងបរិស្ថាន នាវិកនិងមនុស្សនៅលើនាវា ទំនិញ ឬការប្រព្រឹត្តណាមួយ ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច កណ្ដាជារមានសិទ្ធិប្រើជំនួយការកណ្ដាជារមួយរូប។ កណ្ដាជាហាត់ការក៏អាចប្រើបានក្រោមការទទួលខុសត្រូវរបស់កណ្ដាជារនោះ។

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច កណ្ដាជារត្រូវស្លៀកពាក់ឯកសណ្ឋានកណ្ដាជារ។

គ្រប់ករណីនៃការធ្វើកណ្ដាជារកិច្ច នាយនាវាត្រូវទទួលខុសត្រូវទាំងស្រុងលើនាវារបស់ខ្លួន។

**មាត្រា២២៦.-**

ក្នុងកិច្ចប្រតិបត្តិការកណ្ដាជារកិច្ច នាយនាវាត្រូវផ្ដល់ព័ត៌មានអំពីលក្ខណៈចលនាចរណ៍ និងចំណុចសំខាន់ៗនៃនាវារបស់ខ្លួនពាក់ព័ន្ធនឹងកណ្ដាជារកិច្ចទៅកណ្ដាជារ។

**មាត្រា២២៧.-**

កណ្ដាជារមានសិទ្ធិបដិសេធបន្តកណ្ដាជារកិច្ច ប្រសិនបើយល់ឃើញថា ក្នុងការចាប់ផ្ដើមឬការបន្តកណ្ដាជារកិច្ច នាវាបានស្ថិតនៅក្នុងស្ថានភាពដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍ មនុស្សនៅលើនាវា ចរាចរនាវាផ្សេងទៀត ឬបរិស្ថាន។ ក្នុងករណីនេះ កណ្ដាជារត្រូវរាយការណ៍ជាបន្ទាន់ទៅមេបញ្ជាការផែ។

**មាត្រា២២៨.-**

កណ្ដាជារត្រូវមានវិញ្ញាបនបត្រកណ្ដាជារ ដែលមានសុពលភាពមិនលើស៥(ប្រាំ)ឆ្នាំ។

វិញ្ញាបនបត្រកណ្ដាជារ ត្រូវផ្ដល់ឱ្យបេក្ខជនដែលមានគុណវុឌ្ឍិដូចខាងក្រោម៖

- មានការបណ្ដុះបណ្ដាលមុខជំនាញកណ្ដាជារ ឬមានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជានាយនាវា ឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជានាយបើកបរនាវា
- មានវិញ្ញាបនបត្របញ្ជាក់សុខភាព ដែលបញ្ជាក់ថាអាចបម្រើការងារនៅលើដាន់នាវាជំនួញបាន
- ទទួលបានការបណ្ដុះបណ្ដាលអំពីដែនកណ្ដាជារកិច្ចនិងបម្រើការងារជាជំនួយការកណ្ដាជារនៅក្នុងដែនកណ្ដាជារកិច្ច ដែលខ្លួនត្រូវបំពេញ
- មានចំណេះដឹងភាសាអង់គ្លេស
- ប្រឡងឬធ្វើតេស្តជាប់ជាស្ថាពរ ដែលរៀបចំដោយអគ្គនាយកដ្ឋានទទួលបន្ទុកកិច្ចការដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ។

វិញ្ញាបនបត្រកណ្ដាជារ ដែលបានផ្ដល់ឱ្យបេក្ខជនដើម្បីបំពេញមុខងារជាកណ្ដាជារដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវដកហូតឬចាត់ទុកជាមោឃៈ ក្នុងករណីដូចខាងក្រោម៖

- កណ្ណធារបានបាត់បង់សមត្ថភាពការងារ
- កណ្ណធារខកខានបម្រើការងារជាកណ្ណធារ រយៈពេល៣០(សាមសិប)ខែ បន្ទាប់ពីបានទទួលវិញ្ញាបនបត្រកណ្ណធារ
- កណ្ណធារបានបំពេញកណ្ណធារកិច្ចនិងផ្តល់ការណែនាំមិនត្រឹមត្រូវ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍
- កណ្ណធារបានប្រព្រឹត្តអំពើរើសអើងឬទាមទារអត្ថប្រយោជន៍ខុសច្បាប់ណាមួយ ក្នុងពេលបំពេញភារកិច្ច។

**មាត្រា២២៩ .-**

កណ្ណធារកិច្ចជាកាតព្វកិច្ច ត្រូវបានលើកលែង ប្រសិនបើនាយនាវាទទួលបានវិញ្ញាបនបត្រលើកលែងកណ្ណធារ ក្រោយបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១- នាយនាវាបានធ្វើប្រតិបត្តិការឆ្លងកាត់ដែនកណ្ណធារកិច្ចច្រើនដងដោយសុវត្ថិភាព មិនប៉ះពាល់ដល់ចរាចរណ៍របស់នាវាផ្សេងទៀត មិនរំលោភដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។

២- នាយនាវាបានបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា២២៨នៃច្បាប់នេះ។

វិញ្ញាបនបត្រលើកលែងកណ្ណធារ មានសុពលភាពមិនលើស៥(ប្រាំ)ឆ្នាំ។

វិញ្ញាបនបត្រលើកលែងកណ្ណធារ ត្រូវបានដកហូតឬចាត់ទុកជាមោឃៈ ក្នុងករណីដែលនាយនាវាបានបង្កផលប៉ះពាល់ដល់ចរាចរណ៍នាវាផ្សេងទៀត ឬរំលោភផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។

កណ្ណធារកិច្ចជាកាតព្វកិច្ច ក៏ត្រូវបានលើកលែងផងដែរក្នុងករណីប្រធានសក្តិ។

**មាត្រា២៣០ .-**

កណ្ណធារកិច្ចត្រូវអនុវត្តដោយកណ្ណធារ ដែលជាមន្ត្រីក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មានសិទ្ធិប្រគល់ឱ្យផ្នែកឯកជន ដើម្បីបំពេញកណ្ណធារកិច្ចនៅតាមដែនកណ្ណធារកិច្ចណាមួយ។

**មាត្រា២៣១ .-**

លក្ខខណ្ឌនិងនីតិវិធីកណ្ណធារកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ឯកសណ្ឋានកណ្ណធារ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៣
## យានដ្ឋាននាវា

**មាត្រា២៣២ .-**

ការបង្កើតយានដ្ឋាននាវា ត្រូវមានវិញ្ញាបនបត្រយានដ្ឋាននាវា ដែលមានសុពលភាពអចិន្ត្រៃយ៍។

យានដ្ឋាននាវាត្រូវមានលិខិតអនុញ្ញាតអាជីវកម្មយានដ្ឋាននាវា សម្រាប់សាងសង់និងជួសជុលនាវា។

នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រយានដ្ឋាននាវានិងលិខិតអនុញ្ញាតអាជីវកម្មយានដ្ឋាននាវា សម្រាប់សាងសង់និងជួសជុលនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៣៣ .-**

ការសាងសង់និង/ឬការជួសជុលនាវា ត្រូវមានលិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលនាវា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសាងសង់និង/ឬជួសជុលនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៣៤ .-**

ការសាងសង់និងជួសជុលនាវា ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃការសាងសង់និងជួសជុលនាវា។

បទដ្ឋានបច្ចេកទេសនៃការសាងសង់និងជួសជុលនាវា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ជំពូកទី១៤
## អធិការកិច្ចនិងការត្រួតពិនិត្យ
### ផ្នែកទី១
### ការធ្វើអធិការកិច្ចនាវាឆ្លងសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស យានដ្ឋាននាវា ឋបនីយកណ្តាលផែ សំណង់សិល្បការ្យ អង្គបណ្តែតទឹក និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត

**មាត្រា២៣៥ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចាត់តាំងមន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ដើម្បីត្រួតពិនិត្យនាវាឆ្លងសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស យានដ្ឋាននាវា ឋបនីយកណ្តាលផែ សំណង់សិល្បការ្យ អង្គបណ្តែតទឹក និងសកម្មភាពផ្សេងទៀត ដែលប៉ះពាល់ដល់សុវត្ថិភាពនាវាចរណ៍ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីពិនិត្យបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងពេលប្រតិបត្តិការពិនិត្យបទល្មើស មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៣៦ .-**

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិនិងភារកិច្ចដូចខាងក្រោម៖

- ចូលទៅក្នុងទីតាំងណាមួយឬឡើងលើនាវានៅតាមកំពង់ផែ ដើម្បីតាមដាន ពិនិត្យ និងប្រតិបត្តិការងារតាមសមត្ថកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ឃាត់ជាបណ្តោះអាសន្នចំពោះនាវាដែលមានចំណុចខ្វះខាត អាចបង្កភាពគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍
- អញ្ជើញបុគ្គលពាក់ព័ន្ធនឹងនាវា យានដ្ឋាននាវា ឋបនីយកណ្តាលផែ សំណង់សិល្បការ្យ អង្គបណ្តែតទឹក និងសកម្មភាពផ្សេងទៀត មកផ្តល់ព័ត៌មាន ឯកសារ ឬវត្ថុផ្សេងៗ ដើម្បីធ្វើការស្រាវជ្រាវអនុវត្តការពិន័យអន្តរការណ៍ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- សហការជាមួយមន្ត្រីមានសមត្ថកិច្ចជំនាញរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដើម្បីបង្ក្រាបបទល្មើសនាវាចរណ៍នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចនាវានិងកំពង់ផែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៣៧ .-**

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ អាចត្រួតពិនិត្យនាវាដោយគ្មានជូនដំណឹងជាមុន។

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ អាចចូលទៅកាន់យានដ្ឋាននាវា ឋបនីយកណ្ដផែ សំណង់សិល្បការ្យ និងអង្គបណ្ដែតទឹក បន្ទាប់បានជូនដំណឹងជាលាយលក្ខណ៍អក្សរតាមកាលបរិច្ឆេទកំណត់ នៅក្នុងម៉ោងធ្វើការ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

## ផ្នែកទី២
## ការត្រួតពិនិត្យនាវាបរទេសនៅកំពង់ផែ

**មាត្រា២៣៨ .-**

នាវាបរទេសដែលចូលកំពង់ផែនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យនាវាបរទេស ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៣៩ .-**

ការត្រួតពិនិត្យនាវាបរទេស ត្រូវធ្វើឡើងក្នុងគោលបំណងត្រួតពិនិត្យផ្នែកបច្ចេកទេសនិងអនុលោមភាព ដើម្បីធានាឱ្យនាវាបរទេសដែលចូលកំពង់ផែនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោរពតាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

ការត្រួតពិនិត្យនាវាបរទេស ត្រូវធ្វើឡើងតាមការផ្ដួចផ្ដើមរបស់មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬការស្នើសុំពីមន្ត្រីត្រួតពិនិត្យនាវាបរទេសនៅកំពង់ផែចេញដំណើរចុងក្រោយ ឬការស្នើសុំពីនាវិកដែលស្ថិតនៅលើនាវា ឬតាមការស្នើសុំរបស់កំពង់ផែ។

**មាត្រា២៤០ .-**

ការត្រួតពិនិត្យនាវាបរទេស រួមមាន៖

១- ការត្រួតពិនិត្យបឋម : ការពិនិត្យឯកសារនិងស្ថានភាពទូទៅផ្នែកខាងក្រៅរបស់នាវា។

២- ការត្រួតពិនិត្យលម្អិត : ធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យបឋម ប្រសិនបើមានមូលបទច្បាស់លាស់បញ្ជាក់ថា នាវាមានចំណុចខ្វះខាតទាំងផ្នែកឯកសារនិងសុវត្ថិភាព។

ក្នុងការត្រួតពិនិត្យលម្អិត ត្រូវអនុវត្តដូចខាងក្រោម៖

- មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវអនុញ្ញាតឱ្យនាវាចេញពីកំពង់ផែជាធម្មតា ក្នុងករណីពិនិត្យឃើញថា នាវានោះគ្មានចំណុចខ្វះខាត
- មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវឃាត់នាវាជាបណ្ដោះអាសន្ន ដើម្បីធ្វើការកែតម្រូវចំណុចខ្វះខាតឡើងវិញ ក្នុងករណីពិនិត្យឃើញថា នាវានោះមានចំណុចខ្វះខាតដែលត្រូវឃាត់
- មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវផ្អាកការត្រួតពិនិត្យលម្អិត និងបន្តធ្វើការត្រួតពិនិត្យតាមផ្នែកនីមួយៗ ក្នុងករណីពិនិត្យឃើញថា នាវានោះស្ថិតនៅក្រោមបទដ្ឋានបច្ចេកទេស។

**មាត្រា២៤១ .-**

ក្រោយពេលត្រួតពិនិត្យ មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវធ្វើរបាយការណ៍ត្រួតពិនិត្យនាវានៅចំពោះ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

របាយការណ៍ត្រូវបញ្ជាក់អំពីចំណុចខ្វះខាត បុគ្គលដែលត្រូវជូនដំណឹង និងចំណុចខ្វះខាត កាលបរិច្ឆេទ និងទីកន្លែង ដែលនាវាត្រូវកែតម្រូវ។

បុគ្គលដែលត្រូវជូនដំណឹងដូចមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ រួមមានមន្ត្រីត្រួតពិនិត្យនាវាបរទេសនៅកំពង់ផែបន្ទាប់ ប្រទេសម្ចាស់សញ្ជាតិនាវានិងនាវិក តំណាងស្ថានទូតឬស្ថានកុងស៊ុលនៃប្រទេសសញ្ជាតិនាវានិងនាវិក និងអង្គការចំណាត់ថ្នាក់នាវា។

**មាត្រា២៤២ ៈ-**

មន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវមានគុណវុឌ្ឍិដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៤៣ ៈ-**

ការត្រួតពិនិត្យនាវាបរទេសនៅតាមកំពង់ផែ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣

## ការត្រួតពិនិត្យនាវាតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា២៤៤ ៈ-**

នាវាដែលធ្វើនាវាចរណ៍នៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ចនៃក្រសួង ស្ថាប័ន ដែលមានភារកិច្ចត្រួតពិនិត្យនាវានៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាអនុលោមតាមច្បាប់នេះនិងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៤៥ ៈ-**

មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិបញ្ឈប់នាវាឆ្លងសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស ដែលកំពុងធ្វើដំណើរតាមផ្លូវទឹកនិងឡើងលើនាវា ដើម្បីត្រួតពិនិត្យបទល្មើស ក្នុងករណីមានភស្តុតាងឬការសង្ស័យដែលជឿជាក់ថា នាវាបានរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

ក្នុងការត្រួតពិនិត្យលើនាវា ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិចាត់វិធានការឃាត់នាវា និង/ឬឃាត់ជនណាមួយដែលប្រព្រឹត្តបទល្មើស និងកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនិងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

ការត្រួតពិនិត្យនិងការចាត់វិធានការលើនាវា ត្រូវធ្វើឡើងដោយគ្មានការពន្យារពេល និងមិនបង្កហានិភ័យដល់សុវត្ថិភាពនាវាចរណ៍ឡើយ ហើយត្រូវជូនដំណឹងអំពីករណីនេះ ទៅក្រសួងសាធារណការនិងដឹកជញ្ជូន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាវាត្រូវបានចុះបញ្ជី។

**មាត្រា២៤៦ ៈ-**

នាវាបរទេសដែលធ្វើនាវាចរណ៍នៅតាមផ្លូវទឹកឆ្លងកាត់ នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើនាវាចរណ៍ដោយសន្តិភាពដោយត្រូវធ្វើដំណើរជានិច្ចមិនបង្អង់ និងមិនត្រូវប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម៖

១- ការគំរាមកំហែង ឬប្រើកម្លាំងប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពទឹកដី ឯករាជ្យភាព ឬក្នុងទម្រង់ណាមួយដែលរំលោភគោលការណ៍ច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

២- សកម្មភាពប្រមូលយកព័ត៌មានឬឃោសនា ក្នុងគោលបំណងបំផ្លាញសន្តិសុខឬកិច្ចការពារជាតិ។

៣- សកម្មភាពផ្ទេរផ្ទុកវត្ថុ រូបិយបណ្ណ ឬមនុស្ស។

៤- ចេតនាបំពុលបរិស្ថាន។

៥- សកម្មភាពធ្វើនេសាទ។

៦- សកម្មភាពសិក្សានិងស្រាវជ្រាវ។

៧- សកម្មភាពរំខានប្រព័ន្ធទំនាក់ទំនងឬស្ថានីយវិទ្យុឆ្នេរសមុទ្រ។

៨- សកម្មភាពសំចតដោយគ្មានជូនដំណឹង។

៩- សកម្មភាពផ្សេងទៀត ដែលអាចប៉ះពាល់ដោយប្រយោល។

នាវាបរទេសដែលធ្វើនាវាចរណ៍ឆ្លងកាត់នៅតាមតំបន់សមុទ្រដែនដី នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលើកទង់ជាតិនៃប្រទេសម្ចាស់សញ្ជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា មានឯកសារនាវានិងនាវិក ទំនិញ ឬអ្នកដំណើរ ដែលមានសុពលភាព។

**មាត្រា២៤៧ .-**

មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិបញ្ឈប់និងឡើងលើនាវាបរទេសដែលកំពុងធ្វើដំណើរឆ្លងកាត់នៅតាមផ្លូវទឹកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការពិនិត្យបទល្មើស ដែលបានប្រព្រឹត្តដោយនាវាឬនៅលើនាវា។

ការពិនិត្យបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើ រួមមានការសាកសួរនាយនាវា ការពិនិត្យឯកសារនាវានិងនាវិក និងភស្តុតាងជាក់ស្តែងនៅលើនាវា ហើយបន្ទាប់ពីត្រួតពិនិត្យឃើញថា មានបទល្មើសជាក់ស្តែង សមត្ថកិច្ចត្រួតពិនិត្យនាវា មានសិទ្ធិចាប់នាវា ចាប់ជនល្មើស និងរៀបចំសំណុំរឿងទៅតុលាការមានសមត្ថកិច្ចដោយអនុវត្តស្របតាមក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

គ្រប់ករណីនៃការបញ្ឈប់និងឡើងលើនាវាបរទេសដែលកំពុងធ្វើដំណើរឆ្លងកាត់នៅតាមផ្លូវទឹកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីមានសមត្ថកិច្ចដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានភស្តុតាងឬការសង្ស័យដែលជឿជាក់ថានាវាបរទេស បានប្រព្រឹត្តល្មើសដែលផ្ទុយនឹងច្បាប់នេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត និងត្រូវធ្វើការពិនិត្យបទល្មើសរួមនឹងចាត់វិធានការដែលអាចកើតមានដោយគ្មានការពន្យារពេល។

**មាត្រា២៤៨ .-**

ក្នុងករណីមានបទល្មើសដែលបានកើតឡើងនៅលើនាវាបរទេស ដែលកំពុងធ្វើដំណើរឆ្លងកាត់នៅដែនទឹកផ្ទៃក្នុង ឬនៅក្នុងតំបន់សមុទ្រដែនដីនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិចាប់នាវា ឬចាប់ជនណាម្នាក់បាន ក្នុងករណីណាមួយដូចខាងក្រោម៖

- ផលវិបាកនៃបទល្មើសនោះ មានវិសាលភាពប៉ះពាល់ដល់អធិបតេយ្យ បូរណភាពទឹកដី ឯករាជ្យ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា
- មានការស្នើសុំពីនាយនាវា ឬស្ថានទូត ឬស្ថានតំណាងនៃប្រទេសសញ្ជាតិនាវា
- ធានការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ជាអាទិ៍ បទល្មើសគ្រឿងញៀន ការរត់ពន្ធ ការជួញដូរមនុស្ស ។

**មាត្រា២៤៩ .-**

គ្រប់ករណីនៃការបញ្ឈប់ ឡើងលើនាវា និងចាត់វិធានការណាមួយ ដូចមានចែងនៅក្នុងមាត្រា២៤៧ និងមាត្រា២៤៨នៃច្បាប់នេះ មន្ត្រីមានសមត្ថកិច្ចត្រូវជូនដំណឹងទៅម្ចាស់នាវា ឬតំណាងម្ចាស់នាវា ប្រទេសម្ចាស់សញ្ជាតិនាវា ឬស្ថានទូត ឬស្ថានតំណាង។ ការជូនដំណឹងនេះត្រូវធ្វើឡើងទន្ទឹមនឹងការចាត់វិធានការ ឬត្រូវធ្វើឡើងភ្លាមបន្ទាប់ពីការចាត់វិធានការ។

គ្រប់ករណីនៃការបញ្ឈប់នាវាដែលកំពុងធ្វើដំណើរដើម្បីធ្វើការពិនិត្យបទល្មើស ឬក្នុងករណីមានការដេញប្រផាប់ចាប់ប្រកីងនៅពេលដែលនាវាមិនព្រមឈប់ មន្ត្រីមានសមត្ថកិច្ចមិនត្រូវបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍ឡើយ។

## ផ្នែកទី៤
## ឯកសណ្ឋាន

**មាត្រា២៥០ .-**

ក្នុងពេលបំពេញភារកិច្ច មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ និងមន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ និងមន្ត្រីត្រួតពិនិត្យនាវាបរទេស ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៥
## សហាធិធាន

**មាត្រា២៥១ .-**

កម្រៃសេវាសាធារណៈដែលតម្រូវឱ្យមាននៅក្នុងច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ជំពូកទី១៦
## ទោសប្បញ្ញត្តិ

**មាត្រា២៥២ .-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមាន ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

**មាត្រា២៥៣ .-**

ទណ្ឌកម្មរដ្ឋបាល រួមមានៈ

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកជាបណ្តោះអាសន្ន
- ការតម្រូវឱ្យរុះរើ
- ការតម្រូវឱ្យធ្វើបដិទានឡើងវិញ
- ការព្យួរ ការដកហូត ការលុបចោលវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ឬឯកសារដែលបានផ្តល់អនុលោមតាមច្បាប់នេះ។

អំពើដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ក្រៅពីការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចចិត្ត។ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសម្រេចលើពាក្យប្តឹងតវ៉ានេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹងតវ៉ា។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន លើពាក្យបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេច អំពីទណ្ឌកម្មរដ្ឋបាលនោះទេ។

**មាត្រា២៥៤ .-**

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងនៃបទល្មើស ហើយបញ្ជូនទៅតុលាការតាមនីតិវិធី។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាល អាចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ។

**មាត្រា២៥៥ .-**

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬមន្ត្រីមានសមត្ថកិច្ចដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ត្រូវទទួលខុសត្រូវផ្នែករដ្ឋបាលនេះ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ការទទួលខុសត្រូវផ្នែករដ្ឋបាល មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ ការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។

**មាត្រា២៥៦ .-**

នាយនាវា ឬបរិបាលនាវាដែលបានបដិសេធដោយគ្មានមូលហេតុច្បាស់លាស់ផ្តល់ជំនួយសង្គ្រោះដល់នាវា នាវិក អ្នកដំណើរ ឬបុគ្គលណាមួយ ដែលកំពុងរងគ្រោះក្រោយការប៉ះទង្គិចនាវា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

**មាត្រា២៥៧ .-**

ជនណាដែលដឹងច្បាស់ថា នាវាដែលខ្លួនធ្វើនាវាចរណ៍ បានបង្កឱ្យមានគ្រោះថ្នាក់ឬការខូចខាត ហើយបានរត់គេចខ្លួនពីការទទួលខុសត្រូវព្រហ្មទណ្ឌឬរដ្ឋប្បវេណី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

**មាត្រា២៥៨ .-**

ជនណាដែលបានធ្វើនាវាចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិស្តីពីនាវាចរណ៍តម្រូវ បណ្តាលឱ្យមានរងរបួសដល់អ្នកដទៃ ហើយបណ្តាលឱ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១២ ០០០ ០០០(ដប់ពីរលាន)រៀល ក្នុងករណីណាមួយដូចខាងក្រោម៖

១- គ្មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្ហិលេខដែលតម្រូវឱ្យមាន អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- បណ្តាលឱ្យមានរបួសមនុស្សច្រើននាក់។

៣- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

៤- ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

**មាត្រា២៥៩ .-**

ជនណាដែលបានធ្វើនាវាចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិស្តីពីនាវាចរណ៍តម្រូវ បណ្តាលឱ្យអ្នកដទៃបាត់បង់ជីវិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១២ ០០០ ០០០(ដប់ពីរលាន)រៀល។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៨ ០០០ ០០០(ប្រាំបីលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ក្នុងករណីណាមួយដូចខាងក្រោម៖

១- គ្មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្ហិលេខដែលតម្រូវឱ្យមានអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- បណ្តាលឱ្យមនុស្សស្លាប់ច្រើននាក់។

៣- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

៤- ស្ថិតក្នុងស្ថានភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០ (សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា២៦០ .-**

នាវិកដែលបានធ្វើនាវាចរណ៍ ដោយគ្មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកឬវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបង្ហិលេខ ឬក្នុងរយៈពេលដែលវិញ្ញាបនបត្រសមត្ថភាពជំនាញទាំងនោះ ត្រូវបានព្យួរទុក ដកហូត ឬទុកជាមោឃៈ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

បទល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀល ទៅ២ ០០០ ០០០(ពីរលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍រួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងកំលុងពេល១(មួយ) ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា២៦១ .-**

ជនណាដែលបានធ្វើនាវាចរណ៍ដោយគ្មានវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹក ក្នុងប្រទេស ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃ ទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀល ទៅ៤០០ ០០០(បួនសែន)រៀល ករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍រួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងកំលុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា២៦២ .-**

ជនណាដែលបានធ្វើនាវាចរណ៍ដោយក្លែងបន្លំជានាវាសញ្ជាតិខ្មែរ ដោយមិនបានចុះបញ្ជីនាវាសញ្ជាតិខ្មែរស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា២៦៣ .-**

មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬមន្ត្រីមានសមត្ថកិច្ចណាដែល នៅក្នុងក្របខ័ណ្ឌមុខងារ ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ដែលបានដកហូតយកវិញ្ញាបនបត្រចុះបញ្ជីនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា លិខិតអនុញ្ញាតឱ្យនាវាធ្វើអាជីវកម្មដឹកជញ្ជូន វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក ឬឃាត់នាវាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃ ទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន) រៀលទៅ៤០០ ០០០(បួនសែន)រៀល។

ក្នុងករណីដែលអំពើល្មើសខាងលើបណ្តាលឱ្យមានការខូចខាត ឬបាត់បង់ផ្នែកណាមួយនៃនាវា អង្គភាពសាមីត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ឬបាត់បង់នោះ ស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀត។

ក្នុងករណីមន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ មន្ត្រីត្រួតពិនិត្យនាវាបរទេស ឬមន្ត្រីមានសមត្ថកិច្ចដែលប្រើសិទ្ធិអំណាចរំលោភដោយទទួលបានអត្ថប្រយោជន៍ក្នុងការបំពេញមុខងាររបស់ខ្លួន ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន នូវអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៣៥(រំលោភអំណាច) នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលជាបទល្មើសពុករលួយ និងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។

អង្គភាពនិងបុគ្គលដទៃទៀតដែលបានដឹងពីបទល្មើសពុករលួយ ដែលមានចែងនៅក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្ដឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្តប្រឆាំងអំពើពុករលួយ អំពីរឿងហេតុនៃបទល្មើសទាំងនេះ។

**មាត្រា២៦៤ .-**

ជនណាដែលបានរារាំង ឬប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីជាឧបសគ្គដល់នាវាចរណ៍នៅតាមផ្លូវទឹក ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

**មាត្រា២៦៥ .-**

ជនណាដែលសង់សំណង់សិល្បការ្យ ឬអង្គបណ្ដែតទឹក ឬធ្វើសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់សុវត្ថិភាពរបស់នាវាក្នុងការធ្វើនាវាចរណ៍ជាប្រក្រតីនៅតាមផ្លូវនាវាចរណ៍ ហើយរឹងទទឹងមិនព្រមរុះរើ និងធ្វើបដិទាន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

**មាត្រា២៦៦ .-**

ជនណាដែលបានសាងសង់ ឬជួសជុលឋបនីយកណ្ដាផែ ដោយគ្មានលិខិតអនុញ្ញាតសាងសង់ ឬជួសជុលឋបនីយកណ្ដាផែ ហើយរឹងទទឹងមិនព្រមផ្អាកជាបណ្ដោះអាសន្ននិងមិនព្រមបំពេញបែបបទស្នើសុំលិខិតអនុញ្ញាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

**មាត្រា២៦៧ .-**

ជនណាដែលធ្វើប្រតិបត្តិការឋបនីយកណ្ដាផែ ដោយគ្មានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការឋបនីយកណ្ដាផែ ដូចមានចែងនៅក្នុងមាត្រា២០៩នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤០០ ០០០(បួនសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់បានទទួលរងការពិន័យអន្តរការណ៍រួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងកំលុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា២៦៨ .-**

ជនណាដែលបដិសេធផ្ដល់អាទិភាពឱ្យនាវាចូលចេញកំពង់ផែ ដូចមានចែងនៅក្នុងមាត្រា២០១នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

**មាត្រា២៦៩ .-**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដែលមានចែងចាប់ពីមាត្រា២៥៦ដល់មាត្រា២៥៩ កថាខណ្ឌទី២នៃមាត្រា២៦០ កថាខណ្ឌទី២នៃមាត្រា២៦១ មាត្រា២៦២ កថាខណ្ឌទី១នៃមាត្រា២៦៣ មាត្រា២៦៤ដល់មាត្រា២៦៦ កថាខណ្ឌទី២នៃមាត្រា២៦៧ និងមាត្រា២៦៨ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា២៧០ .-**

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា២៥៨ ដល់មាត្រា២៦២ និងមាត្រា២៦៤ដល់មាត្រា២៦៨នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា២៧១ .-**

ការអនុវត្តបញ្ញត្តិនៃជំពូកទី១៦នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី១៧
## អន្តរប្បញ្ញត្តិ

**មាត្រា២៧២ .-**

បទប្បញ្ញត្តិដែលតម្រូវឱ្យនាវិកដែលបម្រើការជាបរិបាលនាវា យន្តការីនាវា អ្នកបើកបរនាវា ជំនួយការបរិបាលនាវា និងជំនួយការយន្តការីនាវា ដូចមានចែងនៅក្នុងមាត្រា៤៦នៃច្បាប់នេះ ត្រូវអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន។

**មាត្រា២៧៣ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនផ្លូវទឹកនិងកំពង់ផែ មានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១៨
## អវសានប្បញ្ញត្តិ

**មាត្រា២៧៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧៥ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ១៤កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

(ហត្ថលេខា)

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស.រកម.១២២៣.០៤៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

(ហត្ថលេខា)

**ប៉េង ពោធិ៍នា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

(ហត្ថលេខា និងត្រា)

**វង្សី វិស្សុត**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
## សន្ទានុក្រម

**ការធ្វើនាវាចរណ៍ឬនាវាចរណ៍** សំដៅដល់ការធ្វើដំណើររបស់នាវា ឬធ្វើចលនាចរណ៍របស់នាវា។

**ការធ្វើនាវាចរណ៍ឬនាវាចរណ៍ជាលក្ខណៈអន្តរជាតិ** សំដៅដល់ការធ្វើនាវាចរណ៍ ដែលក្នុងនោះនាវាចេញដំណើរពីកំពង់ផែដែលស្ថិតនៅក្នុងប្រទេសមួយ ឆ្ពោះទៅកាន់កំពង់ផែដែលស្ថិតនៅក្នុងប្រទេសផ្សេងទៀតដោយត្រូវឆ្លងកាត់សមុទ្រ។

**ការឃាត់នាវា** សំដៅដល់ (១)- ការចាត់វិធានការអន្តរាគមន៍ដោយមន្ត្រីត្រួតពិនិត្យនាវាបរទេសនៅតាមកំពង់ផែ នៅពេលដែលស្ថានភាពនាវា និងក្រុមនាវិក មិនអនុលោមតាមបទប្បញ្ញត្តិសំខាន់ៗនៃអនុសញ្ញាអន្តរជាតិ ដើម្បីធានាថានាវានឹងមិនចេញដំណើរ រហូតដល់ពេលនាវាអាចឆ្លងកាត់សមុទ្រដោយគ្មានគ្រោះថ្នាក់ ដល់នាវា នាវិក និងបរិស្ថាន (២)- ការឃាត់នាវាដើម្បីពិនិត្យបទល្មើសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និង(៣)- ការឃាត់នាវាសមុទ្រដើម្បីធានាដល់ការទូទាត់សំណងនាវាចរណ៍។

**ការចុះបញ្ជីធានានាវាឬចុះបញ្ជីធានានាវា** សំដៅដល់ការចុះបញ្ជីធានានាវាដែលធ្វើឡើងដោយម្ចាស់នាវាដើម្បីទទួលបានការខ្ចីប្រាក់សម្រាប់ការសាងសង់ឬធ្វើប្រតិបត្តិការនាវា តាមអត្រាកំណត់នៅក្នុងកិច្ចសន្យាធានានាវាឬកិច្ចសន្យាសាងសង់នាវា ដែលបានធ្វើឡើងរវាងម្ចាស់នាវា និងម្ចាស់បំណុល ដូចជាធនាគារ ឬក្រុមហ៊ុនធានារ៉ាប់រងណាមួយ។

**ក្រុមហ៊ុននាវា** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់នាវា ឬដែលធ្វើប្រតិបត្តិការនាវា។

**កំពង់ផែ** សំដៅដល់តំបន់ដែលមានដែនទឹកនិងដីគោកជាក់លាក់ និងមានបបនីយកណ្ឌផែសម្រាប់បម្រើឱ្យនាវាចូល ចេញ បោះយុថ្កា និងចត ដើម្បីលើកដាក់ ផ្ទេរ ផ្ទុក និងរក្សាទុកទំនិញ និងផ្ទេរផ្ទុកអ្នកដំណើរ។

**កណ្តជារ** សំដៅដល់អ្នកនាំផ្លូវនាវាដែលមានភារកិច្ចជួយដល់នាយនាវាឬនាយបើកបរនាវា ដើម្បីធ្វើនាវាចរណ៍ប្រកបដោយសុវត្ថិភាពនៅក្នុងដែនកណ្តជារកិច្ច ឬដែនទឹកកំពង់ផែ។

**កណ្តជារកិច្ច** សំដៅដល់កិច្ចការដែលកណ្តជារត្រូវបំពេញនៅលើនាវា ដើម្បីឱ្យនាវាធ្វើនាវាចរណ៍ឆ្លងកាត់ដែនកណ្តជារកិច្ចឬចូលចេញកំពង់ផែ ប្រកបដោយសុវត្ថិភាព នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**កម្លាំងចលករ** សំដៅដល់កម្លាំងដែលបង្កើតបានពីការប្រើប្រព័ន្ធមេកានិក រួមមានម៉ាស៊ីនចលករស្លាបចក្រឬកង្ហារ និងប្រព័ន្ធ ដើម្បីជំរុញនាវាឱ្យមានចលនានៅលើផ្ទៃទឹក ដែលជាទូទៅសំដៅលើចលនាទៅមុខ។

**កម្លាំងចលករបញ្ច្រាស** សំដៅដល់កម្លាំងចលករនាវាដោយការប្រើប្រព័ន្ធមេកានិក ដើម្បីឱ្យនាវាមានចលនាថយក្រោយ។

**ការបាត់បង់នាវាទាំងស្រុង** សំដៅដល់នាវាដែលបានបាត់ដោយអំពើចោរកម្ម មិនអាចរកឃើញឬបានជួបគ្រោះថ្នាក់នាវាចរណ៍ដោយលិចចូលក្នុងសមុទ្រ ដែលមិនអាចស្រង់វិញបាន បាក់បែកជាកំណាត់ ឆេះអស់ឬផ្ទុះដែលមិនអាចជួសជុលប្រើវិញបាន។

**ក្តោងសំខាន់** សំដៅដល់ប្រភេទក្តោងដែលបំពាក់នៅលើដងក្តោងសំខាន់របស់នាវាប្រើក្តោង។

**ក្តោងត្រង់** សំដៅដល់ប្រភេទក្តោងដែលត្រូវបានរៀបចំនិងបំពាក់នៅលើដងក្តោង មានទម្រង់ជាឬផ្ទាំងក្តោងមានដងផ្ចិត កែងនឹងដងក្តោង និងកែងជាមួយទ្រនង់បាតនាវាផងដែរ។

**ការប៉ះទង្គិចនាវា** សំដៅដល់គ្រោះថ្នាក់នាវាចរណ៍ដែលកើតឡើងដោយការប៉ះ ការកៀរ ឬការបុករវាងនាវាពីរគ្រឿងឬច្រើន ដែលបង្កឱ្យមានការបាត់បង់ឬខូចខាតដល់នាវាឬទំនិញនៅលើនាវា ឬដែលបង្កឱ្យមានការរងរបួសឬបាត់បង់ជីវិតមនុស្សនៅលើនាវា ព្រមទាំងការខូចខាតដល់ភាគីទី៣ ដូចជាការប៉ះពាល់ដល់បរិស្ថាន និងខូចខាតដល់សកម្មភាពសេដ្ឋកិច្ចស្របច្បាប់ផ្សេងៗទៀតនៅក្នុងដែនទឹក។



៦២

ករណីប្រធានសក្តិ សំដៅដល់បាតុភូតដែលកើតឡើងដោយធម្មជាតិ ដែលមនុស្សមិនអាចដឹងមុន និងមិនអាចទប់ទល់បាន។

**ខសន្យា** សំដៅដល់បទប្បញ្ញត្តិឬប្រការ ដែលមាននៅក្នុងកិច្ចសន្យា។

**គ្រោះថ្នាក់នាវាចរណ៍** សំដៅដល់គ្រោះថ្នាក់នៃនាវា ដែលកើតឡើងនៅក្នុងការធ្វើនាវាចរណ៍ដោយឧប្បត្តិហេតុផ្សេងៗ រួមមានការប៉ះទង្គិច ការឆេះ ការលិច ការកឿង ការកើល ដែលបង្កឡើងដោយបាតុភូតធម្មជាតិឬកត្តាមនុស្ស។

**គន្លងបែងចែកចរាចរណ៍** សំដៅដល់គន្លងនាវាចរណ៍ ដែលបែងចែកទិសដៅចរាចរណ៍និងត្រូវកំណត់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

**ច្រកនាវាចរណ៍** សំដៅដល់ផ្លូវនាវាចរណ៍នៅក្នុងតំបន់ទន្លេ បឹង ឆកសមុទ្រ ពាម ដែនទឹកកំពង់ផែ ជាអាទិ៍ នៅចន្លោះតំបន់ទឹករាក់ ទំនាបលិចទឹក និង/ឬកោះជាអាទិ៍។

**ចំណុចខ្វះខាតដែលត្រូវឃាត់នាវា** សំដៅដល់ចំណុចខ្វះខាតដែលបង្ហាញថា មានការគំរាមកំហែងដល់សុវត្ថិភាពនាវា នាវិក និងបរិស្ថាន នៅពេលដែលនាវាធ្វើដំណើរឆ្លងកាត់សមុទ្រ។

**ជម្រៅស៊ីទឹក** សំដៅដល់ប្រវែងពីបាតរបស់នាវារហូតដល់ខ្សែបន្ទាត់ទឹករបស់នាវាឬផ្ទៃទឹក។

**ដែនទឹកនៃកំពង់ផែ** សំដៅដល់តំបន់ រួមមានច្រកចូលចេញ តំបន់សម្រាលទំនិញ តំបន់បោះយុថ្កា កន្លែងបត់នាវា ចំណតនាវា និងឋបនីយកណ្តាផ្សេងទៀតជាអាទិ៍។ តំបន់សម្រាលទំនិញ ជាតំបន់ស្ថិតនៅក្នុងឬនៅក្រៅដែនទឹកនៃកំពង់ផែ សម្រាប់ឱ្យនាវាដែលមានជម្រៅស៊ីទឹកជ្រៅ ឬនាវាដឹកប្រេង/ឧស្ម័នដែលមានហានិភ័យកំពប់ប្រេង/ឧស្ម័នក្នុងពេលផ្ទេរផ្ទុក ចូលចតដោយប្រើយុថ្កា ដើម្បីផ្ទេរផ្ទុកទំនិញ។ តំបន់បោះយុថ្កា ជាតំបន់ស្ថិតនៅក្នុងដែនទឹកនៃកំពង់ផែឬក្រៅដែនទឹកនៃកំពង់ផែ សម្រាប់ឱ្យនាវាចូលចតដោយការប្រើយុថ្កាបោះភ្ជាប់ទៅនឹងបាតទឹក។ ចំណតនាវា រួមមានចំណតគោកនិងចំណតទឹក។ ចំណតគោក ជាសំណង់រឹងសម្រាប់នាវាចូលចតដែលមានទីតាំងជាប់ផ្ទាល់ទៅនឹងដីគោកនៃកំពង់ផែ។ ចំណតទឹក ជាតំបន់ស្ថិតនៅក្នុងដែនទឹកនៃកំពង់ផែ សម្រាប់ឱ្យនាវាចូលចតដោយការចងភ្ជាប់នាវាទៅនឹងពោងដែលតភ្ជាប់យ៉ាងមាំទៅបាតទឹក។

**ដីគោកនៃកំពង់ផែ** សំដៅដល់ទីធ្លាដីគោកដែលមានឋបនីយកណ្តាសម្រាប់បម្រើឱ្យការលើកដាក់ ការផ្ទេរផ្ទុក ការរក្សាទុកទំនិញ ការឡើងចុះរបស់អ្នកដំណើរ និងឋបនីយកណ្តាជំនួយផ្សេងទៀត។

**ដែនទឹកផ្ទៃក្នុង** សំដៅដល់តំបន់សមុទ្រដែលស្ថិតនៅខាងក្នុងខ្សែបន្ទាត់មូលដ្ឋាន។

**ដែនកណ្តាជារកិច្ច** សំដៅដល់ផ្នែកមួយនៃផ្លូវនាវាចរណ៍ ដែលត្រូវបានកំណត់ឱ្យនាវាត្រូវប្រើសេវាកណ្តាជារកិច្ច។

**ដេញប្រផាប់ចាប់ប្រកឹង** សំដៅដល់សកម្មភាពនាវារបស់មន្ត្រីមានសមត្ថកិច្ច ដេញនាវាបរទេសនៅក្នុងតំបន់សមុទ្រដែនដីបន្ទាប់ពីនាវាបានចេញពីដែនទឹកផ្ទៃក្នុង ដើម្បីឃាត់ឡើងលើនាវា និងត្រួតពិនិត្យអំពើល្មើស ប្រសិនបើមានភស្តុតាងឬសង្ស័យអំពីអំពើល្មើស ហើយនាវានោះមិនព្រមឈប់តាមការស្នើសុំរបស់មន្ត្រីមានសមត្ថកិច្ចនោះ។

**ឋបនីយកណ្តាផែ** សំដៅដល់ទីតាំងដែលមានប្រតិបត្តិការរវាងនាវានិងកំពង់ផែ។ ឋបនីយកណ្តាផែ រួមមានតំបន់ចំណត តំបន់បោះយុថ្កា តំបន់រង់ចាំ ប្រឡាយនាវាចរណ៍ និងពាម ព្រមទាំងសំណង់និងឧបករណ៍សម្ភារៈនានា។

**ម៉ាស៊ីនបន្សុទ្ធនុយក្លេអ៊ែលើនាវា** សំដៅដល់ម៉ាស៊ីនរ៉េអាក់ទ័រ ម៉ាស៊ីនកែច្នៃសារធាតុនុយក្លេអ៊ែ ម៉ាស៊ីនផលិតឥន្ធនៈ ឬផលិតថាមពលនុយក្លេអ៊ែ ម៉ាស៊ីនរក្សាទុកសារធាតុនុយក្លេអ៊ែ ឬប្រភេទឋបនការណាមួយដែលមានថាមពលនុយក្លេអ៊ែ សារធាតុវិទ្យុសកម្ម ឬសំណល់វិទ្យុសកម្ម។

ណាត សំដៅដល់ខ្នាតល្បឿនគិតជាម៉ែល៍សមុទ្រក្នុងមួយម៉ោង។ ១ម៉ែល៍សមុទ្រសម្រាប់វាស់ល្បឿន ត្រូវបានសន្មតយកម៉ែល៍សមុទ្រអន្តរជាតិស្មើនឹង១៨៥២(មួយពាន់ប្រាំបីរយហាសិបពីរ)ម៉ែត្រ។

**តំបន់បោះយុថ្កា** សំដៅដល់ទីតាំងនៅក្នុងផ្លូវទឹក ដែលបានកំណត់សម្រាប់ឱ្យនាវាបោះយុថ្កា។

**តំបន់សមុទ្រដែនដី** សំដៅដល់តំបន់សមុទ្រដែលស្ថិតនៅក្នុងចម្ងាយ១២ម៉ែល៍សមុទ្រ ពីខ្សែបន្ទាត់មូលដ្ឋានឆ្ពោះទៅសមុទ្រ។

**ថ្លៃឈ្នួលកំពង់ផែ** សំដៅដល់ថ្លៃចំណុះផ្ទុកសរុប ថ្លៃប្រើប្រឡាយនាវាចរណ៍ ថ្លៃបោះយុថ្កា ថ្លៃចងនិងស្រាយពួរ ថ្លៃចត ថ្លៃលើកដាក់ទំនិញ ថ្លៃផ្ទេរផ្ទុកទំនិញ ថ្លៃកណ្ណជារកិច្ច ថ្លៃប្រើនាវាពុញនិងសណ្តោង និងថ្លៃប្រើសេវាផ្សេងទៀត។

**ទំនិញគ្រោះថ្នាក់** សំដៅដល់ទំនិញដែលគេបានចាត់ថ្នាក់នៅក្នុងក្រមអន្តរជាតិស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវសមុទ្រ និងងាយមានគ្រោះថ្នាក់ដល់ការដឹកជញ្ជូន ប្រសិនបើមិនមានវិធានការទប់ស្កាត់ឬការប្រុងប្រយ័ត្នជាមុន។

**ទំនិញ** សំដៅដល់ផលិតផល ជាវត្ថុរឹង រាវ និងឧស្ម័ន ក្នុងទម្រង់វេចខ្ចប់ឬកុងតឺន័រ រាយឬចាក់ជារ និងសត្វរស់ឬរុក្ខជាតិរស់។

**ទិសបើកបរ** សំដៅដល់ទិសឆ្ពោះរបស់នាវា បង្ហាញជាដឺក្រេវាស់តាមទិសដៅទ្រនិចនាឡិកា ចេញពីខ្សែបណ្តោយខាងជើងនៃផែនដីទៅបន្ទាត់ពុះបណ្តោយនៃនាវា។

**ទិសសង្កេត** សំដៅដល់ទិសតម្រង់ទៅវត្ថុត្រូវសង្កេត មានរង្វាស់ជាដឺក្រេដែលវាស់តាមទិសដៅទ្រនិចនាឡិកា ចេញពីខ្សែបណ្តោយខាងជើងនៃផែនដីទៅបន្ទាត់កាត់រវាងអ្នកសង្កេតនិងវត្ថុត្រូវសង្កេត។

នាវា សំដៅដល់ជលយានដែលសាងសង់ឡើងសម្រាប់ធ្វើដំណើរនៅលើផ្លូវទឹក។

នាវាឆ្នេរសមុទ្រ សំដៅដល់នាវាដែលចុះបញ្ជីជានាវាឆ្នេរសមុទ្រ ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍នៅតាមឈូងសមុទ្រ ឆកសមុទ្រ និងព្រែកជាប់សមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជា។

នាវាផ្លូវទឹកក្នុងប្រទេស សំដៅដល់នាវាដែលចុះបញ្ជីជានាវាផ្លូវទឹកក្នុងប្រទេស ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍នៅតាមទន្លេ ព្រែក ស្ទឹង បឹង ក្នុងព្រះរាជាណាចក្រកម្ពុជា។

នាវាសមុទ្រ សំដៅដល់នាវាដែលធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រ។

នាវាសញ្ជាតិខ្មែរ សំដៅដល់នាវាសមុទ្រ ដែលចុះបញ្ជីជានាវាសញ្ជាតិខ្មែរដោយអង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រ។

**នាវាបរទេស** សំដៅដល់នាវាសមុទ្រដែលចុះបញ្ជីជានាវាសមុទ្រដោយអាជ្ញាធរមានសមត្ថកិច្ចបរទេសដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រ។

**នាវាដឹកទំនិញ** សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់គោលបំណងដឹកជញ្ជូនទំនិញ ដែលរួមមាននាវាដឹកទំនិញទូទៅ នាវាដឹកទំនិញកុងតឺន័រ នាវាដឹកទំនិញចាក់ជារ នាវាដឹកប្រេង នាវាដឹកឧស្ម័ន សាឡាង ប៉ុងតុង [illegible]ដាខុនជាអាទិ៍។

**នាវាដឹកអ្នកដំណើរ** សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់គោលបំណងដឹកជញ្ជូនអ្នកដំណើរ ដែលរួមមាននាវាដឹកអ្នកដំណើរ នាវាកម្សាន្ត នាវាលម្ហែជាអាទិ៍។

**នាវាពន្លត់អគ្គិភ័យ** សំដៅដល់នាវាដែលសាងសង់ឡើងសម្រាប់គោលបំណងពន្លត់អគ្គិភ័យ។

**នាវាសង្គ្រោះ** សំដៅដល់នាវាដែលសាងសង់ឡើងសម្រាប់គោលបំណងជួយសង្គ្រោះនាវា និងមនុស្សក្នុងឧប្បត្តិហេតុគ្រោះអាសន្ន និងអាចសម្គាល់បានថាជានាវាសង្គ្រោះ។

**នាវាកងកម្លាំងមានសមត្ថកិច្ច** សំដៅដល់នាវាកងកម្លាំងមានសមត្ថកិច្ចនៃក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ សម្រាប់គោលបំណងរក្សាសន្តិសុខជាតិនិងកិច្ចការពារជាតិ។

**នាវាបំពេញបេសកកម្មពិសេស** សំដៅដល់នាវាធ្វើប្រតិបត្តិការដោយមន្ត្រីដែលត្រូវបានចាត់តាំងឱ្យបំពេញការងារផ្នែកសណ្ដាប់ធ្នាប់នាវាចរណ៍។

**នាវាបំពេញសកម្មភាពសុវត្ថិភាពសាធារណៈ** សំដៅដល់នាវាសម្រាប់ល្បាត ហែក្បួន ពិធីបុណ្យពិសេស ត្រួតពិនិត្យចរាចរណ៍ សង្គ្រោះ ពន្លត់អគ្គិភ័យ ជំនួយផ្នែកសុខាភិបាល ជំនួយសង្គ្រោះនាវា រុករកនិងសង្គ្រោះ ជាអាទិ៍។

**នាវាប្រើម៉ាស៊ីន** សំដៅដល់នាវាដែលធ្វើចលនាបានដោយប្រើកម្លាំងម៉ាស៊ីន។

**នាវានេសាទ** សំដៅដល់នាវាដែលសាងសង់ឡើងដោយមានបំពាក់ឧបករណ៍សម្ភារៈនេសាទសម្រាប់ធ្វើនេសាទ។

**នាវាកំពុងនេសាទ** សំដៅដល់នាវា ដែលកំពុងធ្វើនេសាទដោយប្រើមង សន្ទូច អួនអូស ឬអួនហ៊ុម ឬឧបករណ៍នេសាទផ្សេងទៀត ដែលធ្វើឱ្យនាវាលំបាកបញ្ជាចលនាចរណ៍។

**នាវាប្រើក្ដោង** សំដៅដល់នាវាដែលធ្វើចលនាដោយប្រើកម្លាំងខ្យល់បក់ឬប្រសិនបើមានម៉ាស៊ីន ក៏ម៉ាស៊ីននោះនៅតែមិនប្រើដដែល។

**នាវាសណ្ដោង** សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់សណ្ដោងឬរុញនាវាផ្សេងទៀត។

**នាវារុញ** សំដៅដល់នាវាដែលបានសាងសង់ឡើងសម្រាប់រុញនាវាផ្សេងទៀត។

**នាវាមានកម្រិតសមត្ថភាពចលនាចរណ៍** សំដៅដល់នាវាដែលមានដែនកម្រិតចលនាចរណ៍ក្នុងពេលបំពេញការងាររបស់ខ្លួន រួមមាននាវាកំពុងដាក់ឬលើកសញ្ញាជំនួយនាវាចរណ៍ លើកខ្សែកាបឬបំពង់បង្ហូរនាវាកំពុងធ្វើប្រតិបត្តិការជីកស្ដារប្រឡាយនាវាចរណ៍ នាវាកំពុងធ្វើការសិក្សាស្រាវជ្រាវផ្នែកក្រោមទឹក នាវាកំពុងធ្វើការផ្ទេរទំនិញឬមនុស្ស នាវាកំពុងធ្វើប្រតិបត្តិការយករ៉ែ នាវាកំពុងធ្វើប្រតិបត្តិការស្រង់បំណែកនាវាលិចឬសំណល់នាវានៅក្នុងទឹក និងនាវាកំពុងធ្វើប្រតិបត្តិការសណ្ដោងឬរុញ។

**នាវាមិនអាចបញ្ជាបាន** សំដៅដល់នាវាដែលស្ថិតក្នុងកាលៈទេសៈខុសប្រក្រតី មិនអាចធ្វើចលនាចរណ៍តាមវិធាន ក្នុងបទប្បញ្ញត្តិនាវាចរណ៍បាន និងមិនមានសមត្ថភាពងាកចេញពីផ្លូវធ្វើដំណើររបស់នាវាផ្សេងទៀត។

**នាវាមានដែនកម្រិតជម្រៅស៊ីទឹក** សំដៅដល់នាវាប្រើម៉ាស៊ីនដែលមានដែនកម្រិតងាកចេញពីទិសបើកបរ ដោយសារជម្រៅស៊ីទឹកនាវាត្រូវការជម្រៅទឹកនិងទទឹងផ្លូវចរគ្រប់គ្រាន់ដើម្បីឱ្យនាវាឆ្លងកាត់បាន។

**នាវាគាំទ្រ** សំដៅដល់នាវាតូចៗដែលផ្ដល់សេវាតាមតម្រូវការរបស់នាវាធំៗ រួមមានសេវាកម្មទូទៅ សេវាគ្រោះអាសន្ន សេវាផ្គត់ផ្គង់ ជាអាទិ៍។

**នាវាក្រោមបទដ្ឋាន** សំដៅដល់នាវាដែលតួ គ្រឿងម៉ាស៊ីន ឧបករណ៍ ឬសុវត្ថិភាពប្រតិបត្តិការ មានស្ថានភាព[illegible]នៅក្រោមបទដ្ឋានដែលតម្រូវដោយអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

**នាវាកណ្ណជារ** សំដៅដល់នាវាសម្រាប់ដឹកកណ្ណជារ និងប្រើទង់សញ្ញាកណ្ណជារនៅលើនាវាជាប្រចាំ។

**នាវិក** សំដៅដល់បុគ្គលដែលបម្រើការងារនៅលើនាវា និងមានបញ្ជីឈ្មោះជានាវិក។

**នាយនាវា** សំដៅដល់នាវិកដែលគ្រប់គ្រងនិងបញ្ជានាវានៅលើនាវាសមុទ្រ។

នាយបើកបរ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិបន្ទាប់ពីនាយនាវា និងជាអ្នកដឹកនាំបញ្ជានាវានៅពេលណាដែលនាយនាវាបាត់បង់សមត្ថភាពដឹកនាំបញ្ជា។

នាយបើកបរទី២ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិបន្ទាប់ពីនាយបើកបរ។

នាយបើកបរទី៣ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិបន្ទាប់ពីនាយបើកបរទី២។

នាយទទួលបន្ទុកបើកបរ សំដៅដល់នាយក្នុងផ្នែកបើកបរ ដែលមានឋានន្តរសក្តិទាបជាងគេបំផុត។

នាវិកជំនាញផ្នែកបើកបរ សំដៅដល់នាវិកជំនាញ ដែលមានគុណវុឌ្ឍិប្រចាំវេនបើកបរនាវា និងបម្រើការងារប្រចាំថ្ងៃក្នុងកម្រិតជំនួយការនៅលើដាន់នាវា។

នាវិកប្រចាំវេនបើកបរ សំដៅដល់នាវិកដែលមានគុណវុឌ្ឍិប្រចាំវេនបើកបរនាវា។

នាយយន្តការីនាវា សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិខ្ពស់បំផុត ហើយដែលទទួលខុសត្រូវលើមេកានិកស្លាបចក្រ ប្រតិបត្តិការ និងថែទាំថបនាការមេកានិក និងអគ្គិសនីនាវា។

នាយយន្តការីទី២ សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិបន្ទាប់ពីនាយយន្តការី និងជាអ្នកទទួលខុសត្រូវសម្រាប់មេកានិកស្លាបចក្រ ប្រតិបត្តិការ និងថែទាំថបនាការមេកានិក និងអគ្គិសនីនាវា នៅពេលដែលនាយយន្តការីនាវាបាត់បង់សមត្ថភាព។

នាយយន្តការីទី៣ សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិបន្ទាប់ពីនាយយន្តការីទី២។

នាយទទួលបន្ទុកម៉ាស៊ីន សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលមានឋានន្តរសក្តិទាបជាងគេបំផុត។

នាយអគ្គិសនីនាវា សំដៅដល់នាយក្នុងផ្នែកម៉ាស៊ីនដែលទទួលខុសត្រូវ សម្រាប់ប្រតិបត្តិការ និងថែទាំថបនាការអគ្គិសនីនាវា។

នាវិកជំនាញផ្នែកម៉ាស៊ីន សំដៅដល់នាវិកជំនាញ ដែលមានគុណវុឌ្ឍិប្រចាំវេនប្រតិបត្តិការម៉ាស៊ីននិងបម្រើការងារប្រចាំថ្ងៃជាជំនួយការនៅក្នុងបន្ទប់ម៉ាស៊ីន។

នាវិកប្រចាំវេនម៉ាស៊ីន សំដៅដល់នាវិកដែលមានគុណវុឌ្ឍិប្រចាំវេនប្រតិបត្តិការម៉ាស៊ីន។

នាវិកជំនាញផ្នែកអគ្គិសនី សំដៅដល់នាវិកជំនាញ ដែលមានគុណវុឌ្ឍិជាជំនួយការសម្រាប់ប្រតិបត្តិការ និងថែទាំថបនាការអគ្គិសនីនាវា។

នាយវិទ្យុទាក់ទង សំដៅដល់នាយក្នុងផ្នែកបើកបរដែលមានគុណវុឌ្ឍិប្រតិបត្តិការ និងថែទាំថបនាការប្រព័ន្ធវិទ្យុនៅលើនាវាសម្រាប់ការទំនាក់ទំនង ការផ្តល់និងទទួលព័ត៌មាន និងការផ្តល់និងទទួលសញ្ញាគ្រោះអាសន្ន។

នាវូបករណ៍ឬឧបករណ៍ សំដៅដល់សម្ភារៈបច្ចេកទេសដែលប្រើប្រាស់នៅលើនាវា។

បរិបាលនាវា សំដៅដល់នាវិកដែលមានគុណវុឌ្ឍិបញ្ជានៅលើនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស មានវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកជាបរិបាលនាវា។

បច្ចេកលក្ខណៈ សំដៅដល់លក្ខណៈពិសេសរបស់មនុស្ស វត្ថុ ឬទីតាំងដែលគេបានប្រើសម្រាប់កំណត់អត្តសញ្ញាណមនុស្ស វត្ថុ ឬទីតាំងនោះ។

ប្រឡាយនាវាចរណ៍ សំដៅដល់គន្លងនាវាចរណ៍ ដែលមានទទឹងតូចចង្អៀត មានជម្រៅទឹកគ្រប់គ្រាន់ និងមានជាតិសញ្ញាជំនួយនាវាចរណ៍ ដើម្បីធានាសុវត្ថិភាពនាវាចរណ៍។

ប្រតិបត្តិករកំពង់ផែ សំដៅដល់នីតិបុគ្គលឬរូបវន្តបុគ្គល ដែលផ្តល់សេវាកម្មកំពង់ផែដល់អ្នកប្រើប្រាស់ [illegible] មានជាអាទិ៍សេវាចូលចតនាវា ផ្ទេរ ផ្ទុកទំនិញពីនាវានិងអ្នកដំណើរ រក្សាទំនិញនិងសេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនិញនិងអ្នកដំណើរ។

ប្រតិបត្តិករនៃឋបនការនុយក្លេអ៊ែលើនាវា សំដៅដល់បុគ្គលដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ឬទទួលស្គាល់ឱ្យធ្វើជាប្រតិបត្តិករនៃឋបនការលើនាវានោះ។

**ផ្លូវទឹក** សំដៅដល់ផ្លូវទឹកក្នុងប្រទេស ដែលរួមមានទន្លេ បឹង ស្ទឹង ព្រែក និងផ្លូវសមុទ្រដែលរួមមានឈូងសមុទ្រ ឆកសមុទ្រ និងព្រែកជាប់សមុទ្រ ហើយដែលអាចបម្រើដល់នាវាចរណ៍។

**ផ្លូវនាវាចរណ៍** សំដៅដល់ផ្នែកស្ថិតនៅក្នុងផ្លូវទឹកសម្រាប់ធ្វើនាវាចរណ៍តាមគោលបំណងផ្សេងៗគ្រប់រដូវកាល។

**ផែនការអភិវឌ្ឍន៍កំពង់ផែ** សំដៅដល់ផែនការសាងសង់កំពង់ផែថ្មី ដែលមានទំនាក់ទំនងផ្សារភ្ជាប់នឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងប្រយោជន៍សាធារណៈ ឬការពង្រឹងបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធកំពង់ផែដែលកំពុងធ្វើប្រតិបត្តិការដោយផ្អែកលើកំណើនចរាចរណ៍ទំនិញឬអ្នកដំណើរ។

**ព្រែកជីក** សំដៅដល់ប្រឡាយនាវាចរណ៍សិប្បនិម្មិត ដែលត្រូវអភិវឌ្ឍនៅក្រៅផ្លូវទឹកសម្រាប់តភ្ជាប់ផ្លូវនាវាចរណ៍។

**ព្យសនកម្ម** សំដៅដល់ការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិ ការរងរបួសឬការបាត់បង់ជីវិត ដែលតម្រូវឱ្យមានសំណង។

**ភិនភាគនាវា** សំដៅដល់ចំណុចពិសេសសម្រាប់សម្គាល់នាវា រួមមានលេខសម្គាល់នាវានិង/ឬឈ្មោះនាវា ប្រវែងបណ្ដោយ ប្រវែងទទឹង ប្រវែងជម្រៅស៊ីទឹក ប្រភេទនាវា ប្រភេទម៉ាស៊ីននាវា ពណ៌របស់នាវាជាអាទិ៍។

**ភ្លើងបើកបរ** សំដៅដល់ភ្លើងសញ្ញាដែលបំពាក់នៅលើនាវា ដើម្បីបង្ហាញអំពីស្ថានភាព និងការតម្រង់ទិសរបស់នាវា រួមមានភ្លើងដងក្ដោង ភ្លើងចំហៀង ភ្លើងកន្សៃ ភ្លើងសណ្ដោង ភ្លើងបីរយហុកសិបដឺក្រេ និងភ្លើងភ្លឹបភ្លែត។

**ភ្លើងដងក្ដោង** សំដៅដល់ភ្លើងពណ៌សដែលដាក់នៅលើអ័ក្សបណ្ដោយនាវាមុខក្រោយ ដែលបង្ហាញក្នុងធ្នូរង្វង់២២៥(ពីររយម្ភៃប្រាំ)ដឺក្រេ។

**ភ្លើងចំហៀង** សំដៅដល់ភ្លើងពណ៌ក្រហមនៅខាងឆ្វេង និងភ្លើងពណ៌បៃតងនៅខាងស្ដាំ បំភ្លឺក្នុងធ្នូរង្វង់១១២,៥(មួយរយដប់ពីរក្បៀសប្រាំ)ដឺក្រេ ពីមុខត្រង់ទៅដល់ចំណុច២២,៥(ម្ភៃពីរក្បៀសប្រាំ)ដឺក្រេចំហៀងខាងក្រោយ។

**ភ្លើងកន្សៃ** សំដៅដល់ភ្លើងពណ៌សដាក់នៅជិតកន្សៃនាវាដែលអាចធ្វើទៅបាន ដែលបំភ្លឺនៅក្នុងធ្នូរង្វង់១៣៥(មួយរយសាមសិបប្រាំ)ដឺក្រេ។

**ភ្លើងសណ្ដោង** សំដៅដល់ភ្លើងពណ៌លឿងដាក់នៅជិតកន្សៃនាវាដែលអាចធ្វើទៅបាន ដែលបំភ្លឺនៅក្នុងធ្នូរង្វង់១៣៥ដឺក្រេ។

**ភ្លើងបីរយហុកសិបដឺក្រេ** សំដៅដល់ភ្លើងបំភ្លឺជាប់ពេញធ្នូរង្វង់៣៦០(បីរយហុកសិប)ដឺក្រេក្នុងប្លង់ដេក។

**អនីយភាពនៃការប៉ះទង្គិច** សំដៅដល់ភាពជឿជាក់នៃការប៉ះទង្គិចអាចកើតមានឡើង។

**អីវ៉ាន់** សំដៅដល់វត្ថុឬរថយន្តរបស់អ្នកដំណើរ ដែលបានដឹកដោយអ្នកដឹកជញ្ជូនស្របតាមកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ។

**អីវ៉ាន់ជាប់ខ្លួន** សំដៅដល់វត្ថុដែលអ្នកដំណើរបានយកតាមខ្លួន ឬបានដាក់ផ្ញើទុកនៅលើនាវាក្នុងកន្លែងកាប៊ីនមួយ ឬបានដាក់នៅក្នុងរថយន្តរបស់ខ្លួនតាមនាវា។

ម្ចាស់នាវា សំដៅដល់បុគ្គលដែលមានសិទ្ធិជាកម្មសិទ្ធិលើនាវា។ ម្ចាស់នាវា រួមមានបុគ្គលដែលជាម្ចាស់លើនាវាផ្ទាល់ខ្លួន ឬក្រុមហ៊ុននាវា។

មេបញ្ជាការផែ សំដៅដល់មន្ត្រីមុខងារសាធារណៈដែលចាត់តាំងដោយក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីទទួលបន្ទុកជានាការពារសុវត្ថិភាពដែនទឹកកំពង់ផែ គ្រប់គ្រងចលនានាវា តាមដាន ត្រួតពិនិត្យការពារការបំពុលទឹក ដាក់បទបញ្ជា និងផ្តល់ការឯកភាពលើសកម្មភាពផ្សេងៗក្នុងកំពង់ផែក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់ខ្លួន។ ជាទូទៅ មេបញ្ជាការផែមានតួនាទីគ្រប់គ្រងផ្លូវទឹកក្នុងកំពង់ផែ។

**ម្ចាស់នាវាភាពវកិច្ច** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានទទួលសិទ្ធិគ្រប់គ្រងនិងធ្វើប្រតិបត្តិការនាវាពីម្ចាស់នាវាស្របតាមកិច្ចសន្យាជួល។

**មន្ត្រីត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាឆ្នេរសមុទ្រនិងនាវាផ្លូវទឹកក្នុងប្រទេស** សំដៅដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មន្ត្រីអធិការកិច្ចនាវានិងកំពង់ផែ** សំដៅដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន ដែលមានគុណវុឌ្ឍិធ្វើអធិការកិច្ចនាវាឆ្នេរសមុទ្រ នាវាផ្លូវទឹកក្នុងប្រទេស យានដ្ឋាននាវា បឋនីយកណ្ឌផែ សំណង់សិល្បការ្យ អង្គបណ្ដែតទឹក និងសកម្មភាពផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យនាវាបរទេស សំដៅដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន ដែលមានគុណវុឌ្ឍិត្រួតពិនិត្យនាវាបរទេស។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីនៃក្រសួង ស្ថាប័ន ដែលមានភារកិច្ចត្រួតពិនិត្យនាវានៅតាមផ្លូវទឹកនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាអនុលោមតាមច្បាប់នេះនិងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

មូលបទច្បាស់លាស់ សំដៅដល់ភស្តុតាងដែលបង្ហាញថា នាវា នាវូបករណ៍ ឬក្រុមនាវិក មិនស្របតាមលក្ខខណ្ឌនៃអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ឬនាយនាវាឬក្រុមនាវិក មិនស្គាល់ច្បាស់អំពីនីតិវិធីសំខាន់ៗនៅលើនាវា ដែលទាក់ទងនឹងសុវត្ថិភាពនាវា និងការបំពុលបរិស្ថាន។

យន្តហោះសមុទ្រ សំដៅដល់យន្តហោះ ដែលសាងសង់ឡើងសម្រាប់ចលនាចរណ៍ហោះឡើងនិងចុះលើផ្ទៃទឹក។

**យានហោះលើទឹក** សំដៅដល់យន្តហោះសមុទ្រ ដែលសាងសង់ឡើងសម្រាប់ហោះហើរក្នុងកម្ពស់ទាបដោយបំពាក់បច្ចេកវិទ្យាប្រើកម្លាំងរុញឡើងពីផ្ទៃទឹក គួបផ្សំជាមួយតួ និងផ្នែកផ្សេងទៀតរបស់តួមានរាងជាអាអេរ៉ូឌីណាមិក។

**យន្តការីនាវា** សំដៅដល់នាវិកដែលទទួលខុសត្រូវគ្រប់គ្រងនិងប្រតិបត្តិការម៉ាស៊ីននាវា។

**លិខិតវិទ្ធវាទ** សំដៅដល់លិខិតដែលធ្វើឡើងជាលាយលក្ខណ៍អក្សរនិងជាផ្លូវការ ក្នុងគោលបំណងដើម្បីប្រកាសបដិសេធដោយមានបង្ហាញអំណះអំណាងលើការទទួលខុសត្រូវពាក់ព័ន្ធចំពោះការបាត់បង់ ឬព្យសនកម្មណាមួយ។

**ល្បឿនសុវត្ថិភាព** សំដៅដល់ល្បឿនអតិបរិមាដែលអាចចាត់វិធានការបញ្ចៀសការប៉ះទង្គិចក្នុងចិរវេលា និងចម្ងាយដែលអាចបញ្ឈប់នាវាបាន។

**វិស័យដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែឬវិស័យដឹកជញ្ជូនតាមផ្លូវទឹក** សំដៅដល់សកម្មភាពឬសេវាកម្មដែលពាក់ព័ន្ធនឹងនាវា នាវិក នាវាចរណ៍ ការដឹកជញ្ជូន ការផ្ទេរផ្ទុកទំនិញនិងអ្នកដំណើរ កំពង់ផែ ចំណតនាវា យានដ្ឋាននាវា ការកសាងនិងថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធជាអាទិ៍។

**វិញ្ញាបនបត្របច្ចេកទេស** សំដៅដល់វិញ្ញាបនបត្រដែលតម្រូវឱ្យមានចំពោះនាវាធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ អនុលោមតាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងបរិស្ថាន ក្រោយការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា។

**វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកបដិវេលេខ** សំដៅដល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិកនៃប្រទេសមួយ ដែលត្រូវបានទទួលស្គាល់ដោយប្រទេសមួយទៀត ស្ថិតក្រោមកិច្ចព្រមព្រៀងនៃប្រទេសទាំងពីរ ដើម្បីអាចឱ្យនាវិកនោះអាចបម្រើការងារលើនាវានៃប្រទេសម្ចាស់សញ្ញាតិមួយទៀតបាន។

**វិទ្យុការីនាវា** សំដៅដល់នាយក្នុងផ្នែកបើកបរដែលមានឋានន្តរសក្តិបន្ទាប់ពីនាយវិទ្យុទាក់ទង និងមានគុណវុឌ្ឍិសម្រាប់ប្រតិបត្តិការនិងថែទាំឋបនាការវិទ្យុទាក់ទងនៅលើនាវា។

**សំណង់សិល្បការ្យផ្លូវទឹក** សំដៅដល់ទំនប់ការពារច្រាំង កំពង់ផែ ទំនប់រលក សន្ទះផ្លូវនាវាចរណ៍ ស្ថានីយជម្រៅទឹកផ្លូវនាវាចរណ៍ ស្ថានីយកណ្ណធារ មជ្ឈមណ្ឌលសម្របសម្រួលនាវាចរណ៍ កំពង់ចម្លង យានដ្ឋាននាវា សញ្ញាជំនួយនាវាចរណ៍។

**សំណង់សិល្បការ្យ** សំដៅដល់សំណង់សិល្បការ្យទូទៅក្រៅពីសំណង់សិល្បការ្យផ្លូវទឹក រួមមាន ស្ពាន បង្គោលបញ្ជូនចរន្តអគ្គិសនី បំពង់ឬទុយោក្រោមបាតសមុទ្រឬទន្លេ ទ្វារទឹក ស្ថានីយជលសាស្ត្រ ជាអាទិ៍។

**សញ្ញាជំនួយនាវាចរណ៍** សំដៅដល់គ្រឿងផ្តល់សញ្ញា ប្រព័ន្ធឬសេវាកម្មដែលបំពាក់នៅលើផ្លូវទឹកនិងធ្វើប្រតិបត្តិការដើម្បីបង្កើនសុវត្ថិភាពនិងប្រសិទ្ធភាពនាវាចរណ៍។

**សំណងរួមលើការខាតបង់** សំដៅដល់សំណងដែលបណ្តាលមកពីការលះបង់ដោយចេតនានូវចំណែកនៃនាវាឬទំនិញលើនាវា ដើម្បីចៀសវាងការបាត់បង់នាវាទាំងស្រុង ហើយដែលចំណែកនោះ ត្រូវបែងចែកតាមគ្រប់ភាគីដែលពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងដំណើរចរណ៍នោះ។

**សញ្ញាបើកបរ** សំដៅដល់រូបសញ្ញានៅលើនាវា សម្រាប់លើកបង្ហាញអំពីប្រភេទនិងសកម្មភាពរបស់នាវា រួមមាន ស្វ៊ែ កោន កោនទល់កំពូល កោនទល់បាត និងស៊ីឡាំង។

**សញ្ញាសំឡេង** សំដៅដល់សំឡេងដែលបន្លឺដោយឧបករណ៍ផ្តល់សញ្ញាសំឡេងរបស់នាវាមួយទៅនាវាផ្សេងទៀត សម្រាប់បញ្ជាក់អំពីចេតនានៃការបើកបររបស់នាវានោះ។

**សញ្ញាភ្លើង** សំដៅដល់សញ្ញាភ្លើងដែលនាវាមួយផ្តល់ទៅនាវាផ្សេងទៀត សម្រាប់បញ្ជាក់អំពីចេតនារបស់នាវានោះ។

**សញ្ញាគ្រាអាសន្ន** សំដៅដល់សញ្ញាដែលនាវាកំពុងស្ថិតនៅក្នុងគ្រាអាសន្ន ផ្តល់ជាសញ្ញាផ្សេងៗ ដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ ដើម្បីស្វែងរកជំនួយសង្គ្រោះ។ សញ្ញាទាំងនោះ រួមមានសញ្ញាភ្លើង សញ្ញាសំឡេង សញ្ញារូបភាពផ្សេងៗ សញ្ញាគ្រាអាសន្នតាមប្រព័ន្ធអេឡិចត្រូនិក។

**ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក** សំដៅដល់ផ្លូវទឹក សំណង់សិល្បការ្យផ្លូវទឹក និងប្រព័ន្ធដែលពាក់ព័ន្ធនឹងការធ្វើនាវាចរណ៍។

**អាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុត** សំដៅដល់អង្គភាពនៃក្រសួង ស្ថាប័ន ឬមជ្ឈមណ្ឌលទំនាក់ទំនងផ្លូវទឹកនិងទទួលព័ត៌មាន ឬកំពង់ផែ ឬស្ថានីយទំនាក់ទំនងរវាងនាវា និងមជ្ឈមណ្ឌលនៅលើគោក ដែលស្ថិតនៅជិតបំផុត។

**អង្គភាពចុះបញ្ជីនាវាសញ្ជាតិខ្មែរ** សំដៅដល់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**អង្គភាពមានសមត្ថកិច្ចចុះបញ្ជីនាវា** សំដៅដល់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

**អង្គការចំណាត់ថ្នាក់នាវា** សំដៅដល់អង្គការដែលបង្កើតឡើងដោយក្រុមម្ចាស់នាវាឬក្រុមសមាគមម្ចាស់នាវា ដើម្បីផ្តល់សេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា និងផ្តល់វិញ្ញាបនបត្របច្ចេកទេសដែលពាក់ព័ន្ធអនុលោមតាមអនុសញ្ញាអន្តរជាតិ។

**អង្គគ្រប់គ្រងកំពង់ផែ** សំដៅដល់អង្គភាពសាធារណៈឬឯកជន ដែលទទួលបន្ទុកការងាររដ្ឋបាល ការគ្រប់គ្រង និងការអភិវឌ្ឍកំពង់ផែ និងក្នុងករណីខ្លះធ្វើប្រតិបត្តិការកំពង់ផែនិងអភិរក្សទីលានបរិវេណដីគោកក៏ដូចជាដែនទឹកកំពង់ផែ។

**អង្គបណ្តែតទឹក** សំដៅដល់សំណង់បណ្តែតទឹកដែលប្រើសម្រាប់គោលបំណងផ្សេងៗ រួមមាន ចំណតនាវា ស្តុកនិងផ្ទេរផ្ទុកទំនិញ សាងសង់ឬជួសជុលនាវា ស្ទូច ខួង បូមស្តារ លំនៅឋាន ភោជនីយដ្ឋាន កម្សាន្ត វារីវប្បកម្ម អាជីវកម្មជាអាទិ៍។

**អ្នកដំណើរ** សំដៅដល់បុគ្គលទាំងឡាយដែលជិះនៅលើនាវាក្រៅពីនាវិក ហើយមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកដំណើរ។

**អ្នកដឹកជញ្ជូន** សំដៅដល់បុគ្គលឬតំណាងរបស់អ្នកដឹកជញ្ជូនដែលបានធ្វើកិច្ចសន្យាដឹកជញ្ជូនទំនិញ ឬកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ ទោះបីជាអនុវត្តដោយខ្លួនឯង ឬប្រគល់ការអនុវត្តកិច្ចសន្យានោះទៅអ្នកដឹកជញ្ជូនបន្ត។

**អ្នកដឹកជញ្ជូនបន្ត** សំដៅដល់បុគ្គលផ្សេងទៀតក្រៅពីអ្នកដឹកជញ្ជូនឬតំណាងអ្នកដឹកជញ្ជូន ដែលអនុវត្តកិច្ចសន្យាដឹកជញ្ជូនទំនិញឬកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ ទោះបីជាកិច្ចសន្យានោះ បានត្រូវប្រគល់ទាំងស្រុង ឬដោយផ្នែកណាមួយ ដោយអ្នកដឹកជញ្ជូនឬតំណាងអ្នកដឹកជញ្ជូន។

**អ្នកលួចរត់តាមនាវា** សំដៅដល់បុគ្គលដែលនៅកំពង់ផែណាមួយឬទីកន្លែងជិតកំពង់ផែនោះ លាក់ខ្លួននៅក្នុងនាវា ដោយគ្មានការយល់ព្រមពីម្ចាស់នាវា ឬនាយនាវា ឬអ្នកទទួលបន្ទុកនាវា ឬបុគ្គលដែលឡើងលើនាវា ក្រោយពេលដែលនាវាបានចាកចេញពីកំពង់ផែឬទីកន្លែងជិតកំពង់ផែនោះ។

**អ្នកដើរសមុទ្រដ៏ល្អ** សំដៅដល់នាវិកដែលមានជំនាញ ចំណេះដឹង និងបទពិសោធក្នុងការគ្រប់គ្រងពេលវេលានិងអនុវត្តកិច្ចការសង្កេតដោយផ្ចិតផ្ចង់ក្នុងប្រតិបត្តិការនាវា។

**អ្នកបើកបរនាវា** សំដៅដល់អ្នកដែលធ្វើប្រតិបត្តិការបើកបរនាវាឆ្នេរសមុទ្រឬនាវាផ្លូវទឹកក្នុងប្រទេស ដោយការបញ្ជាចង្កូតនិងម៉ាស៊ីនតែម្នាក់ឯង។

**ឯកសិទ្ធិ** សំដៅដល់សិទ្ធិដែលនាវិកត្រូវទទួលការសងពីម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ចលើកម្មវត្ថុ ឬសកម្មភាពដែលនាវិកបានបំពេញក្នុងអត្ថប្រយោជន៍របស់ម្ចាស់នាវាឬម្ចាស់នាវាភាវវេទកិច្ច។

**ឯកតាតម្លៃSDR** សំដៅដល់ឯកតាសម្រាប់គិតតម្លៃរូបិយបណ្ណដែលកំណត់ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



៩